00861316



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 16-Nov-2012, 12:39
CMS/CFO: Sann Rada

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង
# សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១២**

**ម៉ោង ០៩:០១ នាទី**

**សវនាការលើកទី១៣១**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍

*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)

*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

លោកស្រី សែ កុលវុឌ្ឍី

លោក ម៉ាតេអូ គ្រីប៉ា

*(Mr.Matteo CRIPPA)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

លោក ច័ន្ទ តារាវស្មី

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល

*(Mr. Vincent de wilde d'ESTMAEL)*

លោក ឌេល លីសាក់ (*Mr. Dale LYSAK*)

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក អេនឌ្រូ អ៊ីនូហ្ស៊ី (*Mr. Andrew IANUZZI*)

លោក ហ្សាស្ពើ ប៉ៅ *(Mr Jasper PAUW)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ

*(Ms. Anta GUISSÉ)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោកស្រី ម៉ុច សុវណ្ណារី

លោកស្រី ស៊ីន សុវ៉ន

លោកស្រី នូស៊ីន សាការ៉ាទី

*(Ms. Nushin SAKARATI)*

លោកស្រី គ្រីស្ទីន ម៉ាទីណូ

*(Ms. Christine MARTINEAU)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី ស្ងួ សុទ្ធាវី

# បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ខេល លីសាក់ | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោក ហ្វាស្តើ ប៉ៅ | អង់គ្លេស |
| លោក អាង ឧត្តម | ខ្មែរ |
| លោក គង់ សំអុន | ខ្មែរ |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោកស្រី គ្រីស្ទីន ម៉ាទីណូ | បារាំង |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក ប៉េជុយ ជីបសែ (TCW-507) | ខ្មែរ |
| លោក មាស សារ៉ាន់ (TCCP-82) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី:** **លោក ប៉េជុយ ជីបសៃ** (TCW-507)


សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី៖ ........ ទំព័រ ៣

សួរដោយលោក សុន អរុណ ផ្តើមពី៖ ........ ទំព័រ ៩

សួរដោយលោក ហ្សាស្តេី ប៉ៅ ផ្តើមពី៖ ........ ទំព័រ ១៨

សួរដោយលោក អាង ឧត្តម ផ្តើមពី៖ ........ ទំព័រ ៥៩


**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី:** **លោក មាស សារ៉ាន់** (TCCP-82)


សួរដោយប្រធានអង្គជំនុំ ផ្តើមពី៖ ........ ទំព័រ ៦៥

សួរដោយលោកស្រី គ្រីស្ទីន ម៉ាទីណូ ផ្តើមពី៖ ........ ទំព័រ ៦៧

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០២:០២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយនៅព្រឹកនេះ អង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មសាក្សី ជីបសែ បញ្ចប់ ដោយមេធាវីការពារក្តីដែលនឹងត្រូវតាំងសំណួរដេញដោល។ ហើយមន្ត្រីក្រឡាបញ្ជីសវនាការ លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនៅថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន លើកឡើងតែជនជាប់ចោទ នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមបន្ទប់សវនាការដោយមូលហេតុសុខភាព។

ជនជាប់ចោទ អៀង សារី អវត្តមានដោយមូលហេតុសុខភាព ប៉ុន្តែយោងតាមលិខិតលះបង់សិទ្ធិមានដែនកំណត់របស់ជនជាប់ចោទ ឯកសារលេខ E237 និង E237/1 ជនជាប់ចោទបានលះបង់សិទ្ធិមានវត្តមាននៅក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការនៃការស្តាប់សក្ខីកម្មសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន ក្នុងនោះក៏មានសាក្សីដែលមានរហស្សនាម TCW-507 ដែលអង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មនៅក្នុងថ្ងៃនេះ និងដើមបណ្តឹងរដ្ឋប្បវេណីមួយរូបដែលមានរហស្សនាម TCCP-82 ដែលនឹងស្តាប់សក្ខីកម្មបន្ទាប់ពីបញ្ចប់សក្ខីកម្មសាក្សី TCW-507។ សាក្សីរូបនេះមានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការនេះ។ រីឯដើមបណ្តឹងរដ្ឋប្បវេណី TCCP-82 មានវត្តមាននៅបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។

[០៩:០៤:២៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ លោកមេធាវីការពារក្តីលោក នួន ជា តើលោកបានទទួលនូវកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ អៀង សារី ដែលធ្វើឡើងដោយគ្រូពេទ្យទទួលបន្ទុកពិនិត្យថែទាំសុខភាពជនជាប់

ចោទនៅ អ.វ.ត.ក នេះដែរឬទេ?

[០៩:០៥:៥៨]

**លោក ហ្សាស្កើ ប៉ោ៖**

ខ្ញុំពិតជាបានទទួល។ អរុណសួស្តីអស់លោក លោកស្រីទាំងអស់គ្នា។ យើងបានទទួលរបាយ-ការណ៍សុខភាពរបស់ នួន ជា ហើយ នួន ជា ស្នើសុំតាមដានសវនាការពីបន្ទប់រង់ចាំខាងក្រោមពេញ ១ថ្ងៃ ដូចដែលមានសំអាងហេតុនៅក្នុងរបាយការណ៍សុខភាព។ យើងខ្ញុំនឹងរៀបចំលិខិតបោះបង់សិទ្ធិ ហើយដាក់ជូនអង្គជំនុំជម្រះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានស្តាប់សំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ សូមទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយសម្រាប់រយៈពេលធ្វើសវនាការពេញ១ថ្ងៃនេះ។ ដោយមូលហេតុលោក នួន ជា មានបញ្ហាសុខភាព ដូចមានចង្អុលបង្ហាញបញ្ជាក់នៅក្នុងកំណត់ហេតុរបាយការណ៍ពិនិត្យសុខភាព របស់វេជ្ជបណ្ឌិតទទួលបន្ទុកពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅមន្ទីរឃុំឃាំងនៃ អ.វ.ត.ក។

តាមកំណត់ហេតុពិនិត្យសុខភាពលោក នួន ជា ដែលធ្វើឡើងដោយលោកវេជ្ជបណ្ឌិត ឈា គន្ធាវី បានបញ្ជាក់ថា នៅព្រឹកនេះលោក នួន ជា មានបញ្ហាសុខភាពឈឺចង្កេះ រាក ហើមពោះ សម្រាន្តមិនលក់ អស់កម្លាំងខ្លាំង។ ហើយលោកវេជ្ជបណ្ឌិតបានផ្តល់អនុសាសន៍ថា អង្គជំនុំជម្រះគប្បីអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ខាងក្រោម។ ដូច្នេះសំណើសុំរបស់លោក នួន ជា ធ្វើឡើងមានមូលហេតុសមស្រប។ អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យលោក នួន ជា នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលធ្វើសវនាការពេញ១ថ្ងៃនេះ។

[០៩:០៦:៥៨]

ដោយលោក នួន ជា លះបង់សិទ្ធិចូលរួមដោយផ្ទាល់នៅក្នុងកិច្ចដំណើរការសវនាការនៅក្នុងបន្ទប់សវនាការនេះ។ អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្តី នួន ជា ប្រគល់ជូនមកឲ្យអង្គជំនុំជម្រះភ្ជាមនូវពាក្យសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការ ដោយចុះហត្ថលេខា ឬស្នាមផ្តិត -- ស្នាមម្រាមដៃជាក់ច្បាស់ជនជាប់ចោទ នួន ជា។

ហើយបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួមនឹងតាមដានកិច្ចដំណើរការសវនាការ ពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះសម្រាប់រយៈពេលនៃកិច្ចដំណើរការសវនាការពេញ១ថ្ងៃនេះ។

ហើយជាបន្តនេះ តើអស់លោក លោកស្រីចៅក្រមមានសំណួរអ្វីសួរសាក្សីរូបនេះដែរឬទេ?

បាទ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

[០៩:០៧:៥៥]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំជាចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ខ្ញុំមានសំណួរមួយចំនួនដើម្បីចោទសួរលោកក្នុងគោលដៅបំភ្លឺនូវការឆ្លើយរបស់លោកដែលបានធ្វើឡើងកាលពីថ្ងៃមុន។ ខ្ញុំគិតថាប្រហែលជាខ្ញុំមិនសូវស្គាល់តំបន់ដែលលោកបាននិយាយ គឺ ឧទាហរណ៍ដូចជាតំបន់សៀមរាបជាដើម។ ម្សិលមិញលោកបាននិយាយថា លោកធ្វើការនៅមន្ទីរសន្តិសុខពង្រ តើនៅក្នុងខែមេសា ឆ្នាំ៧៥ លោកជាបុគ្គលិកនៅមន្ទីរសន្តិសុខពង្រនោះមែនដែរឬទេ?

[០៩:០៨:៤៩]

**លោក ប៉េជុយ ជីបសែះ៖**

**ឆ៖** បាទ ខ្ញុំនៅឆ្នាំ៧៥ នោះ ខ្ញុំក៏ជាបុគ្គលិកនៅសន្តិសុខពង្រដែរ។

**ស៖** តើមន្ទីរសន្តិសុខនោះស្ថិតនៅក្នុងស្រុកជីក្រែងមែនដែរឬទេ?

**ឆ៖** បាទ មន្ទីរសន្តិសុខពង្រស្ថិតនៅក្នុងស្រុកជីក្រែងដែរ។

**ស៖** ហើយស្រុកជីក្រែងនោះស្ថិតនៅក្នុងតំបន់សៀមរាប-ឧត្តរមានជ័យ តើមែនទេ?

**ឆ៖** បាទ មែន។ ស្រុកជីក្រែងស្ថិតនៅក្នុងតំបន់សៀមរាប-ឧត្តរមានជ័យ។

**ស៖** តើមន្ទីរស្រុកជីក្រែងនោះមានទីតាំងស្ថិតនៅឯណាដែរ?

**ឆ៖** មន្ទីរស្រុកជីក្រែងស្ថិត មានទីតាំងនៅ សព្វថ្ងៃថានៅផ្សារកំពង់ក្ដី។ នៅអគារចាស់ៗនៅត្រង់ចំណុចទីប្រជុំជន ផ្សារកំពង់ក្ដី។

**ស៖** កាលពីថ្ងៃមុន នៅពេលដែលលោកនិយាយអំពីអគារចាស់នៃផ្សារជីក្រែង តាមពិតទៅ ផ្ទះទាំងនោះ គឺថាស្ថិតនៅក្នុងកំពង់ក្ដី។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ ផ្សារជីក្រែង គឺបានន័យថា ផ្សារកំពង់ក្ដីនោះឯង។ អានេះ គឺមានន័យតែមួយ ផ្សារជីក្រែង គឺផ្សារកំពង់ក្ដី។

[០៩:១១:១៣]

**ស៖** ក្រុងកំពង់ក្ដី ស្ថិតនៅចម្ងាយប្រហែលជា៦០គីឡូម៉ែត្រពីសៀមរាប ហើយស្ថិតនៅលើផ្លូវជាតិលេខ៦ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ ទីប្រជុំជនផ្សារកំពង់ក្ដីនោះ ស្ថិតនៅ៦០គីឡូម៉ែត្រ ពីខេត្តសៀមរាប ពិតប្រាកដមែន។

**ស៖** ខ្ញុំយល់ថា តំបន់ដែលនៅជុំវិញកំពង់ក្ដី ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមតាំងពីយូរមកហើយ មុនខែមេសា ឆ្នាំ៧៥ ជាពិសេសមានការបង្កើតសហករណ៍តាំងពីមុនពេលវ៉ៃយកទីក្រុងភ្នំពេញទៅទៀត។ តើលោកអាចជម្រាបបានទេ ថានៅពេលណាដែលកំពង់ក្ដីស្ថិតនៅក្រោមការក្ដោបក្ដាប់របស់ខ្មែរក្រហម?

**ឆ៖** បាទ កំពង់ក្ដីនៅក្រោមការក្ដោបក្ដាប់របស់ខ្មែរក្រហមចាប់ពីឆ្នាំ១៩៧០មក គឺថាក្រោយរដ្ឋប្រហារហ្នឹង គឺទីតាំងហ្នឹង ស្រុកហ្នឹង ស្ថិតនៅក្នុងការគ្រប់គ្រងរបស់ខ្មែរក្រហម។

**ស៖** ដូច្នេះ នៅពេលខ្មែរក្រហមវ៉ៃយកកំពង់ក្ដីនៅឆ្នាំ៧០ តើប្រជាជននៅកំពង់ក្ដី ត្រូវបានគេជម្លៀសចេញដែរឬទេ?

**ឆ៖** ប្រជាជននៅកំពង់ក្ដី គឺវាជម្លៀសតែ យើងហៅថា ជនជាតិចិន ឲ្យទៅនៅទៅដល់ទៅភូមិដាច់ស្រយាល ដូចជាសព្វប៉ាមង់(?) គឺថានិយាយទៅ ភូមិដែលនៅទីតាំងលើ ចម្ងាយ៣០, ៤០ គីឡូពីផ្សារកំពង់ក្ដី គឺថាជនជាតិចិន វាជម្លៀសទៅ។ ហើយនិងអ្នករដ្ឋការ ដូចជា គ្រូបង្រៀនផ្សេងៗ ក៏វាជម្លៀសទៅ ទៅឆ្ងាយពីកំពង់ក្ដី។

[០៩:១៣:៤៧]

**ស៖** តើគេមានប្រាប់លោកថា ហេតុអ្វីបានគេជាជម្លៀសជនជាតិចិន មន្ត្រីរដ្ឋការ ចេញពីកំពង់ក្ដីដែរឬទេ?

**ឆ៖** បាទ ចំពោះការនោះ គឺខ្ញុំពុំអាចឆ្លើយបានទេ មិនដឹងថាវាជម្លៀសនោះ យ៉ាងដូចម្ដេច គេមិនបានប្រាប់ខ្ញុំទេ។

**សៈ** កាលពីម្សិលមិញ លោកក៏បាននិយាយអំពីទាហាន និងអតីតមន្ត្រីរដ្ឋការនៃសាធារណរដ្ឋខ្មែររបស់ លន់ នល់ ដែលត្រូវបានដាក់នៅក្នុងផ្ទះនៅជុំវិញផ្សារជីក្រែង ឥឡូវនេះ ខ្ញុំយល់ហើយ ថាជាផ្សារកំពង់ក្តី។ ទាហាន និងមន្ត្រីរដ្ឋការទាំងអស់នេះ តើពួកគាត់មកពីសៀមរាប ឬក៏មកពីកំពង់ក្តី?

[០៩:១៤:៥៦]

**ឆៈ** បាទ មន្ត្រី មេទាហាន និងមន្ត្រីរដ្ឋការខ្លះ ជាមេដឹកនាំកំពូល -- ធំៗនៅក្នុងខេត្តហ្នឹងគឺវាយកមកពីសៀមរាប មិនមែនយកពីកំពង់ក្តីហ្នឹងទេ គឺយកពីក្រុងសៀមរាបតែម្តង។

**សៈ** កាលពីម្សិលមិញខ្ញុំយល់ថា ព័ត៌មានទាំងអស់នេះ គឺលោកទទួលបានពីសាក្សីផ្សេងទៀត ឬមួយក៏ព័ត៌មានទាំងអស់ហ្នឹង លោកដឹងដោយខ្លួនឯង។ តើលោកនៅកំពង់ក្តីទេ ហើយលោកបានឃើញវត្តមានមន្ត្រីអ្នករដ្ឋការ និងទាហានទាំងអស់នោះដោយផ្ទាល់ភ្នែករបស់លោកទេ ឬក៏លោកដឹងតាមគេទេ?

**ឆៈ** ខ្ញុំដឹងវត្តមានទាហានដែលមក ជម្លៀសមកពីសៀមរាបហ្នឹងដោយដំណឹងហ្នឹង គឺដឹងពីប្រជាជន និងពីពួកដែលធ្វើការនៅក្នុងសន្តិសុខ គឺថាមិនបានឃើញដោយខ្លួនឯងទេបាទ។

**សៈ** តើគេមានបានប្រាប់លោកទេ ថាហេតុអ្វីបានជាគេជម្លៀសទាហាន និងមន្ត្រីរដ្ឋការពីសៀមរាប យកមកដាក់នៅកំពង់ក្តី ដែលស្ថិតនៅចម្ងាយ៦០ គីឡូម៉ែត្រពីគ្នានោះ? គេមានបានប្រាប់មូលហេតុទេ ថាមូលហេតុអ្វីបានជាគេនាំពីសៀមរាប មកដាក់នៅកំពង់ក្តីហ្នឹង?

[០៩:១៦:៥៣]

**ឆៈ** ចំពោះមូលហេតុ គឺគេមិនបានប្រាប់បានពិតប្រាកដទេ គឺថា ខ្ញុំដឹងតាមរយៈប្រជាជន ហើយនិងពួកធ្វើការនៅកន្លែងសន្តិសុខ គឺគេថាពួកហ្នឹងជាពួកដែលក្បត់បដិវត្តន៍របស់វា បានជាវាត្រូវយកមកឲ្យកសាងខ្លួននៅផ្សារកំពង់ក្តី។ ខ្ញុំដឹងតែប៉ុណ្ណឹង។

**សៈ** តើលោកផ្ទាល់ក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យលោកនៅសៀមរាបផ្ទាល់ ឬក៏លោកបានស្តាប់ឮគេនិយាយអំពីជោគវាសនារបស់ប្រជាជនស៊ីវិលនៅសៀមរាប? តើប្រជាជនស៊ីវិលទាំងអស់នោះ ត្រូវបានគេបង្ខំឲ្យចាកចេញពីក្រុងសៀមរាបដែរឬទេ?

**ឆៈ** បាទ ចំពោះសំណួរនេះ គឺខ្ញុំមិនអាចឆ្លើយបានទេ ពីព្រោះវាមិនទាន់ច្បាស់ គឺថាខ្ញុំមិនអាចឆ្លើយបាន។

**សៈ** កាលពីម្សិលមិញ លោកបានឆ្លើយថា “លោកបានជួបអ្នកដែលត្រូវបានគេជម្លៀស”។

ប្រជាជនដែលត្រូវបានជម្លៀសនោះ គឺតើពួកគាត់មកពីទីណា? មកពីភ្នំពេញ? ពីសៀមរាប? ឬក៏មកពីតំបន់ផ្សេងទៀតនៃប្រទេសកម្ពុជា?

**ឆ៖** ចំពោះការដឹងរបស់ខ្ញុំចំពោះប្រជាជនស៊ីវិល ដែលបានជម្លៀសពីសៀមរាប ឬក៏ក្រុងភ្នំពេញហ្នឹង គឺខ្ញុំក៏ដឹងតាមរយៈដែលប្រជាជនដែលគេនិយាយតៗគ្នាទៅ ក៏ខ្ញុំស្ដាប់បាន ក៏ខ្ញុំឆ្លើយតែម្ដង។ ឆ្លើយទៅតាមសម្ដីរបស់ប្រជាជន គឺដឹងដោយប្រយោល មិនបានដូចថាឃើញជាក់ស្ដែង។

[០៩:១៩:៣៧]

**ស៖** លោកសាក្សីចំពោះលោកផ្ទាល់ តើលោកបានជួបប្រជាជនជម្លៀសដែរឬទេ? ហើយលោកមានបានពិភាក្សាជាមួយពួកគាត់ដែរឬទេ?

**ឆ៖** ចំពោះប្រជាជនជម្លៀសហ្នឹង គឺខ្ញុំបានជួប ពីព្រោះថាពេលដែលខ្ញុំបានចេញពីខ្មែរក្រហមនៅឆ្នាំ៧០ មកគឺគេឲ្យមកនៅជាប្រជាជន ខ្ញុំក៏តែងតែជួបពួកប្រជាជនជម្លៀសដែលនៅក្នុងភូមិរបស់ខ្ញុំហ្នឹងគឺថាជួប តែងជួប។ ប៉ុន្តែគឺថាវាមិនដឹងជាប៉ុន្មាននាក់ទេ វា ពេលនេះ ខ្ញុំជួបច្រើនគ្នាដែរ ប៉ុន្តែថាចំនួនខ្ញុំអត់បានចាំ ប៉ុណ្ណឹង។

**ស៖** ខ្ញុំសួរសំណួរដើម្បីឲ្យបំភ្លឺបញ្ហាមួយចំនួនដែលខ្ញុំគិតថាមានបញ្ហាបកប្រែ។ លោកបានឆ្លើយថានៅឆ្នាំ១៩៧០ លោកបានជួបអ្នកជម្លៀស។ ខ្ញុំស្ដាប់ឮអ៊ីចឹងតាមការបកប្រែ។ តើពិតជានៅឆ្នាំ៧០ហ្នឹង ឬក៏ក្រោយទេ? គឺថាលោកបានឆ្លើយថានៅពេលលោកចាកចេញពីខ្មែរក្រហម ដូច្នេះខ្ញុំចង់ដឹងថាតើលោកបានជួបអ្នកជម្លៀសហ្នឹងនៅឆ្នាំណា?

**ឆ៖** ចំពោះសំណួរនេះ ខ្ញុំឆ្លើយថា ខ្ញុំជួបអ្នកជម្លៀសនៅក្រោយឆ្នាំ៧៥ មិនមែនថាជួបនៅឆ្នាំ៧០គត់ទេ អាហ្នឹងមិនទាន់មានការជម្លៀសប្រជាជនទេ គឺនៅ។ ដូច្នេះក្រោយ៧៥ បានខ្ញុំអាចជួបជាមួយអ្នកជម្លៀសបាទ។

[០៩:២១:៣៦]

**ស៖** នៅ -- តើនៅពេលណាដែលគេនិយាយអំពីប្រជាជន១៧ មេសា? តើការហៅថាជាប្រជាជន១៧ មេសា នេះហៅតែចំពោះប្រជាជនដែលជម្លៀសចេញពីភ្នំពេញ ឬក៏ហៅចំពោះប្រជាជនដែលគេជម្លៀសចេញពីគ្រប់ក្រុងទាំងអស់នៅក្នុងប្រទេសកម្ពុជា?

**ឆ៖** បាទ ចំពោះពាក្យថា "១៧មេសា" ហ្នឹង គឺសំដៅលើប្រជាជនទាំងអស់ដែលខ្មែរក្រហមជម្លៀសពីគ្រប់ខេត្តក្រុងទូទាំងប្រទេស គឺថាជាសំដៅទាំងអស់តែម្ដង គឺមិនមែនថាសំដៅតែខេត្ត

សៀមរាប ឬក៏ភ្នំពេញទេ គឺសំដៅគ្រប់កន្លែងទាំងអស់ គេហៅថា ពួក -- ខ្មែរក្រហមហៅថា "ពួក១៧ មេសា"។

**សៈ** ប្រជាជនដែលត្រូវបានជម្លៀស ពីដំបូង តើលោកដឹងទេថានៅក្នុងស្រុករបស់លោកនោះ មានការជម្លៀសផ្សេងទៀត មានការផ្លាស់ទីប្រជាជនផ្សេងទៀត? ឧទាហរណ៍លោកដឹងទេថា អ្នកជម្លៀសមកពីភ្នំពេញនោះ ត្រូវបានគេបង្ខំឲ្យជម្លៀសចេញពីស្រុកហ្នឹងទៅកន្លែងផ្សេងទៀត តើលោកដឹងទេថាមានការជម្លៀសប៉ុន្មានដងចេញពីភ្នំពេញទៅស្រុក ហើយចេញពីស្រុកហ្នឹងទៅកន្លែងណាផ្សេងទៀតទេ?

[០៩:២៣:១៧]

**ឆះ** ចំពោះសំណួរនេះគឺខ្ញុំមិនដឹងច្បាស់ទេ ពីព្រោះជម្លៀសហ្នឹងពេលជម្លៀសហ្នឹងគឺខ្ញុំក៏នៅក្នុងសន្តិសុខពង្រ វាការដឹងគឺដឹងតាមរយៈតែពួកសន្តិសុខវាប្រាប់។ ដូច្នេះគឺការជម្លៀសវា ខ្ញុំគ្រាន់ដឹងថាឆ្នាំ៧០គត់ គឺមិនទាន់មានអ្នក១៧ ទេ គឺថាអាហ្នឹងជម្លៀស ដែលថាជនជាតិចិនចេញពីផ្សារទៅនៅជនបទឆ្ងាយៗ ហើយដល់ឆ្នាំ៧៥ ជម្លៀសប្រជាជនដែលនៅក្រុងសៀមរាប និងបណ្ដាក្រុងផ្សេងទៀតមកនៅជនបទចុងកាត់មាត់ញក តែប៉ុណ្ណឹង។

**សៈ** នៅខែមេសា ឆ្នាំ១៩៧៥ នៅពេលដែលខ្មែរក្រហមដណ្ដើមបានជ័យជម្នះ តើស្ថានភាពស្បៀងអាហារនៅក្នុងតំបន់របស់លោកមានសភាពយ៉ាងម៉េចដែរ? តើមានបញ្ហាទេ នៅស្រុករបស់លោកហ្នឹង ខាងស្បៀងអាហារនោះ?

**ឆះ** ក្រោយឆ្នាំ៧៥ បញ្ហាស្បៀងអាហារនៅក្នុងស្រុកហ្នឹងគឺមានការលំបាកខ្លាំងណាស់ គឺថាអ្នកដែលត្រូវពួកវាជម្លៀសទៅហ្នឹងមានការស្លាប់ ដោយសារអត់បាយក្រហាយទឹក ដោយសារពលកម្មធ្ងន់ធ្ងរ គឺមានសភាពលំបាកខ្លាំងដោយសារខ្វះស្បៀង។

**សៈ** លោកសាក្សី តើស្ថានភាពបែបហ្នឹងលោកបានឃើញផ្ទាល់ ជួបប្រទះដោយផ្ទាល់ ឬក៏គ្រាន់តែដឹងតាមរយៈប្រភពផ្សេងដែលគេប្រាប់លោកទេ?

[០៩:២៥:៤៥]

**ឆះ** បាទ ខ្ញុំបានដឹងហ្នឹង គឺដោយសារតែប្រភពផ្សេងប្រាប់តែម្ដង ពីព្រោះថាយើងមិនអាចដឹងដោយផ្ទាល់ប្រាកដទេ ពីព្រោះយើងនៅៗក្នុងការធ្វើការជាមួយនឹងខ្មែរក្រហមនៅឡើយ។

**សៈ** មុនខែមេសា ឆ្នាំ៧៥ តើមានគ្រួសារចាម ដែលរស់នៅក្នុងតំបន់របស់លោកដែរឬទេ?

**ឆ៖** មុនឆ្នាំ៧៥ ចំពោះគ្រួសារចាម គឺចំពោះខ្ញុំមិនដឹងទេ គឺដឹងតែក្រោយឆ្នាំ៧៥។

**ស៖** ចុះក្រោយខែមេសា ឆ្នាំ៧៥ លោកដឹងអ្វីខ្លះពីប្រជាជនចាមទាំងអស់នេះ?

**ឆ៖** ខ្ញុំដឹងថា ចាមក្រោយ៧៥ ហ្នឹង គឺវាជម្លៀសទៅនៅភូមិខ្ញុំ ស្ថិតនៅក្នុងឃុំពង្រក្រោមហ្នឹង គឺឲ្យនៅតាមផ្ទះប្រជាជន ហើយវាឲ្យចាមហ្នឹងគឺ តែវាកាប់ជ្រូក វាឲ្យហូបសាច់ជ្រូកដែរ។ ដូច្នេះហើយ ដើម្បីរស់គ្នាក៏ធ្វើតាមតែវាឲ្យធ្វើអី គឺធ្វើនោះ។ ហ្នឹងគឺខ្ញុំឃើញថាចាមហ្នឹង គ្នារស់នៅដោយលំបាក។

**ស៖** តើលោកដឹងទេថា ប្រជាជនចាមនោះមានចេញមកពីខាងណាដែរ?

[០៩:២៨:០៥]

**ឆ៖** បាទ ខ្ញុំចំពោះការដឹងថា ចេញពីកន្លែងណាហ្នឹង គឺមិនបានដឹងទេ ដោយៗខ្ញុំពុំបានស៊ើប -- សាកសួរ ឬមួយក៏អ្នកឯទៀតមិនបានផ្តល់ព័ត៌មានឲ្យខ្ញុំ គឺអត់ដឹងថាមកពីណាទេ គឺដឹងតែនៅក្នុងភូមិជាមួយអ្នកមូលដ្ឋាន។

**ស៖** តើលោកបានឃើញផ្ទាល់ភ្នែក ចំពោះការរើសអើងផ្សេងៗចំពោះប្រជាជនប្រភេទមួយចំនួនដែរឬទេ? ហើយប្រសិនបើមានការរើសអើងមែន តើមានការរើសអើងបែបណាខ្លះដែរ?

**ឆ៖** ក្នុងការរើសអើងប្រជាជន១៧ក្តី ជាជនជាតិចាម ឬមួយក៏អ្នកមន្ត្រីរាជការដែលវាជម្លៀសទៅហ្នឹង គឺខ្ញុំឃើញថាវាឲ្យធ្វើការ គឺធ្ងន់ធ្ងរដូចជាពលកម្មទៅ ស្ទូងដក ឬមួយក៏រែកដី លើកទំនប់ជីកប្រឡាយហ្នឹង គឺវាចាត់តាំងឲ្យទៅ។ ការងារណាលំបាកៗ គឺវាឲ្យទៅ ហើយពួកមូលដ្ឋានវាគ្រាន់តែឲ្យជាអ្នកដឹកនាំ។ បើមានខុសឆ្គងអីខ្លះ គឺវាអនុគ្រោះឲ្យ ប៉ុន្តែចំពោះអ្នក១៧ក្តី អ្នកមន្ត្រីរាជការក្តី អតីតទាហាន ប៉ូលិសក្តី គឺវាមិនអនុគ្រោះទេ គឺវារកតែរឿងសម្លាប់តែម្តង។

[០៩:៣០:០០]

**ស៖** មន្ទីរសន្តិសុខពង្រ ត្រូវបានបិទនៅឆ្នាំ១៩៧៧នេះ បើតាមចម្លើយរបស់លោក។ ក៏ប៉ុន្តែតើការរើសអើងចំពោះប្រជាជនដែលលោកបាននិយាយនោះ បាននៅតែបន្តអនុវត្តដែរឬទេ ក្រោយឆ្នាំ៧៧នោះ?

**ឆ៖** ខ្ញុំឃើញថា វានៅតែរើសអើងរហូត មិនមានការកែសម្រួលអីទេ គឺព្រោះថា ៧៧ ដែលខ្ញុំមកនៅតាមភូមិហើយ ក៏ឃើញថាវានៅតែដាក់អ្នក១៧ហ្នឹងឲ្យធ្វើការធ្ងន់ធ្ងរ ហើយបាយទឹកអី ក៏គ្នាមិនបានហូបគ្រប់គ្រាន់។ អាហ្នឹងខ្ញុំឃើញជាក់ស្តែងអ៊ីចឹង។

**ស៖** ខ្ញុំមានសំណួរចុងក្រោយលោកសាក្សី។ ក្រោយពីការបិទមន្ទីរសន្តិសុខពង្រ តើគេមាន

បង្កើតមន្ទីរសន្តិសុខផ្សេងទៀតទេនៅក្នុងស្រុករបស់លោកនោះ ហើយបើបង្កើតតើមន្ទីរសន្តិសុខនោះឈ្មោះអ្វីដែរ?

**ឆ៖** សំណួរនេះក៏ខ្ញុំដឹងតាមរយៈប្រជាជនដែរ គឺក្រោយពីបិទនៅមន្ទីរសន្តិសុខ -- កន្លែងសន្តិ-សុខពង្រមក គឺពួកវាក៏មកធ្វើនៅទីតាំងវត្តកំពង់ក្ដី ក្នុងឃុំកំពង់ក្ដី ហើយដែលថាឲ្យច្បាស់ជាងនេះ ខ្ញុំក៏មិនដឹងដែរ គឺថាគ្រាន់តែដឹងថា ក្រោយបិទឯណោះ វាបានធ្វើកន្លែងថ្មីនៅវត្តកំពង់ក្ដី។

[០៩:៣២:៤៣]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកសាក្សី ដែលបានឆ្លើយបញ្ជាក់ជូនខ្ញុំ។ ខ្ញុំអស់សំណួរហើយលោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តអង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក នួន ជា ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

**លោក សុន អរុណ៖**

សូមគោរពអង្គសវនាការ សូមគោរពលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរដោយលោក សុន អរុណ៖**

**ស៖** ជម្រាបសួរលោក ជីបសែ។ ខ្ញុំជាមេធាវីរបស់លោក នួន ជា។ ខ្ញុំឈ្មោះ សុន អរុណ។ ខ្ញុំមានសំណួរមួយចំនួនសម្រាប់សួរលោកនៅព្រឹកនេះ។ នៅដើមដំបូងនេះ ខ្ញុំសូមសួរថា ពីរឿងប្រវត្តិរបស់លោកបន្តិច ពីរឿងកាលពីលោកនៅសិក្សា លោកសិក្សាដល់ថ្នាក់ត្រឹមណាដែរ?

**លោក ប៉េជុយ ជីបសែ៖**

**ឆ៖** បាទ ខ្ញុំបានរៀនសូត្រពីសម័យសង្គមរាស្ត្រនិយមហ្នឹង គឺខ្ញុំរៀនដល់ថ្នាក់ទី៤ ៗហ្នឹងខ្ញុំរៀននៅអនុវិទ្យាល័យរស្មីសោភណ្ឌាស្ទោង ក្នុងខេត្តកំពង់ធំ គឺខ្ញុំរៀនដល់ថ្នាក់ទី៤ទៅ ស្រុកក៏រដ្ឋប្រហារ ក៏ខ្ញុំបានទៅនៅជាមួយឪពុកម្ដាយនៅក្នុងទឹកដី ខេត្តសៀមរាបវិញ គឺនៅក្នុងភូមិតាព័រលើ ឃុំពង្រក្រោម ស្រុកជីក្រែង ខេត្តសៀមរាប។

[០៩:៣៤:៣៨]

**ស៖** អរគុណ។ ពេលដែលលោកឈប់រៀន លោកបានចូលកងទ័ពនៅឆ្នាំ១៩៧២ បើខ្ញុំចាំមិនខុសទេ ត្រឹមត្រូវទេ?

**ឆ៖** បាទ លោកនិយាយហ្នឹងគឺត្រឹមត្រូវ។

**ស៖** ពេលដែលលោកចូលជាកងទ័ព ពីម្សិលមិញលោកបានឆ្លើយចំពោះ ឆ្លើយទៅព្រះរាជ-អាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីរួចហើយថា លោកចូលកងទ័ពខ្មែរក្រហម ចូលកងទ័ពរំដោះរបស់ខ្មែរក្រហមនៅតាំងគោក។ ពេលនោះតាំងគោកមានវ៉ៃគ្នាខ្លាំង លោកបានបញ្ជាក់ទៀតថា ចេនឡាអីអ៊ីចឹងទៅឈ្មោះ។ ហើយរួចពីហ្នឹងមកលោកក៏ភៀសខ្លួនចេញពីកងទ័ពទៅនៅស្រុកវិញ។ ខ្ញុំនិយាយហ្នឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ដែលលោកនិយាយហ្នឹង គឺត្រឹមត្រូវ គឺខ្ញុំដល់ពេលឆ្នាំដែលខ្ញុំចេញហ្នឹង គឺចេនឡាទី២ វាបាន ខាង លន់ នល់ គេបើកយុទ្ធនាការចេនឡាទី២ហ្នឹង គឺខាងខ្មែរក្រហមក៏ដកខ្លួន ហើយខ្ញុំក៏គេចពីកងទ័ពមកនៅគេហដ្ឋានវិញ។

[០៩:៣៦:២៦]

**ស៖** ពេលនោះ មានន័យថាលោកឈប់ធ្វើកងទ័ពហើយ ហើយពេលណាបានលោកចូលកងទ័ពវិញម្តងទៀត?

**ឆ៖** បាទ ខ្ញុំមិនបានចូលកងទ័ពវិញទេ គឺខ្ញុំចូលទៅខាងសន្តិសុខពង្រ ដូច្នេះគឺអត់មានចូលទ័ពម្តងទៀតទេ។

**ស៖** ចំពោះឯកសារដែលលោកឆ្លើយជម្រាបចៅក្រមស៊ើបអង្កេត ថាលោកទៅសន្តិសុខពង្រ ដោយលោកដើរវង្វេងផ្លូវ ហើយទៅជួបសន្តិសុខហ្នឹងក៏គេហៅចូលធ្វើជាសន្តិសុខពង្រទៅ គេឲ្យធ្វើស្មៀន។ អាហ្នឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ចំពោះលោកនិយាយអម្បាញ់មិញគឺត្រឹមត្រូវ។

**ស៖** ពេលឆ្នាំ១៩៧២ ពេលហ្នឹងលោកអាយុប្រហែលជា ១៦-១៧ឆ្នាំ លោកបានចូលកងទ័ពពេលហ្នឹងលោកសម្រេចចិត្តដោយខ្លួនឯង ឬក៏មានអ្នកណាណែនាំលោក ឬដឹកនាំលោកឲ្យចូលកងទ័ព?

[០៩:៣៨:០៥]

**ឆ៖** បាទ ចំពោះបញ្ហាចូលកងទ័ពនៅឆ្នាំ៧២ ហ្នឹងគឺខ្ញុំអត់មានបំណងចូលជាមួយនឹងខ្មែរក្រហមទេ ដោយពេលនោះ ខ្ញុំបានចាកចេញពីឪពុកម្តាយឆ្នាំ៧០ហ្នឹង ដើម្បីថាមករៀនបន្តនៅក្រុងសៀមរាប

បន្តទៀតប៉ុន្តែអត់បានបន្តទេ។ ខ្ញុំក៏បានមករកថា កុងរបស់ខ្ញុំនៅកោះធំ ដល់ខ្ញុំមកដល់តាំងក្រសាំង គឺថា ធ្វើដំណើរដោយកង់ ដល់តាំងក្រសាំងហ្នឹងគឺ ពួកខ្មែរក្រហមហ្នឹងគេចោទខ្ញុំថាខ្ញុំហ្នឹងជាគិញ ដូច្នេះហើយ វាក៏ចាប់ខ្ញុំទៅនៅឯភ្នំសន្ទុក ហើយវាក៏ឲ្យខ្ញុំហ្នឹងចូលធ្វើការជាមួយវាទៅ។ គឺថាដោយចិត្តស្មោះត្រង់ ថាធ្វើ ហ្នឹងគឺអត់បានធ្វើទេ។ នេះគឺខ្ញុំរាយការណ៍ប្រាប់លោកប៉ុណ្ណឹង។

**ស៖** អរគុណ។ នៅឆ្នាំ១៩៧៤ តាមដែលលោកជម្រាបចៅក្រមស៊ើបអង្កេតថា មានការកាប់សម្លាប់មនុស្សច្រើនណាស់ ដោយគេចោទថា ជាចោរព្រៃ មានទាំងកុមារ និងស្ត្រីជាដើម។ ពេលនោះ លោកគ្រាន់តែឮគេថា ឬលោកបានឃើញគេយកមនុស្សមានទាំងកុមារទាំងស្ត្រីនោះទៅសម្លាប់ច្រើនៗ បែបនេះ?

**ឆ៖** ចំពោះសេចក្តីរាយការណ៍អំពីឆ្នាំ១៩៧៤ គឺខ្ញុំបានឃើញជាក់ស្តែង គឺពួកវាយកអ្នកដែលជាប់ទោសពីរឿងចោរព្រៃហ្នឹង ទាំងប្រពន្ធ ទាំងកូន យកទៅដាក់នៅកន្លែងសន្តិសុខពង្រ ហើយវាធ្វើរូងដាច់ដោយឡែក ពីព្រោះវាចោទថា ជាទោសធ្ងន់។ ដូច្នេះហើយ វាធ្វើកន្លែងឃុំឃាំងអ្នកទោសហ្នឹងនៅក្នុងព្រៃនុ៎ង ដោយឡែកក្រៅ បើអ្នកទោសដែល ដូចជា ខុសសីលធម៌អី អាហ្នឹង គឺវាដាក់ផ្សេង។

[០៩:៤១:០១]

**ស៖** ខ្ញុំចង់បញ្ជាក់ត្រង់សម្តីលោក ថាមានទាំងស្ត្រី និងកុមារ ជាដើម។ អាហ្នឹង អាចខ្មែរក្រហម -- ទ័ពខ្មែរក្រហម ជាអ្នកចោទអីចឹង ថាទាំងអស់គ្នាហ្នឹង សុទ្ធតែជាចោរព្រៃ?

**ឆ៖** បាទ ចំពោះការចោទហ្នឹង គឺទ័ពខ្មែរក្រហមចោទថា ចោរព្រៃ។ ដោយវាមានការប្រាប់មកសន្តិសុខពង្រថា បានទៅរស់នៅក្នុងព្រៃ។ រត់ពីប្រពន្ធកូនទៅនៅក្នុងព្រៃ ហើយលួចមកយកបាយទឹកក្នុងភូមិ។ ហើយទីតាំង គឺនៅក្នុងព្រៃ។ ដូច្នេះហើយ វាក៏ចោទប្រកាន់ថា ជាចោរព្រៃ។ ព្រោះពួកទ័ពខ្មែរក្រហមហ្នឹង ចោទអីចឹង។

**ស៖** ពេលនោះ ពេលដែលខ្មែរក្រហមចោទថា ទាំងស្ត្រី ទាំងកុមារនុ៎ង ជាចោរព្រៃ ពេលនុ៎ងនៅកន្លែងណា? ហើយលោកនៅកន្លែងណា? លោកនៅជាមួយគ្នាគេ ស្ត្រីទាំងប៉ុន្មានហ្នឹង ឬក៏លោកនៅកន្លែងផ្សេងទេ?

**ឆ៖** បាទ ខ្ញុំ កន្លែងខ្ញុំនៅជាមួយនឹងពួកសន្តិសុខនោះឯង ហើយដែលអ្នកជាប់ទោស គឺនៅក្នុងអាកន្លែងឃុំឃាំង មានដាក់ខ្នោះជើង។ នៅ ថាពួកមិត្ត គឺនៅផ្សេង ហើយពួកខាងអ្នកទោស គឺនៅផ្សេងគ្នា។

[០៩:៤៣:០៦]

**ស៖** សំណួរខ្ញុំបន្តទៅទៀត លោកបានជម្រាបទៅចៅក្រមស៊ើបអង្កេតថា "ក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ខ្ញុំឃើញគេជម្លៀសទាហាន និងអតីតរដ្ឋការ លន់ នល់ ពីខេត្តសៀមរាប មកដាក់នៅតាមផ្លូវ -- អ៊ំ មកតាមផ្ទះចាស់ៗ នៅផ្សារជីក្រែង។ ដោយមានយាមកាមទាំងយប់ ទាំងថ្ងៃ ហើយក្រោយមក គេយកអ្នកទាំងនោះ ទៅសម្លាប់។ តែខ្ញុំមិនដឹងថា សម្លាប់នៅទីណា"។ ខ្ញុំសួរថា លោកដឹងថា សម្លាប់នោះ ដោយគេប្រាប់លោក? ឬលោកឮតៗពីមួយ ទៅមួយ?

**ឆ៖** បាទ សំណួរនេះ គឺខ្ញុំបានដឹងច្បាស់ពីពួកដែលនៅសន្តិសុខហ្នឹង គេឲ្យទៅចូលរួមជាមួយនឹងពួកទាហាន ប៉ុន្តែទាហានហ្នឹង មិនដឹងជាទាហានតំបន់ ឬមួយក៏ទាហានស្រុកទេ គឺខ្ញុំមិនដឹងទេ។ ដូច្នេះ ពួកដែលសន្តិសុខពង្រនោះ វាទៅចូលរួមទៅ វាមកក៏និយាយ ក៏ខ្ញុំអាចដឹងថា អ៊ំ! អ្នកដែលជម្លៀសពីសៀមរាបមក គឺត្រូវគេយកទៅសម្លាប់ទាំងកូន ទាំងប្ដី ទាំងប្រពន្ធ។ គឺខ្ញុំដឹងតែប៉ុណ្ណឹង។

[០៩:៤៤:៤៥]

**ស៖** បើអ៊ីចឹង ការចម្លើយរបស់លោកទៅចៅក្រមស៊ើបអង្កេត លោកបានឮគេប្រាប់ អ៊ីចឹងណ៎ះ! ប្រាកដអ៊ីចឹងទេ?

**ឆ៖** បាទ គឺប្រាកដជាអ៊ីចឹងមែន គឺពួកដែលទៅចូលរួមក្នុងការងារ ដែលយកអ្នកមន្ត្រីយោធាហ្នឹងគឺវាមកដល់កន្លែងវិញ វាក៏និយាយប្រាប់។ គឺខ្ញុំបានដឹងប៉ុណ្ណឹង ច្បាស់លាស់។

**ស៖** លោកធ្វើការនៅមន្ទីរសន្តិសុខមានឈ្មោះ តាវ៉ន ជាមេរបស់លោក។ ហើយរួចពីហ្នឹងមក គេចាប់ តាវ៉ន ទៅ ដាក់ តាគុណ ជំនួស។ តើគេចាប់ តាវ៉ន ហ្នឹង លោកបានឃើញគេចាប់ទេ? ពេលដែលគេមកចាប់ តាវ៉ន ហ្នឹង? ឬក៏លោកឮគេថាទេ? ឬមួយទៀត ឬគេគ្រាន់តែផ្លាស់ តាវ៉ន ហ្នឹងចេញពីកន្លែងហ្នឹងដាក់ តាគុណ មក? រឿងហ្នឹងវាខុសគ្នា ខ្ញុំចង់បញ្ជាក់ថា ផ្លាស់ និងចាប់។ តើគេចាប់ តាវ៉ន ហ្នឹងមែន ឬចាប់ដោយរបៀប? បើលោកឃើញ ដឹងអីដាក់ តាគុណ មកជំនួសនោះ?

**ឆ៖** ការចាប់ តាវ៉ន ថាក្បត់ គឺខ្ញុំមិនបានឃើញទេ ប៉ុន្តែគេ ឮតាមគេ គឺមិនមែនថាចាប់ភ្លាមទេ គឺយកគាត់ឲ្យទៅទទួលមុខសញ្ញាទៅអាងទឹក ពីព្រោះគាត់ក៏ជាអ្នកជាងសំណង់ដែរពីដើមមក ដែលគាត់មិនទាន់ធ្វើសន្តិសុខនោះ។ ដូច្នេះ ខ្មែរក្រហមក៏ឲ្យគាត់ទៅធ្វើជាអ្នកសំណង់នៅឯហៅថាទំនប់ស្ទួង ទំនប់ខាងទំនប់ស្ទួង។ ដល់ក្រោយមកបានពួកខ្មែរក្រហមចាប់ទៅ។ ត្រង់កន្លែងហ្នឹងគឺខ្ញុំមិនបានថាឃើញគេចាប់គេអីទេ គឺគ្រាន់តែថា ដឹងពីពួកសន្តិសុខនោះឯង ថាចាប់ពិតប្រាកដមែន។ ដឹងតែប៉ុណ្ណឹង។

[០៩:៤៧:២៦]

**ស៖** អរគុណ។ ត្រង់ឯកសារលេខ D125/127 ERN 00224054, អង់គ្លេស 00225113, ខ្ញុំមិនមានជា ERN ភាសាបារាំងទេ។ លោកឆ្លើយជម្រាបទៅចៅក្រមស៊ើបអង្កេតថា "គេសម្លាប់មនុស្ស ដោយប្រើដំបងវ៉ៃក្បាលអ្នកទោស។ ពេលអ្នកទោសដួល គេយកកាំបិតអារ-កថែមទៀត រួចហើយ រុញសាកសពទម្លាក់ចូលក្នុងរណ្ដៅ។ សម្លាប់រួចរាល់ហើយ គេកប់រណ្ដៅវិញ"។ ខ្ញុំសួរថា តើសកម្មភាពនៃការធ្វើទារុណកម្ម និងសម្លាប់មនុស្សរបៀបនេះ តើលោកបានឃើញផ្ទាល់នឹងភ្នែកទេ?

**ឆ៖** នេះចំពោះការឃើញ គឺខ្ញុំមិនបានឃើញទេ ពីព្រោះខាងខ្ញុំជាអ្នកសរសេរ គឺខ្មែរក្រហមមិនឱ្យទៅជិតកន្លែងនុ៎ងទេ គឺដឹងតាមពួកមិត្តរបស់វា ដែលធ្វើសកម្មភាព គឺវាបានប្រាប់ខ្ញុំឱ្យដឹង អានេះគឺខ្ញុំក៏ដឹងតាមរយៈពួកគ្នាវាហ្នឹង គឺថាកូនចៅវា ដែលទៅៗធ្វើសកម្មភាពហ្នឹង។

**ស៖** មានន័យថា ពេលដែលលោកឮគេប្រាប់ទាំងប៉ុន្មាន ហើយលោកបានយកមកឆ្លើយជម្រាបចៅក្រមស៊ើបអង្កេត។ នេះជារឿងលោកមិនបានឃើញផ្ទាល់នឹងភ្នែក លោកមិនបានធ្វើដោយដៃខ្លួនឯងទេ លោកឮគេថា។ លោកយកមកជម្រាបឆ្លើយប្រាប់ចៅក្រមស៊ើបអង្កេត លោកប្រាកដក្នុងខ្លួនថាគេថាហ្នឹងពិត ឬអត់?

**ឆ៖** ខ្ញុំគិតថា ការថារបស់ពួកខ្មែរក្រហមហ្នឹងពិត ពីព្រោះក្រោយមកគឺផ្នូរសពហ្នឹងគឺមានទៅឃើញជាក់ស្ដែង។ ហើយក្រោយមកទៀត ដល់ក្រោយ៧៩ហ្នឹងគឺប្រជាជនក៏បានទៅគាស់កកាយក៏ឃើញជាឆ្អឹងជាក់ស្ដែងដែរ។ ដូច្នេះ ខ្ញុំគិតឃើញថាពួកខ្មែរក្រហមដែលនិយាយហ្នឹងគឺជាការពិត។

**ស៖** នៅក្នុងឯកសារលេខ D83-Annex-00012, ERN 00812867, អង់គ្លេស 00124158 និងបារាំង 00779387 ដែលលោកបានសម្ភាសជាមួយនឹង ហង់រី ឡូកា។ ឯកសារដែលលោកបានសម្ភាសជាមួយ ហង់រី ឡូកា ត្រង់ឃ្លាមួយ លោកបានឆ្លើយថា "តាវ៉ន វះពោះសាកសពដើម្បីយកប្រម៉ាត់មកហាលថ្ងៃដើម្បីដាក់ក្នុងស្រាទុកផឹក"។ តើរឿងនេះលោកបានផ្ទាល់ភ្នែក ឬក៏លោកឮគេថា?

[០៩:៥២:២៧]

**ឆ៖** ចំពោះលោកនិយាយអម្បាញ់មិញ គឺខ្ញុំឮគេថាតែម្ដង គឺមិនបានឃើញផ្ទាល់ភ្នែកទេ។

**ស៖** អ្នកណាប្រាប់លោកពេលនុ៎ង?

**ឆ៖** អ្នកដែលប្រាប់គឺប្រជាជនម្នាក់ខ្ញុំមិនចាំឈ្មោះទេ នៅភូមិពង្រ គាត់បានឃើញ តាវ៉ន ហ្នឹងឱ្យគាត់រកស្រា ហើយក៏បានឃើញយកប្រម៉ាត់ដែល តាវ៉ន បានហ្នឹងគឺយកទៅដាក់។ ដូច្នេះខ្ញុំក៏ដឹងតាម

ដែលប្រជាជននៅភូមិពង្រ។

**ស៖** សំណួរមួយទៀត នៅឃ្លាបន្ទាប់នៃវគ្គដដែលនុ៎ង នៅឯកសារដដែលហ្នឹង លោកបាន សម្ភាសជាមួយលោក ហង់រី ឡូកា លោកៗនៅក្នុងឯកសារលោកសរសេរឈ្មោះលោកហ្នឹងដាក់ ប៉ េ ជបរ ហ្នឹងមានន័យថាម៉េច ហើយបាន ជីបសៃ ក្រោយ?

**ឆ៖** ចំពោះការសរសេរហ្នឹង ខ្ញុំក៏មិនដឹងជាខាងលោក ហង់រី ឡូកា លោកសរសេរយ៉ាងម៉េច ដែរ គឺខ្ញុំមិនបានសរសេរផ្ទាល់ដៃទេ គឺលោក ហង់រី ឡូកា លោកមានអ្នកបកប្រែពីរនាក់គឺជាអ្នក ហើយ លោកសួរជាភាសាបារាំងមក មានអ្នកបក។ ដូច្នេះការសរសេររបាយការណ៍ហ្នឹង គឺមិនដឹងជាលោក សរសេរពាក្យហ្នឹងមានន័យថាម៉េច គឺខ្ញុំខាងសាក្សីអត់ដឹងទេ។

[០៩:៥៤:៤៦]

**ស៖** លោកមិនយល់អំពីសំណួរចម្លើយដែល ហង់រី ឡូកា សរសេរនេះទេ។ លោកទទួលយក ទេពាក្យហ្នឹង? បើលោកអត់ៗស្គាល់ លោកអត់ដឹង អត់យល់ក្នុងអក្សរហ្នឹងផង ប្រែថាម៉េច? ហើយ លោកទទួលយកទេ មកដល់ថ្ងៃនេះ?

**ឆ៖** ខ្ញុំទទួលយកមិនបានទេ ចំពោះលោក ហង់រី ឡូកា ត្រង់ដែលខ្ញុំបានដឹងពីៗរឿងថា ប្អូនខ្ញុំ ចូលទ័ពអាយុប៉ុន្មានឆ្នាំហ្នឹងពួ គឺអាហ្នឹងគឺខ្ញុំបដិសេធហើយ។ ចំពោះអាឈ្មោះដែលសរសេរដែលលោក និយាយអំមិញ គឺថាខ្ញុំមិនទទួលទេ ដោយមិនដឹងថាលោក ហង់រី ឡូកា លោកចង់សរសេរឈ្មោះខ្ញុំទៅ អ៊ីចុះទៅវិញ គឺខ្ញុំទទួលមិនបាន។

**ស៖** ក្នុងសំណួរចម្លើយរបស់លោកជាមួយនឹងលោក ហង់រី ឡូកា ទាំងអស់ ឬក៏ថាពីរម៉ាត់ ហ្នឹងទេ? មួយម៉ាត់គឺថាត្រង់តែប្អូនលោកចូលយោធាអាយុ៨ឆ្នាំ ហើយមួយពាក្យទៀត ប៉េ ជបរ ហ្នឹង លោកមិនទទួលប៉ុណ្ណឹង ឬក៏លោកមិនទទួលទាំងអស់?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ!

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថា សំណួរបែបនេះគឺមិនត្រឹមត្រូវនោះទេ។ ព្រោះសាក្សីមិន ត្រូវបានសួរដោយអ្នកស៊ើបអង្កេត សហចៅក្រមស៊ើបអង្កេត ឬក៏សក្ខីកម្មណាមួយនៅក្នុងតុលាការ

ដែលអាចឲ្យគាត់អានទៅលើចម្លើយទាំងអស់នេះ ហើយបញ្ជាក់ទៅលើភាពត្រឹមត្រូវ។ ខ្ញុំគិតថាវាគួរ -- យើងគួរតែសួរទៅលើផ្នែកជាក់លាក់ណាមួយ ថាតើត្រឹមត្រូវឬក៏អត់? ប្រសិនបើមេធាវីមានផ្នែកណាមួយនៃកិច្ចសម្ភាសន៍ ដែលគាត់ចង់ឲ្យសាក្សីបញ្ជាក់ថា ត្រឹមត្រូវឬមិនត្រូវ គឺអាចធ្វើទៅបាន ប៉ុន្តែសាក្សីមិនមានឱកាសបានអានទៅលើកិច្ចសម្ភាសន៍ទាំងមូល ទាំងស្រុងតែម្ដង។ ដូច្នេះជាការមិនត្រឹមត្រូវដែលយើងដាក់សំណួរបែបនេះទៅលើសាក្សី។ សូមអរគុណ។

[០៩:៥៧:២៩]

**លោក សុន អរុណ៖**

ខ្ញុំសូមអនុញ្ញាតឆ្លើយទៅព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញាពីម្សិលមិញមួយព្រឹកធំ ហើយមួយល្ងាចទៀត បាននិយាយសួរទៅសាក្សីពីរឿង ហង់រី ឡូកា ហ្នឹង។ តើអាហ្នឹងពេញច្បាប់ ពេញលក្ខណៈដែលលោកត្រូវសួរទេ? បើលោកមិនឲ្យខ្ញុំសួរពីឥឡូវនេះ។

**ប្រធានអង្គជំនុំ៖**

សេចក្ដីជំទាស់ និងសំអាងហេតុនៃសេចក្ដីជំទាស់របស់តំណាងសហព្រះរាជអាជ្ញាមានមូលហេតុត្រឹមត្រូវ។ សាក្សីមិនចាំបាច់ឆ្លើយតបទៅនឹងសំណួររបស់មេធាវី ដែលសួរលោកចុងក្រោយអម្បាញ់មិញទេ។ លោកមេធាវីគប្បីពិនិត្យឡើងវិញអំពីហេតុផលនៃការអនុញ្ញាតរបស់អង្គជំនុំជម្រះឲ្យសួរ គឺដកស្រង់នូវខ្លឹមសារសារធាតុ ដែលជាពាក្យពេចន៍របស់សាក្សីបានផ្ដល់បទសម្ភាសន៍ជាមួយនឹងលោក ហង់រី ឡូកា។ ប៉ុន្តែមិនមែនជាពាក្យពេចន៍នាម ឬក៏សរសេរអក្ខរាវិរុទ្ធខុស នៅក្នុងកំណត់ហេតុដកស្រង់របស់លោក ហង់រី ឡូកា ជាកំហុសរបស់សាក្សី ហើយសាក្សីទៅទទួលខុសត្រូវលើបញ្ហានុំងនោះឡើយ។ ក្រែងលោកមានការភ័ន្តច្រឡំ។

ខ្លឹមសារគឺលោកអាចដកស្រង់បានដូចគ្នា ឲ្យតែជាសម្ដីដែលលោក ឡូកា បានដកស្រង់នូវបទសម្ដីដែលសាក្សីរូបនេះបានធ្វើសម្ភាសជាមួយគាត់ កាលពីឆ្នាំ១៩៩១។

[០៩:៥៩:០៧]

**លោក សុន អរុណ៖**

សូមអរគុណលោកប្រធានមានការណែនាំ។

**សួរដោយលោក សុន អរុណ៖**

**ស៖** ឃ្លាបន្ទាប់មកទៀត ខ្ញុំសួរបន្ត ដែលៗលោកបានសម្ភាសជាមួយលោក ហង់រី ឡូកា លោក

ឈ្មោះ ប៉េ ជបរ ជីបស៊ែ សារភាពថាបានសម្លាប់អ្នកទោសចំនួនពីរនាក់ ហើយវ៉ៃអ្នកទោសក្នុងពេលសួរចម្លើយ។ ចម្លើយរបស់លោកនេះត្រឹមត្រូវទេ? លោកទទួលយកបានទេ ឬក៏យ៉ាងម៉េច?

**លោក ប៉េជុយ ជីបស៊ែ៖**

**ឆ៖** ចម្លើយចំពោះលោក ហង់រី ឡូកា ហ្នឹង គឺខ្ញុំមិនទទួលយកបានទេ ប៉ុន្តែខ្ញុំគ្រាន់តែថា ចំពោះអ្នកទោស គឺខ្ញុំបានវាយមែន។ ប៉ុន្តែត្រង់ថាសម្លាប់អ្នកទោសហ្នឹង គឺខ្ញុំមិនបានអនុវត្តទេ ដោយខ្មែរក្រហមវាមិនទុកចិត្តខ្ញុំ។ ដូច្នេះគឺខ្ញុំមិនអាចយកបានទេចំពោះសម្ដីនេះ។

**ស៖** លោក អំមិញឆ្លើយថា លោកបានវាយមែន ប៉ុន្តែលោកមិនបានសម្លាប់ទេ។ លោកបានវាយអ្នកទោសច្រើនទេ ហើយឬក៏ម្នាក់ ឬពីរនាក់ទេ?

**ឆ៖** បាទ ខ្ញុំបានវាយអ្នកទោសហ្នឹងតែពេលសួរចម្លើយទេ ត្រង់តែថាយកទៅវាយដូចថានឹងដំបងហ្នឹង គឺអត់មានទេ គឺចំនួនដែលខ្ញុំបានវាយហ្នឹង គឺខ្ញុំមិនបានចាំទេមកដល់ពេលនេះ គឺភ្លេចអស់ហើយ។

[១០:០១:២៧]

**ស៖** នៅក្នុងសំណួរ-ចម្លើយជាមួយនឹងសហចៅក្រមស៊ើបអង្កេតលេខ D125/127 ERN 00224054, អង់គ្លេស 00225313។ លោកបានឆ្លើយជម្រាបព្រះរាជអាជ្ញាពីម្សិលមិញថា "លោកបានឃើញការសម្លាប់ផ្ទាល់តែម្ដងទេ"។ ពេលលោក ពេលដែលលោកឃើញម្ដងនោះ ខ្ញុំសួរថាតើលោកឃើញសភាពការណ៍នៃការសម្លាប់នឹងយ៉ាងម៉េច? ឧទាហរណ៍ថា គេធ្វើសម្លាប់ -- មុននឹងសម្លាប់ធ្វើយ៉ាងម៉េច? ដល់ពេលសម្លាប់ធ្វើយ៉ាងម៉េច? ហើយសម្លាប់ហ្នឹងដោយអ្វី ហើយនៅទីកន្លែងណា?

**ឆ៖** ចំពោះការសម្លាប់របស់ពួកខ្មែរក្រហមជំនាន់នោះគឺថា មុននឹងសម្លាប់វាយកដឹកមនុស្សទៅហើយរណ្ដៅដែលវាជីកនោះ គឺវាជីករួចហើយ។ ហើយវាមិនប៉ានសម្លាប់នៅជិតកន្លែងឃុំឃាំងទេ ខ្លាចអ្នកទោសហ្នឹងឮសូរដូច្នេះ។ វាចម្ងាយបើខ្ញុំប៉ាន់ទៅប្រហែលជា១គីឡូពីកន្លែងឃុំឃាំងហើយ។ ហើយនៅកន្លែងធ្វើឃាតហ្នឹង វាមានដំបងទុក ហើយអ្នកទោសពេលយកទៅសម្លាប់ត្រូវចង ហើយយកក្រណាត់ខ្មៅរុំមុខទៅ។ ពេលទៅដល់ណោះ វាឲ្យអង្គុយចុះ ហើយក៏ពួកវាវាយនឹងដំបង ដល់ពេលអ្នកទោសស្លាប់ទៅ វាក៏យកកាំបិតអារ-ក ហើយក៏រុញសាកសពទម្លាក់ទៅក្នុងអន្លង់បានគ្រប់ហើយបានវាកប់រណ្ដៅ។

[១០:០៣:៤៣]

**ស៖** គេសម្លាប់អ្នកទោសហ្នឹងនៅពេលណា ពេលយប់ ឬពេលថ្ងៃ?

**ឆ៖** គឺតាមសម្ដីដែលពួកដែដល់ដូចជាគ្នារបស់ខ្មែរក្រហម គឺច្រើនតែសម្លាប់នៅពេលថ្ងៃ គឺពេលថ្ងៃ គឺពេលថ្ងៃ។

**ស៖** លោក ពេលដែលគេនាំអ្នកទោសទៅសម្លាប់ លោកបានទៅមើលផ្ទាល់ភ្នែក ឬលោកឮគេថា?

**ឆ៖** គឺខ្ញុំច្រើនតែឮតាមសម្ដីរបស់អ្នកដែលវាឲ្យនាំអ្នកទោសទៅ ដូចជាពួក គេហៅថា ខ្មែរក្រហមហៅថា ពួកសម្ព័ន្ធយុវកក អង្គការសម្ងាត់របស់វា ដែលជាអ្នកដែដល់ហ្នឹង គឺពេលដែលវាធ្វើការរួច គឺវាតែងតែមកប្រាប់ខ្ញុំឲ្យដឹងពីរឿងអ្នកទោសដែលត្រូវសម្លាប់។

[១០:០៥:០៥]

**ស៖** គ្រប់ការសម្លាប់អ្នកទោសយកចេញពីមន្ទីរសន្តិសុខពង្រហ្នឹង ត្រឡប់ គេត្រឡប់ អ្នកសម្លាប់ត្រឡប់មកវិញហើយប្រាប់លោករាល់ពេល ឬក៏ថាម្ដងម្កាលដែលលោកបានឮ?

**ឆ៖** វាមិនបានប្រាប់ខ្ញុំរាល់ពេលទេ គឺថាវាដោយពេលខ្លះដែលវាពេលវានិយាយជាមួយគ្នាវាទៅក៏ខ្ញុំក៏អង្គុយជិតនុ៎ងក៏បានឮសូរវានិយាយទៅក៏ខ្ញុំអាចដឹងច្បាស់ថាវាធ្វើអីខ្លះ គឺខ្ញុំដឹងតាមរយៈតែវានិយាយគ្នាវា ឬមួយក៏ គឺខ្ញុំមិនបានទៅសាកសួរទេ ពីព្រោះការងារ គឺជាការងារសម្ងាត់របស់ពួកវា។

**ស៖** អរគុណ។ សំណួរចុងក្រោយរបស់ខ្ញុំ លោកបានធ្វើស្មៀន ឬក៏ធ្វើលេខានៅមន្ទីរសន្តិសុខពង្របានរយៈពេលប៉ុន្មាន? ហើយរួចពីហ្នឹងទៅលោកនឹងធ្វើអ្វីទៀត?

[១០:០៦:៣៤]

**ឆ៖** បាទ ខ្ញុំបានធ្វើកន្លែងសន្តិសពង្រនោះ គឺចាប់ពីឆ្នាំ១៩៧៣ រហូតដល់ឆ្នាំ១៩៧៧ ខ្មែរក្រហមក៏ចោទថា ក្បត់ហើយក៏ចាប់មេៗយកទៅ ខ្ញុំខាងជាស្មៀន ជាអីក៏ត្រូវគេរំសាយឲ្យមកនៅតាមសហករណ៍ភូមិឃុំវិញ។ ហើយខ្ញុំមិនបានធ្វើការងារអ្វីទេ គឺក្រោយពីឆ្នាំ៧៧ គឺជាកងចល័តនៅក្នុងភូមិ។

**ស៖** លោកបាននៅក្នុងក្របខ័ណ្ឌខ្មែរក្រហមតាំងពីធ្វើឃោធាររហូតមកដល់ធ្វើសន្តិសុខ រហូតដល់ពេលណាបានលោកឈប់?

**ឆ៖** ខ្ញុំបានឈប់នៅឆ្នាំ១៩៧៧ គឺខ្ញុំឈប់មាននាទីជាអ្វីទៀតហើយ គឺខ្ញុំជាប្រជាជននៅក្នុងសហករណ៍ គឺនៅក្រោមការគ្រប់គ្រងរបស់សហករណ៍ខ្មែរក្រហម គឺអត់មាននាទីអ្វីទៀតទេ គឺអស់ហើយ អស់ត្រឹមឆ្នាំ១៩៧៧។

[១០:០៨:០៨]

**ស៖** ពេលនុំងលោកនៅស្រុកណា? នៅស្រុកផ្ទាល់ខ្លួន ឬក៏លោកជម្លៀសទៅនៅកន្លែងណាផ្សេង?

**ឆ៖** ពេលខ្ញុំចេញពីខ្មែរក្រហមឆ្នាំ៧៧ មកគឺខ្ញុំមកនៅភូមិរបស់ខ្ញុំផ្ទាល់គឺភូមិតាព័រលើ ឃុំពង្រក្រោម ស្រុកជីក្រែង ខេត្តសៀមរាប។ មកនៅស្រុករបស់ខ្ញុំវិញ។

**ស៖** លោកបានធ្វើការនៅក្នុងក្របខ័ណ្ឌបក្សរបស់កុម្មុយនីស្តកម្ពុជាប្រជាធិបតេយ្យតាំងពីឆ្នាំ៧០ -- ១៩៧២ ដល់៧៧ មានន័យថា ៥ឆ្នាំ។ តាំងពីសំណួររបស់ព្រះរាជអាជ្ញារហូតមកដល់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី លោកច្រើនតែឆ្លើយទៅវិញថា ពួកវា ៗហ្នឹងអ្នកណាពួកវាសូមលោកបញ្ជាក់បន្តិចមើល?

**ឆ៖** បាទ ខ្ញុំពាក្យថា "ពួកវា" ហ្នឹងខ្ញុំគឺ ខ្មែរក្រហមតែម្តង។ ពាក្យថា "ពួកវា" គឺខ្មែរក្រហម។ ហ្នឹងខ្ញុំនិយាយពួកវា គឺមានន័យថា ខ្មែរក្រហម។

**លោក សុន អរុណ៖**

សូមអរគុណ។ លោកប្រធាន ខ្ញុំអស់សំណួរ ខ្ញុំជូនទៅសហភាគីរបស់ខ្ញុំ។ ខ្ញុំអស់ណាស់លោកសាក្សី។

[១០:០៩:៥៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញ!

**លោក ហ្សាស្តេ ប៉ៅ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ហ្សាស្តេ ប៉ៅ៖**

**ស៖** សួស្តី លោក ជីបសែ ខ្ញុំឈ្មោះ ហ្សាស្តី ប៉ៅ ជាមេធាវីអន្តរជាតិលោក នួន ជា។ ខ្ញុំមានសំណួរបន្ថែមមួយចំនួនចង់សួរលោក ពាក់ព័ន្ធទៅនឹងចំណុចមួយចំនួនដែលលោកបានឆ្លើយរួចមកហើយក្នុងរយៈ២ថ្ងៃនេះ។ ខ្ញុំនឹងនិយាយឲ្យបានយឺតៗ ដើម្បីកុំឲ្យមានការយល់ច្រឡំគ្នា។ ហើយសំណួរណាដែលលោកមិនយល់ច្បាស់នោះ សូមឲ្យសួរមកឲ្យខ្ញុំវិញ ឲ្យខ្ញុំបញ្ជាក់បំភ្លឺជូនលោក។ សំណួរទី១របស់ខ្ញុំពាក់ព័ន្ធទៅនឹងស្ថានភាពនៅផ្សារជីក្រែង។ យោងតាមចម្លើយរបស់លោក "ទាហាន លន់ នល់ ត្រូវបាន

គេឃុំនៅក្នុងផ្ទះល្វែងចាស់"។ នៅព្រឹកមិញនេះ យើងក៏បានស្តាប់ឮឃើញថា ជីក្រែងនោះ ផ្សារជីក្រែងបច្ចុប្បន្ន គឺជាផ្សារកំពង់ក្តីនេះឯង។ សំណួរដែលខ្ញុំចង់សួរលោក គឺមានដូចតទៅ៖ លោកបានឆ្លើយថា "ទាំងទាហាន លន់ នល់ ទាំងរដ្ឋ -- មន្ត្រីរដ្ឋការ លន់ នល់ ត្រូវបានដឹកចេញពីផ្សារជីក្រែងយកទៅសម្លាប់ចោល"។ ខ្ញុំចង់សូមសួរលោកដូចតទៅ៖ តើលោកដឹងថា ពួកគេទាំងអស់នោះ ជាទាហាន លន់ នល់ និងជាមន្ត្រីរដ្ឋការ លន់ នល់ នោះ ដោយរបៀបណា? នរណាប្រាប់លោកដែរ?

[១០:១២:០៣]

**លោក ប៉េជុយ ជីបសែ៖**

**ឆ៖** បាទ លោកសួរថាតើការជម្លៀសមកនៅផ្សារកំពង់ក្តីហ្នឹង ជានរណា -- គឺជាមេទាហានដែលខ្មែរក្រហម វាជម្លៀសមក ហើយខ្ញុំដឹងតាមរយៈ គឺតាមរយៈពួកខ្មែរក្រហមដែលបានធ្វើសន្តិសុខពង្រហ្នឹង គឺគេជាអ្នកនិយាយប្រាប់ខ្ញុំ។ ហើយនិងប្រជាជនដែលតែងតែនិយាយទៅ គឺខ្ញុំអាចដឹងតាមរយៈហ្នឹង គឺថាដល់ខ្ញុំឃើញជាក់ស្តែងហ្នឹង គឺថាខ្ញុំមិនបានឃើញទេ គឺថាមានទាហាន លន់ នល់ មកគេដឹកមកដាក់នៅផ្សារកំពង់ក្តីហើយ ហើយថ្ងៃដែលយកទៅធ្វើឃាតអី គឺពួកខ្មែរក្រហមហ្នឹង គឺគេនិយាយប្រាប់ខ្ញុំ បានខ្ញុំដឹងតាមរយៈហ្នឹង។

**ស៖** ដូច្នេះ ទាហានខ្មែរក្រហមធ្វើការនៅមន្ទីរសន្តិសុខពង្រនោះ ជាអ្នកប្រាប់លោកថា "អ្នកទាំងអស់នោះ គឺជាទាហាន លន់ នល់ និងមន្ត្រីរដ្ឋការ លន់ នល់ ដែលត្រូវបានគេឃុំខ្លួននៅផ្សារជីក្រែងនោះ"។ តើការសង្ខេបចម្លើយរបស់លោកអ៊ីចឹង គឺត្រឹមត្រូវទេ តាមដែលលោកឆ្លើយអ៊ីចឹងហ្នឹង?

[១០:១៣:៤៥]

**ឆ៖** បាទ ចំពោះចម្លើយដែលខ្ញុំឆ្លើយអម្បាញ់មិញ គឺជាការត្រឹមត្រូវ។

**ស៖** ដើម្បីកុំឱ្យយើងយល់ច្រឡំនឹងគ្នា លោកក៏និយាយអំពីប្រាប់អំពីការឃុំខ្លួន ហ្នឹងក៏មានការឃុំខ្លួនអ្នកភូមិផងដែរ។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** សូមលោកសួរជាសំណួរម្តងទៀត ថាឃុំខ្លួនប្រជាជននោះ ឃុំនៅកន្លែងណា? សូមលោកបញ្ជាក់ម្តងទៀត ខ្ញុំស្តាប់មិនច្បាស់។

**ស៖** សូមអធ្យាស្រ័យ ខ្ញុំនឹងសួរឱ្យបានជាក់លាក់។ តើអ្នកភូមិគេមានប្រាប់លោកថា "នៅផ្សារជីក្រែងនោះ គឺគេឃុំទាហាន លន់ នល់ និងឃុំមន្ត្រីរដ្ឋការ លន់ នល់"។ តើអ្នកភូមិបានប្រាប់លោកអ៊ីចឹងដែរឬទេ?

[១០:១៤:៥៦]

**ឆ៖** សំណួរនេះ គឺថាអ្នកភូមិក៏បានប្រាប់ខ្ញុំ ហើយពួកដែលបានទៅនាំពួកទាហានយកទៅក៏ពួកសន្តិសុខពង្រហ្នឹង ក៏បានប្រាប់ខ្ញុំ បាទ។ គឺខ្ញុំដឹងទាំងពីរផ្នែកតែម្តង។

**ស៖** តើលោកនៅចាំទេ តើមានទាហានខ្មែរក្រហមប៉ុន្មាននាក់ដែរ ដែលធ្វើការនៅមន្ទីរសន្តិសុខពង្រនោះ បានប្រាប់លោកថា ទាហានលន់ នល់ និងមន្ត្រីរដ្ឋការលន់ នល់ នោះគឺត្រូវបានគេឃុំខ្លួននៅផ្សារជីក្រែង ហើយក្រោយមកទាហានលន់ នល់នោះគឺ -- ពួកទាហានទាំងអស់នោះត្រូវបានគេសម្លាប់ចោល? តើអ្នកធ្វើការជាទាហានខ្មែរក្រហមនៅទីនោះប៉ុន្មាននាក់ដែរ?

**ឆ៖** ចំពោះចំនួន គឺខ្ញុំមិនចាំច្បាស់លាស់ទេ។ លោកចង់សួរថា ដែលពួកធ្វើការនៅសន្តិសុខពង្រប៉ុន្មាននាក់ ឬមួយក៏សួរដូចម្តេច សូមម្តងទៀត។ សូមលោកសួរម្តងទៀត?

**ស៖** ជាការពិតណាស់ ខ្ញុំសូមឲ្យលោកជម្រាបអង្គជំនុំជម្រះសាលាដំបូង ប្រសិនបើលោកចាំនោះ តើមានទាហានខ្មែរក្រហមប៉ុន្មាននាក់ ដែលជាអ្នកប្រាប់លោកថា ទាហានលន់ នល់ និងមន្ត្រីរដ្ឋការលន់ នល់នោះ ត្រូវបានគេឃុំនៅផ្សារជីក្រែង? ប្រសិនបើលោកមិនចាំទេ ថាតើគិតមើល នឹកឃើញមើល ថាតើម្នាក់ ពីរបីនាក់ ឬក៏ច្រើនជាងនេះ ដែលបានប្រាប់លោកអំពីករណីហ្នឹង?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំមិនដឹងថាតើមេធាវីបានបង្ហាញសួរសំណួរហ្នឹង ឡើងវិញយ៉ាងម៉េចនោះទេ គឺថាសាក្សីមិនបានប្រាប់ថា ទាហានខ្មែរក្រហមនោះជាអ្នកប្រាប់នោះទេ គឺគ្រាន់តែបែងចែកថា អ្នកដែលជាប់ឃុំនៅទីនោះ គឺជាទាហានខ្មែរ -- ទាហានលន់ នល់ និងមន្ត្រីរដ្ឋការលន់ នល់។ ដូច្នេះ សូមឲ្យមេធាវីនោះសួរសំណួរឡើងវិញ។

[១០:១៧:៣៧]

**លោក ហ្សាស្តេី ប៉ៅ៖**

ខ្ញុំនឹងសួរសំណួរឡើងវិញ កុំឲ្យយើងយល់ច្រឡំ។

**សួរដោយលោក ហ្សាស្តេី ប៉ៅ៖**

**ស៖** លោកសាក្សី គេប្រាប់លោក អ្នកដែលធ្វើការនៅមន្ទីរសន្តិសុខនោះ សន្តិសុខពង្រនោះបាន

ប្រាប់លោកថា មានការឃុំខ្លួនទាហានលន់ នល់ និងមន្ត្រីរដ្ឋការលន់ នល់ នៅផ្សារជីក្រែង។ តើលោកចាំដែរឬទេ? តើអ្នកអ្នកដែលប្រាប់លោកហ្នឹង ធ្វើការនៅមន្ទីរសន្តិសុខពង្រ អ្នកដែលប្រាប់លោកហ្នឹងតើមានប៉ុន្មាននាក់ដែរ ដែលថាមានការឃុំខ្លួនទាហានលន់ នល់ និងមន្ត្រីរដ្ឋការលន់ នល់នោះ?

[១០:១៨:១៥]

**លោក ប៉េជុយ ជីបសែះ**

**ឆ៖** បាទ ចំពោះអ្នកដែលប្រាប់ខ្ញុំ ដែលអ្នកទៅនៅនឹងសន្តិសុខពង្រជាមួយខ្ញុំហ្នឹងប្រហែលជាបីនាក់។ ព្រោះខ្ញុំ -- ប្រហែលបីនាក់ចុះ គឺថាដែលបានមកប្រាប់ខ្ញុំពីរឿងបានទៅជាមួយនឹងកងទ័ពខ្មែរក្រហម។

**ស៖** តើលោកនៅនៅចាំឈ្មោះពួកគាត់ទាំងបី ដែលធ្វើការនៅមន្ទីរសន្តិសុខពង្រ ដែលបានប្រាប់លោកអំពីហេតុការណ៍នេះដែរឬទេ? ចាំឈ្មោះអ្នកទាំងបីនោះដែរឬទេ?

**ឆ៖** មកដល់ពេលនេះ គឺខ្ញុំមិនចាំឈ្មោះអ្នកទាំងបីនោះទេ ដោយវារយៈពេលយូរហើយ គឺខ្ញុំមិនអាចចាំបាន។

**ស៖** លោកក៏បានឆ្លើយថា "អ្នកភូមិនោះ ៗក៏បានប្រាប់លោកថា មានការឃុំខ្លួនទាហានលន់ នល់ និងមន្ត្រីរដ្ឋការលន់ នល់ នៅផ្សារជីក្រែងផងដែរ"។ តើលោកអាចជម្រាបជូនយើងខ្ញុំដែរឬទេ អ្នកភូមិដែលប្រាប់លោកនោះ តើមានប៉ុន្មាននាក់ដែរ ដែលបានប្រាប់លោកអំពីការឃុំខ្លួននេះ? តើមានអ្នកភូមិប៉ុន្មាននាក់ដែរដែលប្រាប់លោក?

**ឆ៖** ចំពោះអ្នកភូមិដែលបានប្រាប់អំពីដំណឹងរឿងយកទាហានលន់ នល់ ទៅទំនប់ម្កាក់ហ្នឹង គឺមកដល់ពេលនេះ ក៏ខ្ញុំមិនបានចាំថាប៉ុន្មាននាក់ទៀត ដោយសារខ្ញុំមានការភ្លេចភ្លាំងច្រើន។

**ស៖** តើលោកអាចប្រាប់ចំនួនស្មានដែរឬទេ? តើអ្នកភូមិម្នាក់ ពីរ ឬក៏ច្រើនជាងហ្នឹង?

**ឆ៖** បាទ ខ្ញុំបើប្រាប់ចំនួនស្មាន គឺខ្ញុំប្រាប់បាន មិនមែនម្នាក់ទេ គឺច្រើននាក់ ប៉ុន្តែចំនួនពិតមិនដឹង។

[១០:២០:៥១]

**ស៖** ខ្ញុំហាក់ដូចជាស្តាប់ច្រឡំតាមកាសរបស់ខ្ញុំ តើលោកនិយាយថាច្រើនជាងពីរនាក់ ឬក៏លោកឆ្លើយយ៉ាងម៉េចដែរ សូមឲ្យលោកកែខ្ញុំប្រសិនបើខ្ញុំស្តាប់ឮច្រឡំដូច្នេះ?

**ឆ៖** បាទ លោកខ្ញុំប្រាប់ថា ប្រជាជនដែលប្រាប់ខ្ញុំហ្នឹងវាច្រើននាក់ ប៉ុន្តែចំនួនថាពីរ ឬមួយក៏បី

ហ្នឹង គឺមិន -- ខ្ញុំភ្លេច អាហ្នឹងគឺចំនួនពិតគឺខ្ញុំប្រាប់វាមិនកើត ព្រោះភ្លេច ប៉ុន្តែចំនួនអ្នកប្រាប់ពីរឿងហ្នឹងគឺច្រើន។

**ស៖** តើជាការសង្ខេបចម្លើយរបស់លោកត្រឹមត្រូវដែរឬទេ ដែលខ្ញុំអាចនិយាយថា "បុគ្គលិកបីនាក់នៅមន្ទីរសន្តិសុខពង្រ រួមទាំងអ្នកភូមិទាំងឡាយនោះបានប្រាប់លោកថា អតីតទាហាន លន់ នល់ និងមន្ត្រីរដ្ឋការ លន់ នល់ ត្រូវបានគេឃុំខ្លួននៅផ្សារដីក្រែង ហើយក្រោយមកអ្នកទាំងអស់នោះត្រូវបានគេសម្លាប់ចោល"។ តើការសង្ខេបចម្លើយរបស់លោកអ៊ីចឹងត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ការសង្ខេបចម្លើយរបស់ខ្ញុំ គឺត្រឹមត្រូវ។

[១០:២២:២៤]

**ស៖** លោកក៏បានឆ្លើយប្រាប់ -- លោកក៏ប្រាប់អំពីឡានដែលគេប្រើប្រាស់ដឹក -- សម្រាប់ដឹកទាហាន លន់ នល់ រួមទាំងមន្ត្រីរដ្ឋការ លន់ នល់ ហើយលោកក៏បានបញ្ជាក់ថា លោកមិនបានឃើញឡានទាំងអស់នោះដោយផ្ទាល់ភ្នែកនោះទេ។ តើលោកអាចជម្រាបជូនយើងខ្ញុំបានដែរឬទេ នរណាជាអ្នកប្រាប់លោកថា ទាហាន លន់ នល់ និងមន្ត្រីរដ្ឋការទាំងអស់នោះត្រូវបានគេដឹកតាមឡាន?

**ឆ៖** ចំពោះការដឹកទាហាន គឺអ្នកស្រុកគឺជាអ្នកប្រាប់ខ្ញុំថា មានដឹកទាហានយកទៅទំនប់ម្កាក់ ហើយក៏បានធ្វើឃាតទាំងអស់នោះទៅ។ នេះគឺសម្ដីរបស់អ្នកស្រុកផ្ទាល់ដែលប្រាប់ខ្ញុំ។

**ស៖** តើលោកចាំទេ តើមានអ្នកភូមិប៉ុន្មាននាក់ដែរ ដែលប្រាប់លោកអំពីឡានដែលគេមកដឹកទាហាន លន់ នល់ និងមន្ត្រីរដ្ឋការ លន់ នល់ ទាំងអស់នេះ? តើមានអ្នកភូមិប៉ុន្មានដែរ ដែលប្រាប់លោកអំពីហេតុការណ៍នេះ?

**ឆ៖** ចំពោះសំណួរនេះ ខ្ញុំមិនអាចចាំបានទេ គឺសូមថាចំនួនពិតប្រាកដប៉ុន្មាននាក់ គឺខ្ញុំមិនចាំតែម្ដង គឺថាមានការភ្លេចហើយ។ ចំនួនដែលប្រាប់ខ្ញុំ គឺខ្ញុំអត់ចាំតែម្ដង។

[១០:២៤:២២]

**ស៖** តើលោកនៅចាំឈ្មោះទេ? ឈ្មោះអ្នកភូមិដែលបានប្រាប់លោកអំពីហេតុការណ៍ហ្នឹងនោះ ដែលថាបានប្រាប់លោកអំពីហេតុការណ៍ ដែលគេយកឡានយកមកដឹកអ្នកទាំងអស់នេះចេញទៅ តើលោកនៅចាំទេឈ្មោះអ្នកទាំងអស់នោះនុ៎ង អ្នកភូមិដែលប្រាប់លោកហ្នឹង?

**ឆ៖** អ៊ូ ប្រសិនជាឈ្មោះទៀត គឺខ្ញុំរឹតតែមិនចាំទៅទៀតហើយ។ នេះគឺសូមថាមិនឆ្លើយ មិនចាំតែម្ដង។

**ស៖** នៅពេលដែលលោកនិយាយអំពីអ្នកភូមិ តើលោកនិយាយអំពីអ្នកភូមិណាដែរ? លោកនិយាយអំពីអ្នកភូមិរស់នៅក្នុងភូមិមួយជាក់លាក់ ឬក៏អ្នកភូមិរស់នៅក្នុងភូមិនានា រួមគ្នាតែម្តង? តើនិយាយសំដៅលើអ្នកភូមិណាដែរលោក?

**ឆ៖** បាទ ខ្ញុំនិយាយសំដៅលើអ្នកភូមិពង្រ ឃុំពង្រក្រោម ស្រុកជីក្រែង។ នេះគឺថាដែលបានប្រាប់ខ្ញុំ គឺអ្នកភូមិពង្រ ឃុំពង្រក្រោម ស្រុកជីក្រែង។ សំដៅតែភូមិមួយ។

**ស៖** តើគឺជាភូមិដែលលោករស់នៅក្នុងខណៈពេល ដែលលោកធ្វើការងារនៅមន្ទីរសន្តិសុខពង្រនោះ មែនដែរឬទេ?

**ឆ៖** បាទ មិនមែនភូមិដែលខ្ញុំរស់នៅទេ គឺភូមិនៅជិតមន្ទីរសន្តិសុខ។ មិនមែនជិតទេ នៅចម្ងាយប្រហែល៣គីឡូ គឺភូមិរបស់ខ្ញុំរស់នៅ គឺភូមិតាព័រលើ ឃុំពង្រក្រោម ស្រុកជីក្រែង ខេត្តសៀមរាប។ ឯភូមិអ្នកដែលប្រាប់ខ្ញុំ គឺភូមិពង្រ ឃុំពង្រក្រោមដូចគ្នា ប៉ុន្តែស្រុកជីក្រែងដែរ។

[១០:២៧:០០]

**ស៖** តើពីភូមិដែលលោករស់នៅ និងពីភូមិដែលលោករស់នៅ ទៅភូមិអ្នកដែលប្រាប់លោកនោះ គឺចម្ងាយពីគ្នាប៉ុន្មានដែរ?

**ឆ៖** ចំពោះសំណួរនេះ គឺខ្ញុំឆ្លើយមិនច្បាស់ទេ ប៉ុន្តែបើប្រហែល ខ្ញុំគិតថាពីភូមិដែលខ្ញុំរស់នៅ និងភូមិពង្រ ប្រហែល៥គីឡូម៉ែត្រ។ នេះការប្រហែល។

**ស៖** លោកបានឆ្លើយថា ខ្ញុំសូមសួរលោកទៅលើប្រធានបទមួយផ្សេងវិញ សូមឲ្យលោកបញ្ជាក់បំភ្លឺ។ លោកបានឆ្លើយថា មន្ទីរសន្តិសុខនេះត្រូវបានបិទទ្វារឈប់ដំណើរការនៅក្នុងឆ្នាំ១៩៧៧ តើលោកដឹងមូលហេតុទេ ហេតុអ្វីគេបិទទ្វារឈប់ដំណើរការមន្ទីរសន្តិសុខនេះ?

**ឆ៖** បាទ ខ្ញុំដឹងមូលហេតុ គឺការបិទមន្ទីរសន្តិសុខពង្រហ្នឹង ដោយវាចោទថាពួកដែលធ្វើការនៅៗមន្ទីរសន្តិសុខហ្នឹង គឺជាពួកក្បត់ ដោយខ្មែរក្រហមគេចោទថា ជាក្បត់។ ហើយក្បត់ហ្នឹង មិនមែនថាតែពួកសន្តិសុខពង្រទេ គឺថាក្បត់ទូទាំងប្រទេសតែម្តង គឺថាដូច្នេះពីជំនាន់មួយទៅជំនាន់មួយ គឺខ្មែរក្រហមចោទគ្នាថាក្បត់មិនចេះចប់។ ដូច្នេះជំនាន់ តាវ៉ន នោះក៏ថាក្បត់ ចាប់ តាវ៉ន ទៅ។ ហើយដល់ជំនាន់តាគុណ នេះ ថា តាគុណ ហ្នឹងក្បត់ទៀត ចាប់មេដឹកនាំយកទៅ។ ដូច្នេះហើយ មូលហេតុ ខ្ញុំថាមកពីវាចោទថាកន្លែងសន្តិសុខពង្រហ្នឹងជាពួកក្បត់។ ខ្មែរក្រហមចោទ។

[១០:២៩:២៥]

**ស៖** នៅពេលដែលលោកនិយាយអំពីក្បត់នេះ តើគេចោទថាក្បត់អំពីអ្វីដែរ? ធ្វើខុសអ្វីដែរ? តើគេចោទយ៉ាងម៉េចដែរ ការក្បត់នេះ?

**ឆ៖** ចំពោះការចោទហ្នឹង គឺខ្ញុំមិនដឹងថាយ៉ាងដូចម្ដេចទេ ពីព្រោះខ្ញុំជាកូនចៅគេ គឺដឹងតែត្រឹមពាក្យថា "ប៉ុណ្ណឹង គេឲ្យដឹងតែប៉ុណ្ណឹង ថាក្បត់"។ ហើយឲ្យសរសេរឈ្មោះដែលអ្នកនៅ ធ្វើការនៅសន្តិសុខពង្រទាំងអស់ជូនទៅថ្នាក់លើ។ ដូច្នេះហើយក៏សរសេរឲ្យគេរួចទៅ ក៏រំសាយអ្នកទោស និងអ្នកធ្វើការទាំងអស់ចេញភ្លាមមួយរំពេច។

**ស៖** សាក្សីដដែទៀតបានបញ្ជាក់អំពីរយៈពេលមួយនេះដែរ ហើយសាក្សីផ្សេងទៀតគឺគាត់បានផ្ដល់សក្ខីកម្មថា តាសុខ និងតាសំ ចាប់ខ្លួន តាវ៉ន, តាគុណ ហើយតានាគ ហើយសាក្សីដទៃទៀតនោះគាត់បានបញ្ជាក់ថា តាសុខ ហើយនិង តាសំ ជំរុញឲ្យប្រជាជននោះ តាមដាន ហើយនិងសម្លាប់អាជ្ញាធរនៅក្នុងភូមិ ហើយនិងនៅក្នុងឃុំដែលធ្វើឲ្យប្រជាជនគាត់អត់ឃ្លាន។ សំណួររបស់ខ្ញុំចង់សួរលោក គឺថានៅពេលនោះ តើលោកបានឮអំពីប្រជាជនគាត់និយាយអំពីហេតុការណ៍ទាំងអស់នេះ គឺនិយាយអំពីហេតុការណ៍ដែលថា ពួកខ្មែរក្រហមត្រូវបានគេសម្លាប់ដោយសារតែពួកអ្នកដឹកនាំខ្មែរក្រហម ពួកមូលដ្ឋានខ្មែរក្រហមនោះធ្វើឲ្យប្រជាជនអត់បាយ? តើលោកដែលឮអំពីហេតុការណ៍នេះដែរឬទេ?

[១០:៣១:៥០]

**ឆ៖** ចំពោះហេតុការណ៍នេះ គឺខ្ញុំមិនជាច្បាស់លាស់ទេ ពីព្រោះថាវាជាកិច្ចការរបស់ខ្មែរក្រហមថ្នាក់លើ។ ដូច្នេះខ្ញុំឆ្លើយមិនបានទេ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណណាស់លោកមេធាវី។ អរគុណសាក្សី។ ឥឡូវដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក ២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញ ដល់សាក្សីនិងមេធាវីប្រឹក្សាសាក្សីនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្ដល់សក្ខីកម្មនេះវិញ នៅវេលាម៉ោងដប់មួយខ្វះដប់នាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣២នាទី ដល់ម៉ោង ១០:៥១ នាទី)*

[១០:៥២:០៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តដំណើរការនីតិវិធីសវនាការ ហើយនិងផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក នួន ជា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

សូមអញ្ជើញ!

**លោក ហ្សាស្កេី ប៉ោ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ហ្សាស្កេី ប៉ោ៖**

**ស៖** មុនពេលដែលយើងសម្រាក យើងបានពិភាក្សាអំពីឆ្នាំដែលមន្ទីរសន្តិសុខដែលត្រូវបានគេបិទ។ ហើយនៅក្នុងការសម្ភាសរបស់លោកជាមួយនឹងលោក ហង់រី ឡូកា លោកសាក្សីបានបញ្ជាក់ថា "នៅពេលដែលមន្ទីរសន្តិសុខត្រូវបានគេបិទ ឯកសារទាំងអស់នៅក្នុងមន្ទីរសន្តិសុខត្រូវបានបំផ្លាញ"។ លោកដឹងដែរឬទេ ថាតើហេតុអ្វីបានជាគេបំផ្លាញឯកសារនៅក្នុងមន្ទីរសន្តិសុខទាំងអស់នោះ?

[១០:៥៣:២៣]

**លោក ប៉េជុយ ជីបសែ៖**

**ឆ៖** ខ្ញុំបានដឹងថា ការដែលបំផ្លាញមន្ទីរសន្តិសុខពង្រហ្នឹង ដោយសារកន្លែងហ្នឹង ជាតំបន់ព្រៃដែលពួកខ្មែរក្រហមបានទៅធ្វើកន្លែងសន្តិសុខ។ ហើយការបំផ្លាញហ្នឹង ដោយសារវាចោទថា ពួកមុនថា ពួកខ្មែរក្រហមមុននោះ ពួកមុន បានខ្ញុំនិយាយថា ពួកខ្មែរក្រហមមុន សុទ្ធតែជាអ្នកក្បត់បដិវត្តន៍របស់វា។ ដូច្នេះ អ្វីៗគឺវាត្រូវផ្លាស់ប្ដូរ ដូច្នេះវាត្រូវបំផ្លាញកន្លែងចាស់ចោល។ នេះគឺខ្ញុំបានដឹងត្រឹមហ្នឹង។

**ស៖** នៅពេលដែលមន្ទីរសន្តិសុខត្រូវបានគេបិទ គេបំផ្លាញហ្នឹង តើអ្នកទោសហ្នឹង ត្រូវបានគេដោះលែងចេញពីមន្ទីរសន្តិសុខដែរឬទេ? ហើយតើលោកអាចធ្វើការប៉ាន់ប្រមាណមើល ថាតើមាន

មនុស្សប្រហែលជាប៉ុន្មានដែលត្រូវបានគេដោះលែងចេញពីមន្ទីរសន្តិសុខ នៅពេលដែលគេបិទមន្ទីរសន្តិសុខនោះ?

**ឆ៖** បាទ នៅពេលដែលបិទមន្ទីរសន្តិសុខនុ៎ង គឺមានចំនួនមនុស្សប្រហែលជាង១០០នាក់។ នេះគឺថាការប៉ាន់ស្មាន។ ហើយពេលបិទហ្នឹង គឺមានការប្រជុំ ដើម្បីប្រាប់អំពីឲ្យថា អ្នកទោសទាំងអស់ហ្នឹងដឹងថាគេដោះលែងអស់ហើយ អត់មានទុកសម្រាប់យកទៅកន្លែងផ្សេងទេ។ ដូច្នេះសូមឲ្យបងប្អូនទៅនៅភូមិឃុំរបស់ខ្លួនវិញចុះ ទាំងអ្នកទោសស្រាលធ្ងន់ គឺរំសាយពេលហ្នឹងគឺថាទាំងអស់គ្នា ចំនួនជាង១០០នាក់។

**ស៖** លោកហង់រី ឡូកា បានសម្ភាសមនុស្សដទៃទៀតនៅក្នុងតំបន់ ដែលលោកបំពេញការងារនៅក្នុងសម័យនោះ។ ហើយសាក្សីមួយចំនួនៗបានបញ្ជាក់ថា មានការផ្លាស់ប្តូរគោលនយោបាយនៅក្នុងឆ្នាំ១៩៧៧ ហើយប្រធានស្រុកដែលសាក្សីគាត់រស់នៅនុ៎ងគឺថា បានប្រកាសថា “ខ្មែរក្រហមមានការធ្វើកំហុស គឺមានកំហុស ឬក៏ គឺថាខ្មែរក្រហមមិនគួរឃុំឃាំងមនុស្សច្រើនបែបនេះទេ”។ ដូច្នេះ តើលោកខ្លួនលោកផ្ទាល់ តើលោកធ្លាប់ឮអំពីការនិយាយ ឬក៏ការប្រកាសដែលថា អ្នកដែលដឹកនាំមុនពួកគាត់ចូលមកហ្នឹង មិនគួរឃុំឃាំងមនុស្សច្រើនបែបនេះទេ។ តើលោកធ្លាប់ឮអំពីការនិយាយបែបនេះទេ?

[១០:៥៦:៤០]

**ឆ៖** បាទ ខ្ញុំបានធ្លាប់ឮ វានិយាយបែបនេះ ពីព្រោះខ្មែរក្រហមដែលប្រកាសនេះគឺថា ដូចជាវាកែប្រែគោលនយោបាយរបស់វា។ វាបានចោទអ្នកមុនថា សុទ្ធតែជាពួកសម្លាប់ប្រជាជន ធ្វើឲ្យប្រជាជនអត់បាយក្រហាយទឹក ដូច្នេះ គឺក្នុងសំណួរនេះ គឺលោកនិយាយនេះគឺត្រឹមត្រូវ។

**ស៖** សូមអរគុណលោក។ ឥឡូវនេះខ្ញុំសូមត្រឡប់ក្រោយបន្តិច មកនិយាយអំពីបញ្ហានៃការសម្លាប់ទាហាន និងអតីតមន្ត្រីរដ្ឋការសម័យលន់ នល់។ តើលោកចាំដែរឬទេ ថាតើអ្នកណាចូលរួមនៅក្នុងការសម្លាប់ទាហាន និងមន្ត្រីទាំងអស់នោះ? ថាតើអ្នកណាជាអ្នកអនុវត្តការសម្លាប់ទៅលើមន្ត្រី និងទាហានទាំងអស់នោះ? តើលោកចាំទេ?

**ឆ៖** នេះគឺបើតាមការចងចាំរបស់ខ្ញុំ គឺខ្ញុំថា មានពួកដែលគេយកពីកន្លែងសន្តិសុខពង្រនោះមួយចំនួន ហើយអ្នកដែលដឹកនាំការសម្លាប់នោះគឺប្រហែលជាពួកទាហាន ទាហានហ្នឹងប្រហែលជាពួកតំបន់ ក៏ខ្ញុំមិនបានច្បាស់ដែរ ប៉ុន្តែថា ពីព្រោះខ្ញុំកន្លែងហ្នឹង គឺមិនអាចឆ្លើយក្បោះក្បាយបានទេ គឺដឹងតែថាពួកសន្តិសុខពង្រមកចូលរួមក្នុងការយកទាហានយកទៅសម្លាប់នៅតំបន់ទំនប់ម្កាក់។

**ស៖** តើលោកមានបានឃើញដោយផ្ទាល់ថា ទាហានតំបន់បានចូលរួមក្នុងការសម្លាប់មនុស្ស នោះដែរឬទេ ឬមួយក៏លោកគ្រាន់តែឮគេនិយាយទេ?

**ឆ៖** បាទ គឺខ្ញុំឮតែគេនិយាយទេ ត្រង់ថាឃើញគឺអត់ដែលឃើញទេ គឺសូមបញ្ជាក់ប្រាប់ច្បាស់ អ៊ីចឹងតែម្តង។

[១០:៥៩:៣៤]

**ស៖** សូមអរគុណលោក។ ឥឡូវនេះ ខ្ញុំសូមបន្តទៅប្រធានបទបន្ទាប់។ ហើយប្រធានបទនេះ គឺពាក់ព័ន្ធទៅនឹងការសម្ភាសរបស់លោក ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត។ លោកប្រធានបានសួរលោកនៅថ្ងៃទី១ នៅថ្ងៃដំបូង ហើយសួរលោកថាតើលោកសម្ភាសប៉ុន្មានដងជាមួយនឹងសហចៅក្រមស៊ើបអង្កេត។ ហើយលោកនិយាយថា លោកធ្លាប់សម្ភាស២ដង។ សំណួររបស់ខ្ញុំគឺថា តើលោកមានបាននិយាយអំពីបទពិសោធន៍របស់លោកនៅមន្ទីរសន្តិសុខពង្រទាំងពីរការសម្ភាសនោះដែរឬទេ? បានន័យថា លោកនិយាយទាំងការសម្ភាសលើកទី១ និងនិយាយនៅក្នុងការសម្ភាសលើកទី២ តើលោកមានបាននិយាយទាំងពីរដងដែរឬទេ?

**ឆ៖** ចំពោះសំណួរនេះគឺខ្ញុំមិនអាចឆ្លើយបាន ដោយសារមិនទាន់យល់សំណួរច្បាស់លាស់ សូមម្តងទៀត។

**ស៖** ខ្ញុំនឹងសួរសំណួរលោកម្តងទៀត លោកបានជួបជាមួយអ្នកស៊ើបអង្កេត សហចៅក្រមស៊ើបអង្កេតចំនួន ២ដង តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ គឺត្រឹមត្រូវណាស់ គឺខ្ញុំបានជួបខាងស៊ើបអង្កេតហ្នឹង ២ដងមែន។

[១១:០១:២០]

**ស៖** តើអ្នកស៊ើបអង្កេតមានបានសួរលោកអំពីមន្ទីរសន្តិសុខពង្រទាំងការសម្ភាសលើកទី១ និងការសម្ភាសលើកទី២ ដែរឬទេ?

**ឆ៖** ចំពោះសំណួរដែលខាងស៊ើបអង្កេតសួរហ្នឹងគឺថា លោកសួរនៅៗលើកទី១ ហ្នឹងអស់ហើយ ប៉ុន្តែមានខ្វះចន្លោះខ្លះដែលលោកត្រូវបំពេញហ្នឹងក៏លោកណាត់ជួបខ្ញុំនៅសាលាដែលខ្ញុំបង្រៀនហ្នឹងគឺសាលាគីឡូតាឈឹមហ្នឹង បន្ថែមទៀត។ អាហ្នឹងគឺថាវាជាសំណួរ ដូចថាបំពេញឱ្យពេញនូវការស៊ើបអង្កេតទេ។

**ស៖** តើលោកចាំដែរឬទេ តើសំណួរបំពេញ ឬក៏សំណួរបំពេញបន្ថែមដែលលោកថានៅលើក

ទី២នោះ តើគេសួរអំពីអ្វីដែរ តើលោកចាំដែរឬទេ?

**ឆ៖** បាទ ចំពោះលើកទី២ហ្នឹង គឺខ្ញុំអត់ចាំសោះមកដល់ពេលនេះ សូម -- មិនអាចថាអ្វីខ្លះទេ គឺខ្ញុំភ្លេចអស់ហើយ។

**ស៖** តើលោកចាំដែរឬទេ ថាតើការសម្ភាសលើកទី២ហ្នឹងត្រូវបានថតជាខ្សែអាត់ដែរឬទេ?

**ឆ៖** បាទ ក្នុងការដែលសម្ភាសលើកទី២ហ្នឹង គឺដូចជាខ្ញុំមិនចាំទៀតអារឿងថាមានខ្សែអាត់ហ្នឹង គឺថាដូច -- ឥឡូវដូចខ្ញុំនិយាយស្មានទៅមិនដឹងជាខុស ឬត្រូវ បែបគ្មានទេ គឺគ្មានខ្សែអាត់ទេ។

**ស៖** តើលោកចាំដែរឬទេថា ការសម្ភាសលើកទី១ ដែលលោកសម្ភាសជាមួយនឹងអ្នកស៊ើបអង្កេតហ្នឹង គឺមានថតជាសំឡេងដែរឬទេ?

[១១:០៣:៣៧]

**ឆ៖** បាទ សម្ភាសលើកទី១ ហ្នឹង ឃើញថាក្រុមស៊ើបអង្កេតក្តីហ្នឹង គឺមានគ្នាច្រើនដែរគឺថាមានការ -- ខ្ញុំចាំបានតែថាមានស្បថចំពោះមុខព្រះ ហើយក៏ធ្វើការសម្ភាស ប្រហែលជាៗមានចាក់ជាខ្សែអាត់សំឡេងផង ក៏មកដល់ពេលនេះគឺខ្ញុំមិនសូវជាច្បាស់លាស់ដែរ។

**ស៖** តើអ្នកស៊ើបអង្កេតមានបានបង្ហាញឯកសារខ្លះ ឬក៏ឯកសារណាមួយដែរឬទេទាំងនៅក្នុងការសម្ភាសទី១ ក៏ដូចជាការសម្ភាសទី២នោះ?

**ឆ៖** បាទ ចំពោះអ្នកទៅសម្ភាសហ្នឹងគឺខ្ញុំក៏មិនបានជាចាំថាគាត់ផ្តល់ឯកសារឲ្យខ្ញុំដែរឬមួយក៏យ៉ាងដូចម្តេចទេ គឺមកដល់ពេលនេះគឺខ្ញុំភ្លេចទាំងស្រុង។ គឺខ្ញុំភ្លេច។

**ស៖** ឥឡូវនេះខ្ញុំព្យាយាមរំឭកការចងចាំរបស់លោក។ តើអ្នកស៊ើបអង្កេតមានបានបង្ហាញអំពីចម្លើយរបស់សាក្សីដទៃទៀត ថាតើអ្នកស៊ើបអង្កេតមានបានអាននូវចម្លើយរបស់សាក្សីដទៃទៀតឲ្យលោកស្តាប់ដែរឬទេ?

**ឆ៖** ឯចំពោះលោកសួរសំណួរនេះ ខ្ញុំក៏ចាំមិនបានដែរ គឺឆ្លើយមិនរួចទេសំណួរហ្នឹង គឺខ្ញុំវាភ្លេចច្រើន។

**ស៖** នៅពេលដែលគេសម្ភាសលោកលើកទី២ នៅពេលដែលគេសួរសំណួរបំពេញបន្ថែមដល់លោកនោះ តើលោកដឹងដែរឬទេថា អ្នកស៊ើបអង្កេតមានបានធ្វើការរៀបចំជាកំណត់ហេតុស្តាប់ចម្លើយសង្ខេបទៅលើការសម្ភាសលើកទី២ របស់លោកហ្នឹង? តើអ្នកស៊ើបអង្កេតគាត់មានបានរៀបចំជាកំណត់ហេតុស្តាប់ចម្លើយសង្ខេបចំពោះការសម្ភាសលោកនោះដែរឬទេ?

[១១:០៦:១២]

**ឆ៖** បាទ ខ្ញុំចំពោះការឆ្លើយ គឺខ្ញុំកន្លែងហ្នឹងក៏សូម នេះគឺខ្ញុំមិនចាំ មិនដឹងជាមានការកំណត់ហេតុ ឬមួយក៏អ្វី ឯកសារអ្វី គឺខ្ញុំភ្លេចទាំងស្រុងតែម្តង។

**ស៖** សំណួរដែលខ្ញុំចង់សួរ គឺប្លែកបន្តិច ខុសពីមុនបន្តិច។ តើលោក ខ្លួនលោកផ្ទាល់ដឹងដែរឬទេ ថាមានកំណត់ត្រា ឬក៏សៀវភៅកំណត់ហេតុនៅក្នុងការសម្ភាសដោយអ្នកស៊ើបអង្កេតនោះ គឺអ្នកស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេតនោះ? តើលោកដឹងថាមានកំណត់ត្រា ឬក៏មានកំណត់ហេតុ ឬក៏មានសៀវភៅកំណត់ត្រាអ្វីដែរឬទេ?

**ឆ៖** បាទ ចំពោះសំណួរនេះ គឺខ្ញុំសូមឆ្លើយថា នៅពេលដែលលោកសហស៊ើបអង្កេត លោកបានសម្ភាសជាមួយខ្ញុំរួចហើយ លោកក៏បានឱ្យកំណត់ហេតុអ្វីផ្សេងៗ គឺថាប្រគល់មកឱ្យរូបខ្ញុំ។ ដល់ក្រោយមកនេះខ្ញុំក៏រក្សាទុកមិនគង់វង្ស ដោយការកូនពីរលើកទៅ ខ្ញុំមិនដឹងជាដៃទៅឯណា ដល់ពេលរៀបថាមកធ្វើជាសាក្សីហ្នឹង រកមិនឃើញសោះ។ ដូច្នេះហើយក៏បានឯកសារពីមេធាវីទេ បានមើល ដឹងនូវការសម្ភាសរបស់សហស៊ើបអង្កេត។

[១១:០៨:០៧]

**ស៖** សំណួររបស់ខ្ញុំគឺថាចង់សួរបែបនេះ នៅពេលដែលគេសម្ភាសលោក គឺសម្ភាសដោយអ្នកស៊ើបអង្កេត តើលោកមានប្រើប្រាស់ ឬក៏ពឹងផ្អែកទៅលើកំណត់ត្រា ឬក៏សៀវភៅកំណត់ហេតុណាមួយដែលលោក ខ្លួនលោកផ្ទាល់បានត្រៀមរៀបចំដែរឬទេ?

**ឆ៖** បាទ ចំពោះដែលសហស៊ើបអង្កេត លោកទៅសម្ភាសជាមួយខ្ញុំហ្នឹង ខ្ញុំក៏អត់មានត្រៀមនូវអ្វីទាំងអស់ ដូចជាកំណត់ហេតុ កំណត់ត្រានៅក្នុងខ្លួនគឺអត់មានទេ គឺរកនឹកឆ្លើយដោយការចងចាំរបស់ខ្ញុំតែម្តង។

**ស៖** លោកនិយាយថា លោកមិនបានរៀបចំអ្វីទុកជាមុននោះទេ តើលោកមានបានអាននូវកំណត់ត្រា ឬក៏កំណត់ហេតុដែលរៀបចំដោយអ្នកដទៃ គឺមិនមែនដោយលោកទេ ប៉ុន្តែរៀបចំដោយអ្នកដទៃ តើលោកមានអាននូវកំណត់ហេតុ ឬកំណត់ត្រាបែបនោះដែរឬទេ?

**ឆ៖** បាទ ចំពោះដែលការអានហ្នឹង គឺខ្ញុំបានអានយ៉ាងយកចិត្តទុកដាក់ នៅពេលដែលសហស៊ើបអង្កេតគាត់ប្រគល់ឱ្យដល់ដៃខ្ញុំមក ខ្ញុំក៏អានដើម្បីមើលការឆ្លើយរបស់ខ្ញុំ គឺតើត្រឹមត្រូវ ឬមួយក៏យ៉ាងដូចម្តេច ហើយក៏ខំរក្សាទុក ប៉ុន្តែខ្ញុំរក្សាទុកមិនបានគង់វង្ស។ ខ្ញុំខំប្រឹងអានយ៉ាងយកចិត្តទុកដាក់

បំផុត។

[១១:១០:១០]

**ស៖** លោកសាក្សី ខ្ញុំមិនមែននិយាយអំពីកំណត់ហេតុស្តាប់ចម្លើយសាក្សី ដែលរៀបចំឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេតនោះទេ។ ខ្ញុំនិយាយអំពីកំណត់ត្រាដែលរៀបចំ ដោយលោកឬក៏អ្នកដទៃមុនពេលដែលមានការសម្ភាសដោយអ្នកស៊ើបអង្កេតនោះ។ សំណួររបស់ខ្ញុំ គឺចង់សួរលោកថា តើលោកមានបានពឹងផ្អែក ឬក៏បានប្រឹក្សាទៅលើកំណត់ត្រា ឬក៏កំណត់ហេតុណាមួយនៅក្នុងពេលកំពុងសម្ភាសជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ?

**ឆ៖** បាទ ចំពោះសំណួរនេះ ខ្ញុំសូមឆ្លើយថា ខ្ញុំអត់មានបានពឹងផ្អែក ឬមួយក៏មានឯកសារអីទេ គឺការឆ្លើយរបស់ខ្ញុំពេលនោះ គឺពឹងលើការចងចាំរបស់ខ្ញុំទាំងអម្បាលម៉ានដែលបានស្ថិតនៅក្នុងពេលដែលខ្ញុំនៅធ្វើការជាមួយនឹងខ្មែរក្រហមហ្នឹង គឺខ្ញុំពឹងផ្អែកលើការចងចាំដែលខ្ញុំមានទាំងប៉ុន្មានហ្នឹង គឺបញ្ចេញមកតែម្តង អត់មានថាមានពឹងផ្អែកលើបុគ្គលណា ឬមួយក៏អ្វីទាំងអស់ គឺលោកសហស៊ើបអង្កេតសួរអ្វី ក៏ខ្ញុំឆ្លើយទៅតាមនោះទៅ។

[១១:១១:៥៤]

**ស៖** ខ្ញុំសួរលោកទៅលើចំណុចទាំងអស់នេះ ព្រោះថានៅពេលដែលក្រុមការងារខ្ញុំស្តាប់ទៅលើខ្សែអាត់សំឡេងនៃការសម្ភាសរបស់លោក គេសួរលោកនូវសំណួរមួយចំនួន ហើយស្តាប់ទៅគឺហាក់ដូចជា លោកនិយាយថា "តើខ្ញុំអាចមើលសៀវភៅកំណត់ហេតុ ឬក៏ថា ខ្ញុំសូមមើលនូវសៀវភៅ*ណូត*របស់ខ្ញុំបានដែរឬ ក៏អត់"។ អានេះគឺជាអ្វីដែលស្តាប់ឮតាមខ្សែអាត់។ ហើយបន្ទាប់អ្នកស៊ើបអង្កេតប្រាប់ថា "បាទ លោកអានបាន លោកមើលបាន"។ ហើយបន្ទាប់មក លោកក៏ផ្តល់នូវចម្លើយផ្សេងខុសពីអ្វីដែលលោកផ្តល់មុន។ ដូច្នេះសំណួររបស់ចង់សួរលោកម្តងទៀតថា តើលោកមានបានប្រើប្រាស់ ឬក៏មានបានអាននូវកំណត់ហេតុ ឬក៏កំណត់ត្រាណាមួយ នៅពេលដែលលោកសម្ភាសជាមួយអ្នកស៊ើបអង្កេតនោះដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ឌែល លីសាក់៖**

សូមអរគុណលោកប្រធាន។ ប្រសិនបើមេធាវី គាត់លើកឡើងអំពីខ្សែអាត់ គាត់គួរតែបង្ហាញ

អំពីឯកសារយោងទៅលើខ្សែអាត់ថតសំឡេងដែលគាត់លើកឡើងនោះ។ គាត់មិនគួរគ្រាន់តែលើកឡើង ហើយក៏បំពេញតួនាទីជាអ្នកផ្តល់សក្ខីកម្មទៅវិញនោះទេ។ ដូច្នេះហើយ គាត់គួរតែបង្ហាញអំពីឯកសារយោង លេខយោងនៃខ្សែអាត់សំឡេងនោះ។

[១១:១៣:៥៣]

**លោក ហ្វាស្តេ ប៉ោ៖**

លោកប្រធាន ខ្ញុំនឹងផ្តល់នូវផ្នែកនេះ គឺយើងអាចស្តាប់ឮនៅលើខ្សែអាត់សំឡេងដែលសម្ភាសសាក្សីនេះ គឺនៅត្រង់នាទី ១៤:00 នៃការសម្ភាស ហើយការថតសំឡេង វាមិនច្បាស់នោះទេ។ ប៉ុន្តែនៅពេលដែលការស្តាប់ទៅលើសំឡេង នេះគឺជាអ្វីដែលសាក្សីបានបញ្ជាក់។ ដូច្នេះ ខ្ញុំចង់ផ្តល់ឱកាសឲ្យសាក្សី ដើម្បីបញ្ជាក់ថា តើសាក្សីពិតជាបានពឹងផ្អែកទៅលើកំណត់ត្រា ឬក៏សៀវភៅ*ណូត*ណាមួយ នៅពេលដែលគាត់សម្ភាសជាមួយអ្នកស៊ើបអង្កេតដែរឬអត់?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

យើងសូមជំទាស់ទៅលើការសួរសាក្សីបែបនេះ។ មេធាវីគួរតែមានប្រតិចារឹកនៃការបកស្រាយសំឡេង ប៉ុន្តែឥឡូវនេះគាត់គ្រាន់តែ -- គ្រាន់និយាយថាសំឡេងដែលថតហ្នឹង វាមិនច្បាស់លាស់ មិនអ្វីហើយគាត់ក៏សួរសាក្សី។ ដូច្នេះហើយគាត់គួរតែរៀបចំ ឬក៏មានការបង្ហាញសំឡេងនៃការថត សំឡេងនេះនៅក្នុងតុលាការ ជាជាងការគ្រាន់តែបង្ហាញថា តើផ្នែកណាមួយដែលគាត់និយាយ ឬក៏នៅនាទីណាមួយដែលបាននិយាយបែបនេះនោះទេ។

**លោក ហ្វាស្តេ ប៉ោ៖**

លោកប្រធាន ខ្ញុំមិនមែនពឹងផ្អែកទៅលើកំណត់ហេតុ ទៅលើខ្សែអាត់សំឡេងនោះទេ។ ខ្ញុំគ្រាន់តែចង់ឲ្យសាក្សីឆ្លើយតបផ្អែកទៅលើអ្វីដែលយើងបានស្តាប់ឮនៅក្នុងខ្សែអាត់ថតសំឡេង។ ហើយខ្សែអាត់សំឡេងនេះ គឺឲ្យ -- គឺភាគីនានាអាចស្តាប់បានគ្រប់គ្នាទាំងអស់ រួមទាំងជំនុំជម្រះផងដែរ។

[១១:១៦:០៩]

ការលើកឡើងអំពីខ្សែអាត់ថតសំឡេងនេះ វាពាក់ព័ន្ធព្រោះតែនៅពេលនេះ សាក្សីគាត់និយាយថា គាត់អត់បានពឹងផ្អែក ឬក៏អត់បានអានទៅលើកំណត់ហេតុ ឬក៏សៀវភៅ*ណូត*ណាមួយឡើយ។ ដូច្នេះខ្ញុំ

គ្រាន់តែលើកឡើងពីចំណុចទាំងអស់នេះ គ្រាន់តែដើម្បីជារំឭកឲ្យសាក្សីគាត់នឹកឃើញអំពីការដែលគាត់ពឹងផ្អែក ឬក៏គាត់អានទៅលើសៀវភៅ*ណូត*នៅពេលដែលគាត់សម្ភាសជាមួយអ្នកស៊ើបអង្កេត។

[១១:១៦:៣៤]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:១៧:០៤]

**ប្រធានអង្គជំនុំ៖**

សេចក្ដីជំទាស់ និងសំអាងហេតុនៃសេចក្ដីជំទាស់របស់តំណាងសហព្រះរាជអាជ្ញាសមស្រប។ សំណួរនេះ គឺមិនមានមូលដ្ឋានជាក់ច្បាស់ទេ ជាសំណួរដែលនាំឲ្យសាក្សីឆ្លើយស្មានៗប៉ុណ្ណោះ។ សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរសួរចុងក្រោយដោយមេធាវីអន្តរជាតិការពារក្ដីលោក នួន ជា ដែលសួរលោកអម្បាញ់មិញនេះទេ!

**លោក ហ្សាស្ដើ ប៉ោ៖**

លោកប្រសិនបើក្នុងករណីនេះ ខ្ញុំនឹងសូមអនុញ្ញាតបង្ហាញ ឬក៏ចាក់នូវកាសែតអាត់ថតសំឡេងនេះនៅក្នុងតុលាការ។ ប៉ុន្តែដោយសារតែខ្សែអាត់ថតសំឡេងមិនច្បាស់ ដូច្នេះខ្ញុំសូមអនុញ្ញាតឲ្យចាក់ខ្សែអាត់ថតសំឡេងឲ្យបានពីរទៅបីដង។ ហើយយើងនឹងរៀបចំនូវខ្សែអាត់ថតសំឡេងនេះ ហើយយើងនឹងចាក់ យើងនឹងបញ្ជាក់ទាំងអស់គ្នា ដើម្បីជៀសវាងនូវការយល់ច្រឡំណាមួយនៅក្នុងអង្គជំនុំជម្រះ។

[១១:១៨:២៦]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត! សូមអញ្ជើញ!

**លោក ហ្សាស្ដើ ប៉ោ៖**

ខ្ញុំគិតថា ដើម្បីធ្វើបែបនេះ បានយើងត្រូវស្នើឲ្យមន្ត្រីតុលាការត្រូវតែទៅយកនូវខ្សែអាត់ថតសំឡេងមួយច្បាប់មក ហើយខ្ញុំមិនដឹងច្បាស់ថា ម៉េចនោះទេ? ថាឥឡូវយើងរៀបចំរួចរាល់ហើយ ថាប្រសិនបើលោកប្រធានអនុញ្ញាត ខ្ញុំនឹងចាក់ឲ្យស្ដាប់។ ហើយឥឡូវនេះ យើងទទួលបានការអនុញ្ញាតទៅហើយ ដូច្នេះ ខ្ញុំនឹងពិនិត្យមើល។

[១១:១៩:១៧]

*(សម្រាករយៈពេលខ្លី)*

[១១:២១:៤១]

**ប្រធានអង្គជំនុំ៖**

បាទ ខាងសោតទស្សន៍ចូរបង្ហាញនូវផ្នែកបទសម្ភាសន៍ ដែលពាក់ព័ន្ធនឹងសំណើសុំរបស់លោកមេធាវីអន្តរជាតិការពារក្តីលោក នួន ជា ដែលបានសុំដាក់បង្ហាញនៅក្នុងសវនាការ នៅលើកញ្ចក់អេក្រង់ទូរទស្សន៍ និងកុំព្យូទ័រ។ សូមអញ្ជើញ!

[១១:២២:១៤]

(ការបង្ហាញឯកសារសំឡេង)

*"ពេលណាដែលវាយាមចប់មួយៗ វាបាញ់ទៅលើ។ បាញ់ស៊ីញ៉ូគ្នាវាឲ្យមកយាមជំនួស។ (សូមលោកចេញទៅនោមបន្តិច។ បាទៗ) នេះ គឺវាមានដេញវៀតណាម ឲ្យទៅស្រុកវិញ ឆ្នាំ៧៥ៗ មិនទាន់រំដោះទេ ពេលនោះ។ ដល់ពេលនោះ ខ្មែរដែលបម្រើក្នុងកងទ័ពយួនហ្នឹង គឺថាប្រុងទៅតាម -- ប្រុងកងទ័ពៗ វៀតណាម។ វាក៏ចាប់ពួកនោះឯង យកទៅសម្លាប់"។*

(បញ្ចប់ការបង្ហាញឯកសារសំឡេង)

[១១:២៣:២៤]

**លោក ហ្សាស្តេី ប៉ោ៖**

លោកប្រធាន ខ្ញុំសូមបញ្ចប់ ហើយព្រោះថា ផ្នែកដែលខ្ញុំចង់និយាយ គឺថាបានបញ្ជាក់រួចទៅហើយ ហើយខ្ញុំបានពិភាក្សាជាមួយក្រុមខាង ខៀវ សំផន គឺបានបញ្ជាក់ថា គឺពិតជានិយាយបែបនេះមែន។ ប្រសិនបើអនុញ្ញាត ឬក៏មានតម្រូវការចាំបាច់ អាចនឹងចាក់មួយសាទៀត ឬក៏ចាក់ម្តងទៀត ប៉ុន្តែចំពោះយ៉ាងណាក៏ដោយ គឺថាផ្នែកដែលនិយាយអំពីសៀវភៅ*ណូត*នោះ គឺបានធ្វើឡើង ឬក៏បាននិយាយនៅពេលចាប់ផ្តើមបន្តិច ប្រសិនបើមានតម្រូវចាំបាច់ ឬក៏ចង់ គឺថាយើងអាចសុំអនុញ្ញាតចាកសាជាថ្មីឡើងវិញ នូវសំឡេងនៃខ្សែអាត់នេះម្តងទៀត។

**ប្រធានអង្គជំនុំ៖**

ផ្នែកខាងសោតទស្សន៍ចាក់ម្តងទៀត។

[១១:២៤:១៩]

(ការបង្ហាញឯកសារសំឡេង)

*“ពេលណាដែលវាឃាមចប់មួយៗ វាបាញ់ទៅលើ បាញ់ស៊ីញ៉ូគ្នាវាឲ្យមកឃាមជំនួស។*
*(សុំលោកចេញទៅនោមបន្តិច។ បាទៗ)”*។

(បញ្ចប់ការបង្ហាញឯកសារសំឡេង)

[១១:២៤:៥៥]

**លោក ហ្សាស្តេី ប៉ោ៖**

លោកប្រធាន ផ្នែកដែលខ្ញុំចង់និយាយនោះ គឺបានចប់ហើយ។ ខ្ញុំសូមថ្លែងអំណរគុណចំពោះលោកប្រធាន ដែលបានអនុញ្ញាតឲ្យខ្ញុំចាក់នូវខ្សែអាត់ថតសំឡេង ដើម្បីបង្ហាញនូវតម្លាភាព ក៏ដូចជាដើម្បីបង្ហាញឲ្យច្បាស់ដល់អង្គជំនុំជម្រះ។

**សួរដោយលោក ហ្សាស្តេី ប៉ោ៖**

**ស៖** លោកសាក្សី លោក ជីបសែ អ្នក--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា យ៉ាងម៉េចទៅ?

**លោក ឌេល លីសាក់៖**

ខ្ញុំសូមជំទាស់ទៅលើមេធាវីការពារក្តី ដែលនិយាយថា បែបនេះ ព្រោះថាខាងសហការីរបស់ខ្ញុំនិយាយថា មិនច្បាស់លាស់ ស្តាប់ទៅមិនច្បាស់លាស់។ ដូច្នេះវាពិបាកនៅក្នុងការកំណត់ ដែលថាការធ្វើបែបនេះជាការរំឭកទៅដល់សាក្សី។ ខ្ញុំគិតថា សហការីរបស់ខ្ញុំ ដែលនិយាយភាសាខ្មែរ ក៏ជាជនជាតិខ្មែរ ក៏ស្តាប់មិនទាំងច្បាស់ផង រឿងអីលោកដែលជាជនបរទេសនិយាយខ្មែរមិនច្បាស់ លោកទៅបញ្ជាក់បែបនេះទៅវិញបាន?

[១១:២៦:១៣]

**លោក ហ្សាស្តេី ប៉ោ៖**

ខ្ញុំសូមបញ្ជាក់ថា ប្រហែលជាមិនបានស្តាប់ឮអ្នកណានិយាយនោះទេ។ ដូច្នេះ ខ្ញុំស្នើថា អាចនៅពេលណាមួយ នៅពេលក្រោយ គឺយើងស្តាប់ទៅលើផ្នែកនេះ ហើយនិងដោះស្រាយទៅលើបញ្ហាដែលយើងកំពុងជួបប្រទះ។

**សួរដោយលោក ហ្សាស្តេី ប៉ោ៖**

**ស៖** លោក ជីបសែ អ្វីដែលលោកបានស្តាប់ឮអម្បាញ់មិញនេះ តើលោកអាចប្រាប់យើងខ្ញុំបាន

ដែរឬទេ ថាតើនៅពេលនោះលោកពិតជាបានមើលទៅលើសៀវភៅកំណត់ត្រា ឬក៏សៀវភៅកំណត់ហេតុដែរឬអត់?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតបសាក្សី! ភាពមិនច្បាស់លាស់នៅតែមាន មិនគប្បីបន្តរបៀបនេះទេ។

[១១:២៧:០២]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:២៧:៤៦]

**ប្រធានអង្គជំនុំ៖**

លោក ជីបសែ លោកស្តាប់សំឡេងអំមិញ ដែលបានចាក់ផ្សាយឡើងវិញអម្បាញ់មិញនេះ តើវាជាសំឡេងរបស់លោកដែរឬទេ? ពិតមែនដែរឬទេលោកស្តាប់សំឡេងនេះបានទេ?

**លោក ប៉េជុយ ជីបសែ៖**

បាទ លោកប្រធាន ចំពោះខ្ញុំស្តាប់អម្បាញ់មិញហ្នឹងគឺថា ដូចមិនមែនសំឡេងខ្ញុំ អានេះគឺ ក្រែងតែខ្ញុំសំឡេងនៅក្នុងនោះវាខ្ទរយ៉ាងម៉េចមិនដឹងទេ។ ប៉ុន្តែសូមប្រាប់លោកប្រធាន ហាក់ដូចជាមិនមែនសំឡេងខ្ញុំ។ ហ្នឹងគឺខ្ញុំ--

**ប្រធានអង្គជំនុំ៖**

លោក ជីបសែ នៅក្នុងអំឡុងពេលធ្វើសម្ភាសហ្នឹង តើលោកមានបានសុំសម្រាកដើម្បីទៅនោមដែរទេ?

**លោក ប៉េជុយ ជីបសែ៖**

រឿងនេះ លោកប្រធាន ខ្ញុំក៏រហូតដល់ពេលនេះមិនចាំទេលោកប្រធាន គឺមិនដឹងជាបានទៅ ឬក៏មិនបានទៅ មិនចាំតែម្តង។

[១១:២៨:៥៧]

**ប្រធានអង្គជំនុំ៖**

សូមបន្តសំណួរផ្សេងទៀត ទៅមុខទៀតចុះ ពីព្រោះបញ្ហានេះមិនច្បាស់លាស់ទេ។ បើភាសាខ្មែរ បើតាមយើងដែលជាប្រធានអង្គជំនុំជម្រះស្តាប់ គឺគាត់សុំទៅនោមបន្តិច មិនមែនទៅ*ណូត*បន្តិចទេ។ ភាសាខ្មែរអត់មានទៅ*ណូត*បន្តិចទេ។ មានតែទៅនោម។ ព្រោះ *ណូត* នេះភាសាបរទេស។ ទាល់ -- បើ

ថាទៅយក ទៅយកកំណត់ហេតុ ទៅយកកំណត់ត្រា ទៅ--

**លោក ហ្សាស្តេ ប៉ោះ**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនធ្វើការតវ៉ាទៅលើភាសាខ្មែរ ដែលលោកប្រធានជួយបញ្ជាក់នេះទេ។ ក៏ប៉ុន្តែ ខ្ញុំមានសំណើសុំបន្ថែមមួយ សាក្សីគឺមិនស្គាល់ ឬក៏គាត់មិនជំទាស់ថា បាននិយាយពាក់ព័ន្ធនឹងកំណត់ហេតុ ឬក៏យ៉ាងណានោះទេ។ សាក្សីគឺគាត់គ្រាន់តែលើកឡើងថា គាត់មិនស្គាល់ថាសំឡេងនោះជាសំឡេងគាត់ ឬក៏មិនមែន។ បញ្ហានេះគឺ ហេតុផលដែលថាសំខាន់នោះ គឺថាដោយសារតែនៅក្នុងផ្នែកនៃខ្សែអាត់នេះ គឺយើងស្តាប់ឮយ៉ាង ច្បាស់ថាសាក្សីបានផ្តល់សក្ខីកម្ម ផ្តល់ចម្លើយពាក់ព័ន្ធទៅនឹងការឃុំខ្លួន និងការកាប់សម្លាប់ទាហាន លន់ នល់ នៅផ្សារដីក្រែង។ ហើយជាការពិតនៅក្នុងខ្សែអាត់នោះគឺបានលើកឡើងថា ជាសេចក្តីសន្និដ្ឋានរបស់ខ្ញុំមិនមែនជាភស្តុតាងនោះទេ។ សាក្សីបាននិយាយដោយក្រោយពីអ្នកសួរ --អ្នកស៊ើបអង្កេត សួរនោះគឺថា “ក្រៅពីទាហាន តើមានមន្ត្រីរដ្ឋការផ្សេងទៀតដែរឬទេ ដែលត្រូវបានឃុំខ្លួន ឬការកាប់សម្លាប់?” សាក្សីឆ្លើយថា “អត់មានទេ មន្ត្រីរដ្ឋការសាធារណៈគឺអត់មានទេ”។ ក្រោយនោះបន្តិច នៅក្នុងខ្សែអាត់គេសួរសាក្សីថាតើ -- សាក្សីបានស្នើសុំថាតើខ្ញុំអាចមើលកំណត់ហេតុដែរឬទេ? បន្ទាប់ មកសាក្សីឆ្លើយថា “ខ្ញុំសូមប្រាប់ចំណុចមួយទៀត ថាមិនមែនមានតែទាហាននោះទេ គឺមានទាំងមន្ត្រីរដ្ឋការផងដែរ”។ ដូច្នេះចំណុចនេះវាពាក់ព័ន្ធទៅនឹងប្រភពនៃការដឹងរបស់សាក្សី ហើយយើងមិនដឹងថា តើនរណាគេនៅក្នុងខ្សែអាត់នោះជាអ្នកនិយាយទោះបីជាក្រុមរបស់យើងខ្ញុំលើកឡើងថា សាក្សីជាអ្នក និយាយនោះក៏ដោយ នេះជាឧទាហរណ៍មួយ។

ហើយខ្ញុំសូមចាក់ខ្សែអាត់មួយដែលប្រហែលជា ២នាទី ជាងបន្តិច ជុំវិញទៅនឹងខ្សែអាត់ដែលយើងស្តាប់អម្បាញ់មិញនេះ ថាតើសាក្សីបាននិយាយឬក៏យ៉ាងណា ហើយថាតើមានមន្ត្រីរដ្ឋការដែរឬទេដែលត្រូវបានគេឃុំខ្លួន និងកាប់សម្លាប់។ ហើយក្រោយខ្សែអាត់នេះ បន្តិចនោះគឺថា មានការស្នើសុំមើលកំណត់ហេតុ ហើយក្រោយមកសាក្សីបានប្តូរចម្លើយរបស់ខ្លួន។

[១១:៣២:២១]

ដូច្នេះ លោកប្រធានជាទីគោរព! គឺខ្ញុំសូមថ្លែងអំណរគុណលោកប្រធានដែលបានអនុញ្ញាតឲ្យខ្ញុំប្រើបច្ចេកទេសសនៃការចាក់ខ្សែអាត់នេះឡើងវិញ។ ហើយខ្សែអាត់ដែលខ្ញុំស្នើចាក់ម្តងទៀតនេះគឺ ២នាទី លើសបន្តិចតែប៉ុណ្ណោះ ហើយវាបង្ហាញអំពីប្រភពនៃការដឹងរបស់សាក្សី តើគាត់ដឹងដោយរបៀបណា ដូច្នេះលោកប្រធាន គឺខ្ញុំស្នើសុំឲ្យចាក់ខ្សែអាត់ដែលមានរយៈពេល ២នាទីកន្លះនេះស្តាប់។

**លោក ឌេល លីសាក់៖**

យើងខ្ញុំមិនជំទាស់ទេការចាក់ខ្សែអាត់។ ខ្ញុំជំទាស់នឹងការបន្តព្យាយាមលើកឡើងខុស លើកឡើងចេញតែពីខ្លួនគាត់តែប៉ុណ្ណោះ ក្រុមខ្មែរខាងរបស់ខ្ញុំនេះ ខាងក្រុមខ្មែរ គឺមិនស្ដាប់ឮដូចដែលមេធាវី បានលើកឡើងនោះទេ។ ដូច្នេះហើយ ហើយគ្មាននរណាដែលនៅក្នុងនេះបញ្ជាក់ថា គាត់និយាយអំពីកំណត់ហេតុនោះទេ ដែលហៅថា *"ណូតប៊ុក"* នោះ។ ក្រុមគាត់ទេដែលលើកឡើងចំណុចនេះតែប៉ុណ្ណោះ។

[១១:៣៣:២៣]

យើងដឹងហើយថា យើងមិនឯកភាព អ៎!យើងមិនយល់ យើងមិនជំទាស់ទេ ចំពោះការចាក់ខ្សែអាត់ ហើយយើងដឹងផងដែរថានៅក្នុងពេលស្ដាប់ចម្លើយនោះ មានបុគ្គលជាច្រើនដែលបានចូលរួមនៅក្នុងដំណើរការនោះ។ យ៉ាងណាក៏ដោយ គឺយើងខ្ញុំជំទាស់វិធីដែលមេធាវីការពារក្ដីលើកឡើងបញ្ជាក់ទៅលើភស្តុតាងដោយខ្លួនគាត់ ហើយខ្ញុំមិនជំទាស់ចំពោះការចាក់ខ្សែអាតនោះទេ។

**លោក ហ្សាស្ទើ ប៉ោ៖**

ខ្ញុំសូមធ្វើការឆ្លើយតប។ ខ្ញុំមិនមែនធ្វើការលើកឡើងភស្តុតាងហ្នឹងដោយខ្លួនឯងនោះទេ គឺយើងដឹងហើយថា នៅក្នុងខ្សែអាត់នេះគឺមានការបក -- ក្រោយមកមានការបកប្រែទៅជាភាសាអង់គ្លេសសម្រាប់គ្រប់ភាគីដែលមិនអាចនិយាយភាសាខ្មែរបាន ឲ្យមើលទាំងអស់គ្នាបាន។ ជាការពិតគឺ សំណួរទាំងឡាយនោះគឺយើងបានមើលឃើញយ៉ាងច្បាស់ ហើយយើងយល់ទាំងអស់គ្នា។ ហើយលោកប្រធានបានបញ្ជាក់ហើយថា ចំណុចនេះវាអាចសមហេតុផល ដែលថាយើងអាចស្ដាប់ខ្សែអាត់បាន។ យើងដឹងហើយថានៅពេលនេះជនជាតិហូឡង់មួយរូប ហើយជនជាតិកាណាដា នៅក្នុងនេះ ពីរនាក់នេះ កំពុងតែតទល់គ្នាទៅលើភាសាខ្មែរដែលយើងមិនចេះនិយាយផងនោះ។ ដូច្នេះហើយ ខ្ញុំសូមអនុញ្ញាតចាក់តែម្ដងទៅឲ្យយើងស្ដាប់ឮទាំងអស់គ្នា។

[១១:៣៤:៤៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៣៦:៣៤]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ដើម្បីឆ្លើយតបទៅនឹងសំណើសុំរបស់មេធាវីអន្តរជាតិការពារក្ដីលោកៗ នួន ជា!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ ដូចដែលភាគីបានសង្កេតឃើញរួចមកហើយ ចៅក្រមបានលើកឡើងទៅលើបញ្ហានេះ។ ហើយឯកភាពថា មិនមានមូលដ្ឋាននោះទេចំពោះសារណាដែលមេធាវីការពារក្តី នួន ជា បានលើកឡើង។ ដូច្នេះហើយអង្គជំនុំជម្រះគឺ អាចស្តាប់ខ្សែអាត់បាន។ មានមូលដ្ឋានពីរ ទី១ គឺមិនច្បាស់ថាតើសាក្សីរូបនេះបានលើកឡើងថា តើគាត់សុំមើលកំណត់ហេតុ ឬក៏យ៉ាងណាដូចដែលលើកឡើងដោយមេធាវី នួន ជា។ ហើយពាក្យថា "ប្រើ" នោះគួរ -- ពាក្យដែលនិយាយក្នុងនោះក៏មិនដឹងថាសំដៅទៅលើកំណត់ហេតុដែលហៅថា *"ណូត"* ឬក៏យ៉ាងណា?

ដូច្នេះ វាគ្មានគោលបំណងអ្វីដែលថាយើងត្រូវត្រឡប់មកធ្វើការស្តាប់ខ្សែអាត់នេះឡើងវិញ ហើយព្យាយាមយល់ថាបាននិយាយអ្វីខ្លះនៅក្នុងខ្សែអាត់នោះ។ អង្គជំនុំជម្រះនៅពេលនេះគឺថា ស្នើសុំមេធាវីការពារក្តី នួន ជា ឲ្យបន្តសួរសំណួរបន្ថែមទៀតទៅ។

[១១:៣៨:១០]

**លោក ហ្សាស្តេី ប៉ោ៖**

សូមអរគុណចៅក្រម ខាតវ៉ាយថ៍។ ខ្ញុំយល់ និងស្តាប់បានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ខ្ញុំសូមធ្វើសេចក្តីសន្និដ្ឋាន ឬសំណើសុំបន្ទាប់ទៀតនេះ។

សាក្សីបានបញ្ជាក់ហើយថា "គាត់មិនស្គាល់ ហើយគាត់មិនដឹងថាតើសំឡេងនោះគឺជាសំឡេងរបស់គាត់ ឬក៏យ៉ាងណា"។ ហើយគាត់និយាយហើយថា ដោយសារតែសំឡេងនោះវាខ្សុរ ដូច្នេះហើយប្រហែលជាគាត់ស្តាប់មិនបាន។ ហេតុដូច្នេះទើបខ្ញុំសូមឲ្យចាក់ខ្សែអាត់ដែលវាមានរយៈពេលវែងជាងមុនបន្តិច ដើម្បីឲ្យសាក្សីនោះអាចផ្ទៀងផ្ទាត់ តើសំឡេងនោះគឺជាសំឡេងរបស់សាក្សី ឬក៏មិនមែន? ហើយខ្ញុំដឹងថាហេតុអ្វីបានជា គ្រាន់តែចាក់តែប៉ុណ្ណឹង វាបង្កើតជាបញ្ហាចំពោះយើង។

[១១:៣៩:០៥]

ហើយប្រសិនបើតុលាការនេះរកឃើញថា នោះជាសំឡេងរបស់សាក្សីនោះគឺសាក្សីអាចពន្យល់បន្ថែម ពន្យល់បន្ថែមបានទាក់ទងនឹងបញ្ហានេះ។ សំណើសុំរបស់ខ្ញុំបន្ទាប់គឺថា តើយើងអាចចាក់ខ្សែអាត់នេះឲ្យបានវែងជាមុនបន្តិចបានដែរឬទេ ដើម្បីឲ្យយើងបង្ហាញថាតើសំឡេងនោះគឺពិតជានិយាយដោយសាក្សី ឬក៏យ៉ាងណា? ហើយខ្ញុំគិតថាគ្រាន់តែរយៈពេល ២នាទីកន្លះនៅក្នុងខ្សែអាត់នោះ គឺអាចឲ្យយើងយល់ទាំងអស់គ្នាបាន ហើយអាចខ្ញុំគិតថាអាចចាក់ទៅបាន។

[១១:៣៩:៣៧]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៣៩:៤៨]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះជំទាស់មិនឯកភាពជាមួយនឹងសំណើនេះទេ។ ដោយផ្អែកទៅលើគោលការណ៍ដូចគ្នា។ ចំពោះក្រុមមេធាវីការពារក្ដី គឺយល់ច្បាស់ហើយថាសាក្សីដែលនិយាយនៅក្នុងសារនោះ គឺមិនច្បាស់ទាំងអស់គ្នាសម្រាប់អង្គជំនុំជម្រះផងដែរ។ ហើយម្យ៉ាងវិញទៀតយើងក៏មិនស្ដាប់ឮថា គាត់បាននិយាយប្រើប្រាស់ពាក្យអ្វីនៅក្នុងនោះ។ ដូច្នេះហើយគឺថាក្រុមមេធាវីមិនចាំបាច់ធ្វើសំណើ ដោយគ្រាន់តែប្រើប្រាស់វិធី ឬក៏លើកឡើងសំណើរបស់ខ្លួនក្នុងពាក្យពេចន៍ផ្សេងនោះទេ ដូច្នេះមេធាវីការពារក្ដីអាចបន្តទៅមុខទៀតបាន។

**លោក ហ្សាស្ដើ ប៉ោ៖**

លោកស្រីចៅក្រម ខ្ញុំសូមបញ្ជាក់ឲ្យបានច្បាស់ទៅលើចំណុចនេះ ដែលវាមាននិយាយនៅក្នុងខ្សែអាត់ តើយ៉ាងម៉េចដែរ?

**ប្រធានអង្គជំនុំ៖**

លោកបន្តទៀត បន្តសំណួរផ្សេងទៀត ក្រៅពីបញ្ហាដែលបានសម្រេចរួចហើយបានណ៎ា ហើយបើអស់សំណួរហើយ អាចប្រគល់វេទិកាទៅក្រុមមេធាវីផ្សេងទៀត។ ពីព្រោះពេលវេលាសម្រាប់សួរនេះ គឺនៅសល់តែ២០នាទីប៉ុណ្ណោះ សម្រាប់មេធាវីពីរក្រុមទៀត ព្រោះសាក្សីនេះយើងកំណត់ធ្វើសវនាការតែ១ថ្ងៃទេ មួយពេលសម្រាប់ខាងភាគីចោទប្រកាន់ ហើយមួយពេលខាងភាគីការពារក្ដី។

[១១:៤១:២៦]

**លោក ហ្សាស្ដើ ប៉ោ៖**

សូមអរគុណលោកប្រធាន។

សំណើសុំមួយទៀតនោះគឺថា សាក្សីនេះគឺគួរតែយល់ថាគាត់និយាយនៅក្នុងខ្សែអាត់នោះ ឬក៏យ៉ាងណា? ប្រសិនបើគាត់គិតថា គាត់និយាយមែននោះ គឺគួរតែបញ្ជាក់បំភ្លឺឲ្យបានច្បាស់។ យើងខ្ញុំ

គិតថា មិនមែនយើងស្វែងរកការពិតទេ ប្រសិនបើយើងមិនបញ្ជាក់ឲ្យបានច្បាស់លាស់ សួរថាតើវាជាពាក្យសម្តីរបស់គាត់ ដែលគាត់និយាយ ហើយពាក្យនោះគឺមានន័យយ៉ាងម៉េច? ដូច្នេះហើយនេះជាការស្វែងរកការពិតសម្រាប់យើង។ ពាក្យពេចន៍នៅក្នុងខ្សែអាត់នោះ គឺជាយន្តការមួយឲ្យយើងយល់ច្បាស់ស្វែងរកការពិតទាំងអស់គ្នា។ ហើយយើងគួរតែឲ្យសាក្សីនោះស្តាប់ទៅ តើគាត់ស្គាល់សំឡេងរបស់គាត់ដែរឬទេ? ហើយប្រសិនបើគាត់ថាជាសំឡេងរបស់គាត់នោះ ពាក្យស្អីខ្លះដែលគាត់បាននិយាយ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍!

[១១:៤២:៤០]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ លោក ប៉ៅ លោកធ្វើសំណើដដែលៗបីដងរួចមកហើយ ហើយសេចក្តីសម្រេចរបស់យើងខ្ញុំនៅតែដដែលៗ។ ខ្ញុំសូមរំឭកថា លោកប្រធានបញ្ជាក់ហើយ ប្រសិនបើលោកមិនបន្តសួរសំណួរបន្ទាប់ទៀតទេនោះទេ គឺលោកប្រធានគិតថា លោកអស់សំណួរហើយ។

**លោក ហ្សាស្តេ ប៉ៅ៖**

យើងខ្ញុំមិនចង់ឲ្យលោកប្រធានគិតដូច្នេះនោះទេ ដូច្នេះខ្ញុំសូមបន្តសួរសំណួរទៅមុខទៀត។

**សួរដោយលោក ហ្សាស្តេ ប៉ៅ៖**

**ស៖** លោកសាក្សី តើជាការពិតដែរឬទេដែលថា ពីដំបូងនោះលោកគិតថា ភាគច្រើនមានតែទាហាន លន់ នល់ តែប៉ុណ្ណោះ ដែលត្រូវបានគេឃុំនៅផ្សារដីក្រែង ក្រោយមកទេទើបលោកចាំថាក៏មានការឃុំខ្លួនមន្ត្រីរដ្ឋការ លន់ នល់ ផងដែរ តើអ៊ីចឹងដែរឬទេ?

[១១:៤៣:៥៤]

**លោក ប៉េជុយ ជីបសែ៖**

**ឆ៖** ចំពោះសំណួរដែលលោកសួរអំពីថា តើវាមានការឃុំខ្លួនទាហាន លន់ នល់ ឬមួយក៏មានមន្ត្រីរដ្ឋការរបស់ លន់ នល់ មកនៅកន្លែងហ្នឹង គឺថាខ្ញុំវាមិនច្បាស់លាស់ដែរ ប៉ុន្តែថាពិតប្រាកដគឺជាពួកមេទាហាន លន់ នល់ គឺវាច្បាស់ជាង។ ត្រង់ថាអាអ្នករដ្ឋការនោះ គឺថាខ្ញុំឮសួរពីប្រជាជនទេដែលប្រាប់ ប៉ុន្តែត្រង់ថាមានពិតប្រាកដ ឬយ៉ាងម៉េច គឺខ្ញុំក៏ឮតែពីពាក្យប្រជាជន។ ដូច្នេះគឺខ្ញុំឆ្លើយអស់ប៉ុណ្ណឹងឯង។

**ស៖** តើលោកនៅចាំទេ ថាលោកបានឆ្លើយប្រាប់អ្នកស៊ើបអង្កេត ពីដំបូងនោះលោកឆ្លើយថា

"តាមលោកដឹង គឺមិនមានមន្ត្រីរដ្ឋការដែលត្រូវបានគេឃុំខ្លួននៅផ្សារជីក្រែងនោះទេ។ តើលោកចាំទេមុនដំបូងប្រាប់គេអ៊ីចឹង?

**ឆ៖** បាទ គឺលោកនិយាយហ្នឹងគឺច្បាស់ហើយ គឺខ្ញុំៗបានប្រាប់ថា លើកមុនគឺជា ខាងគឺពួកទាហាន លន់ នល់ ទេ គឺខ្ញុំបាននិយាយដូច្នោះមែន។

[១១:៤៥:៤០]

**ស៖** ពីដំបូង លោកបានប្រាប់អ្នកស៊ើបអង្កេត ចៅក្រមស៊ើបអង្កេតថា "តាមលោកដឹង ពីដំបូងគឺមិនមានមន្ត្រីរដ្ឋការ លន់ នល់ ដែលត្រូវបានគេឃុំខ្លួននៅជីក្រែងនោះទេ"។ នៅក្នុងការផ្តល់ចម្លើយរបស់លោកនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត និងនៅចំពោះមុខអង្គជំនុំជម្រះនេះ គឺលោកបាននិយាយជាហូរហែ អំពីមន្ត្រីរដ្ឋការ លន់ នល់ ដែលត្រូវបានគេឃុំខ្លួននៅផ្សារជីក្រែង។ ខ្ញុំចង់សុំសួរលោកថា ហេតុអ្វីពីដំបូងលោកបានប្រាប់អ្នកស៊ើបអង្កេតរបស់ចៅក្រមស៊ើបអង្កេតថា ពីដំបូងនោះគឺលោកដឹងថា អត់មានទេ អត់មានការឃុំខ្លួនមន្ត្រីរដ្ឋការ លន់ នល់ ទេ មានតែឃុំខ្លួនទាហាន លន់ នល់ប៉ុណ្ណោះ។ ហេតុអ្វីលោកប្រាប់ដូច្នេះ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

ការជំទាស់របស់ខ្ញុំនោះគឺថា សាក្សីនេះនិយាយមិនត្រឹមត្រូវទៅលើសម្តីរបស់សាក្សី ដែលគាត់បានឆ្លើយ គឺសាក្សី គឺមិនមែនឆ្លើយថា គ្មានមន្ត្រីរដ្ឋការឃុំខ្លួននោះទេ គឺគាត់ថា មិនមានវត្តមានមន្ត្រីយោធាតែប៉ុណ្ណោះ។ ដូច្នេះ ហើយមេធាវីការពារក្តីគឺលើកឡើងសម្តីរបស់សាក្សីខុសនោះទេ។

[១១:៤៧:១៩]

**លោក ហ្សាស្តេ ប៉ោ៖**

សំណួររបស់ខ្ញុំនោះគឺថា ខ្ញុំអាចរៀបចំឡើងវិញបាន។

**សួរដោយលោក ហ្សាស្តេ ប៉ោ៖**

**ស៖** តើត្រឹមត្រូវដែរឬទេ លោកសាក្សី តាមលោក តាមការដឹងរបស់លោក -- បាទ ខ្ញុំសូមកែសំណួររបស់ខ្ញុំដើម្បីឲ្យច្បាស់។ លោកសាក្សី តើត្រឹមត្រូវដែរឬទេ ដែលលោកបានប្រាប់អ្នកស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេតថា "ពីដំបូងតាមលោកដឹងនោះគឺមិនមានមន្ត្រីរដ្ឋការត្រូវបានគេឃុំខ្លួន

នៅផ្សារជីក្រែងនោះទេ”។ តើលោកមានប្រាប់អ៊ីចឹងទេ?

**លោក ប៉េជុយ ជីបសែះ**

**ឆ៖** បាទ ចំពោះសំណួរនេះ គឺខ្ញុំឆ្លើយថា ខ្ញុំបានប្រាប់ខាងសាក្សីស៊ើបអង្កេតដូច្នោះមែន។ ក៏ប៉ុន្តែខ្ញុំចង់ឆ្លើយឲ្យច្បាស់ថា សំណួរដែលខ្ញុំឆ្លើយ ដែលមានថាមានអ្នករដ្ឋការហ្នឹងគឺ ជាចម្លើយមិនច្បាស់ទេ បើនិយាយឲ្យត្រង់ទៅកន្លែងហ្នឹងគឺ ច្បាស់លាស់គឺមានតែទាហាន មេទាហាន លន់ នល់ ហើយនិងកូនប្រពន្ធតែប៉ុណ្ណោះ ដែលជាចម្លើយត្រឹមត្រូវ។

[១១:៤៨:៤២]

**ស៖** ហេតុអ្វីបានជាលោកដឹងច្បាស់ យ៉ាងដូចម្តេចទៅបានជាដឹងថា មានតែទាហាន លន់ នល់ទេ ដែលឃុំខ្លួននៅទីនោះ?

**ឆ៖** បានជាខ្ញុំដឹងច្បាស់ ព្រោះថា ខ្ញុំស្តាប់ឮពីប្រជាជន គឺច្រើនតែនិយាយថា ជាទាហាន លន់ នល់ ដែលបានជម្លៀសពីសៀមរាបមក។ ភាគច្រើនគឺ អ្នកទាំងនោះច្រើននិយាយថា មេទាហាន លន់ នល់ និងកូនចៅបានត្រូវខ្មែរក្រហមយកមកដាក់នៅផ្សារកំពង់ក្តី។

**ស៖** ក៏ប៉ុន្តែនៅពេលដែលខ្ញុំអានកំណត់ហេតុស្តាប់ចម្លើយ ដែលលោកឆ្លើយជូនអ្នកស៊ើបអង្កេតនៃសហចៅក្រមស៊ើបអង្កេត លោកបានឆ្លើយថា ត្រង់ទំព័រលេខ 00225210, ខ្មែរគឺ 0016453 (ស៊ីក) “ក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំឃើញមានមន្ត្រីរដ្ឋការ លន់ នល់ និងទាហាន លន់ នល់ ត្រូវបានគេឃុំនៅផ្ទះថ្ម នៅក្នុងផ្សារជីក្រែងក្នុងខេត្តសៀមរាប ដែលត្រូវបានគេយាមកាមទាំងយប់ទាំងថ្ងៃ”។ គឺត្រង់កំណត់ហេតុ 00164153 ជាភាសាខ្មែរ។ ហើយនៅក្នុងពេលនេះ គឺលោកមិនដែលនិយាយថា លោកមិនដែលបានឃើញអ្នកទាំងអស់នោះទេ។ ដូច្នេះ ហេតុអ្វីបានជាលោកធ្វើការចុះហត្ថលេខា និងផ្តិតមេដៃទៅលើកំណត់ហេតុចៅក្រមស៊ើបអង្កេត ដែលពាក់ព័ន្ធទៅនឹងការឃុំខ្លួនទាហាន លន់ នល់ និងមន្ត្រីរដ្ឋការ លន់ នល់ នាពេលនោះ ដែលលោកមិនដឹងច្បាស់ផងនោះ?

**ឆ៖** ចំពោះខ្ញុំការឆ្លើយហ្នឹងគឺថា នៅ ខ្ញុំសូមប្រាប់ថា វានៅតែក្នុងការស្រពេចស្រពិលរបស់ខ្ញុំដែរគឺពីព្រោះខ្ញុំស្តាប់តពីគេ គឺជួនកាលគេនិយាយថា មានអ្នករដ្ឋការខ្លះមកដែរ ប៉ុន្តែភាគច្រើនគេនិយាយថា មេទាហាន លន់ នល់ គេជម្លៀសមកពីសៀមរាប។ ដូច្នេះ ក្នុងការឆ្លើយហ្នឹង ខ្ញុំក៏ជាពាក្យសម្តីរបស់ដែលខ្ញុំស្តាប់បានពីអ្នកស្រុកទេ បានជាខ្ញុំឆ្លើយដូច្នេះ ហើយនិងផ្តិតមេដៃទៅ។

[១១:៥២:១២]

**ស៖** សូមអរគុណ។ តើលោកមានដែលធ្លាប់ចងក្រង ឬក៏រៀបចំសរសេរជាកំណត់ហេតុ អំពីបទពិសោធន៍របស់លោក ដែលលោកធ្វើការ ឬក៏ធ្លាប់ឆ្លងកាត់នៅក្នុងរបបខ្មែរក្រហមដែរឬទេ? ដើម្បីឱ្យធ្វើការកត់ត្រាទុកនូវការចងចាំរបស់លោកក្នុងកំណត់ហេតុ តើលោកធ្លាប់មានដែលរៀបចំអីចឹងទេ?

**ឆ៖** បាទ ក្នុងការចងក្រងនេះគឺ ខ្ញុំមិនទាន់បានចងក្រងឱ្យមានជាការចងចាំ ឬមួយក៏ទុកសម្រាប់ជនសាក្រោយគឺនៅទាំងអស់ គឺនិយាយតែផ្ទាល់មាត់តែម្តង មិនទាន់ចងក្រងទេ។

**ស៖** នៅពេលដែលលោកនិយាយប្រាប់ប្រជាជនផ្សេងថា អំពីបទពិសោធន៍របស់លោក ដែលធ្លាប់ឆ្លងកាត់ តើអ្នកផ្សេងមានដែលធ្លាប់ប្រាប់លោក អំពីបទពិសោធន៍ដែលគេឆ្លងកាត់ឱ្យលោកបានដឹងវិញដែរឬទេ?

**ឆ៖** ចំពោះអ្នកផ្សេងដែលប្រាប់មកលើរូបខ្ញុំហ្នឹង ក៏គេមិនដែលនិយាយពីរឿងបទពិសោធន៍អ្វីប្រាប់រូបខ្ញុំដែរ គឺមិនដែលបានជួបនូវការនិយាយរបស់គេ ពីរឿងបទពិសោធន៍អ្វីទេ។

**ស៖** ដើម្បីបញ្ជាក់ឱ្យបានច្បាស់ តើលោកបាននិយាយថា នៅពេលដែលលោកនិយាយជាមួយគេផ្សេងនោះ អំពីសម័យខ្មែរក្រហម អ្នកផ្សេងដែលលោកនិយាយជាមួយហ្នឹង គឺគេមិនដែលធ្លាប់និយាយប្រាប់លោកវិញ អំពីបទពិសោធន៍ដែលពួកគាត់ធ្លាប់ឆ្លងកាត់ក្នុងសម័យខ្មែរក្រហមនោះទេ តើអីចឹងដែរឬទេ លោកបានឆ្លើយអីចឹង?

[១១:៥៤:៣៣]

**ឆ៖** បាទ ខ្ញុំបានឆ្លើយដូច្នោះមែន ព្រោះថាមិនដែលបាន គេមិនដែលបានប្រាប់ដល់ខ្ញុំនូវបទពិសោធន៍អ្វីទាំងអស់។ ដូច្នេះហើយ ខ្ញុំមិនបានដឹងនូវបទពិសោធន៍ទាំងនេះទេ។ ដូច្នេះ ខ្ញុំក៏ឆ្លើយបានតែប៉ុណ្ណឹង។

**ស៖** សូមអរគុណ។ ដើម្បីឱ្យខ្ញុំយល់ឱ្យបានច្បាស់ ខ្ញុំដឹងថា វាលំបាកមិនអាចឱ្យលោកនោះនិយាយឱ្យបានគ្រប់ជ្រុងជ្រោយទៅលើសម័យកាលនោះទេ ហើយលោកក៏មិនចាំគ្រប់ជ្រុងជ្រោយផងដែរ ហើយខ្ញុំក៏មិនចង់ឱ្យលោកនោះយល់ឃើញថា អ្វីធ្វើនេះនោះវាងាយពេកសម្រាប់លោក គឺខ្ញុំដឹងថាមានការលំបាកសម្រាប់លោក។ ខ្ញុំមានសំណួរបន្តទៀត ដែលចង់សួរទៅកាន់លោក។ កាលពីថ្ងៃចន្ទសហព្រះរាជអាជ្ញាបានសួរលោក អំពីការសម្ភាសដែលលោកបានផ្តល់ការសម្ភាសទៅឱ្យ ហង់រី ឡូកា។ ប្រតិចារឹកជាភាសាអង់គ្លេសបានសរសេរថា លោកបានឆ្លើយថា លោកមានទំនាក់ទំនងមួយចំនួនជាមួយនឹង ហង់រី ឡូកា តើនៅពេលដែលលោកនិយាយថា លោកមានទំនាក់ទំនងជាមួយនឹង ហង់រី

ឡូកា នោះ លោកចង់បានន័យយ៉ាងម៉េចដែរ?

[១១:៥៦:០៦]

**ឆ៖** បាទ ខ្ញុំចំពោះ និងលោក ហង់រី ឡូកា ហ្នឹងគឺ បានជួបសម្ភាសនៅហ្គ្រង់អូតែលសៀមរាប ហើយលោកក៏បានរាប់អានខ្ញុំ គឺថាលោកយកចិត្តទុកដាក់នៅក្នុងសំណួរ ដែលលោកសួរ ហើយលោកឲ្យទាំងអាសយដ្ឋាន គឺថាកាតរបស់លោក លេខទូរស័ព្ទគឺថា លោកថានឹងរាប់អានខ្ញុំ ទោះជាលោកនៅបារាំងមែន ប៉ុន្តែថា នៅតែរាប់អានខ្ញុំ។ ដូច្នេះហើយ ខ្ញុំក៏ពេញចិត្តនឹងលោក ហង់រី ឡូកា សូម្បីតែសាសន៍ផ្សេងគ្នាមែន ប៉ុន្តែថាលោកមានប្រជាប្រិយនៅក្នុងការរាប់អានរូបខ្ញុំនេះ។ ដូច្នេះហើយក៏ ខ្ញុំឮឈ្មោះលោកក៏ខ្ញុំគឺ ពេញចិត្តនឹងលោក ហង់រី ឡូកា តែម្តង។

**ស៖** ចាប់តាំងពីឆ្នាំ១៩៩១មក តើលោកធ្លាប់ជួប ធ្លាប់ឃើញលោក ហង់រី ឡូកា ទៀតដែរឬទេ?

**ឆ៖** បាទ តាំងពីឆ្នាំ១៩៩១ មក ខ្ញុំមិនដែលបានជួបលោក ហង់រី ឡូកា សោះ ហើយកាតដែលលោកទុកឲ្យខ្ញុំ ក៏ខ្ញុំធ្វើបាត់ទៅទៀត។ ដូច្នេះហើយរាល់ទំនាក់ទំនងផ្សេង គឺមិនដែលជួបទេ រហូតដល់ឆ្នាំ ២០១២ នេះគឺ បែកគ្នារហូត។

**ស៖** តើលោកចាប់ពីឆ្នាំ១៩៩១ មក ធ្លាប់ជជែកនិយាយជាមួយគាត់តាមទូរស័ព្ទដែរឬទេ?

**ឆ៖** អត់ដែលបាន -- ខ្ញុំមិនដែលបានជជែកជាមួយលោក ហង់រី ឡូកា តាមទូរស័ព្ទទេ ដោយខ្ញុំធ្វើបាត់លេខទូរស័ព្ទរបស់លោក។

**ស៖** នៅពេលដែល ហង់រី ឡូកា បានផ្តល់កិច្ចសម្ភាសន៍ដល់លោក តើគាត់នោះមានបានផ្តល់កំណត់ហេតុ ឬក៏កំណត់ត្រាមួយច្បាប់ ដែលគាត់រៀបចំនោះ ផ្តល់ជូនទៅឲ្យលោកដែរឬទេ?

**ឆ៖** បាទ នៅពេលដែលគាត់បានសាកសួររួចហើយ នៅឆ្នាំ១៩៩១ នោះគឺ ពេលបែកគ្នាលោកក៏អត់បានឲ្យកំណត់ហេតុអ្វីមកដល់ខ្ញុំទេ គឺគ្មានកំណត់ហេតុអ្វីដែលលោកថា ឲ្យតម្កល់ទុកទេ ឲ្យតែកាតមួយ ដែលជាអាសយដ្ឋានរបស់លោក។

[១១:៥៩:២៥]

**ស៖** នៅពេលដែលអ្នកស៊ើបអង្កេត នៃការិយាល័យចៅក្រមស៊ើបអង្កេតទៅស្តាប់ចម្លើយលោក តើលោកមានបានប្រាប់ពួកគាត់ ថាគេផ្សេងនោះបានដាក់សម្ពាធឲ្យលោកនេះ ឆ្លើយហ្នឹងផ្សេងតាមទៅគេទៅវិញទេ។ តើគេមានដាក់សម្ពាធដល់លោកដែរឬទេ?

**ឆ៖** បាទ ចំពោះការដាក់សម្ពាធគឺគ្មានទេ គឺអត់មានទាល់តែសោះ គឺគេថាតាំងពីលោក ហង់រី ឡូកា ក៏លោកមិនដែលថាឲ្យខ្ញុំត្រូវឆ្លើយដូច្នេះ ដូច្នោះដែរ គឺថា លោកឲ្យឆ្លើយតែការពិត ឃើញជាក់ស្តែងតែម្តង ទាំងសហាស៊ើបអង្កេតក៏មិនដែលមានបង្ខំរូបខ្ញុំ ឲ្យឆ្លើយតាមការណែនាំរបស់គេដែរ គឺឆ្លើយទៅតាមការពិតជាក់ស្តែង។

**ស៖** គឺខ្ញុំសូមអធ្យាស្រ័យ ខ្ញុំមិនមែនចង់សំដៅ មានន័យថាលោក ហង់រី ឡូកា នោះធ្លាប់ដាក់សម្ពាធលើលោកនោះទេ ខ្ញុំមិនចង់សួរដូច្នោះនោះទេ។ សំណួររបស់ខ្ញុំគឺចង់សួរដូច្នេះ ខ្ញុំចង់សួរថា តើលោកមានដែរធ្លាប់ប្រាប់អ្នកស៊ើបអង្កេតថា មានអាជ្ញាធរណាមួយផ្សេងនោះបានបង្ខំលោកឲ្យនិយាយចំណុចណាមួយជាក់លាក់ទៅតាមគេដែរឬទេ?

[១២:០១:២០]

**ឆ៖** បាទ ដែលចំពោះសំណួរ--

**ប្រធានអង្គជំនុំ៖**

មិនបាច់ឆ្លើយតបទេ! សំណួរនេះមិនពាក់ព័ន្ធទេ។ មិនមានមូលដ្ឋានព័ត៌មានអីមកនាំឲ្យសំណួរបែបនេះទេ។

លោកមេធាវីអាចបង្ហាញបានទេ តើលោកត្រូវការពេលវេលាប៉ុន្មានទៀត ក្នុងការសួរសំណួរសាក្សីរូបនេះ? ឥឡូវនេះដល់ម៉ោង១២ហើយ ពេលវេលាសម្រាប់មេធាវីការពារក្តីទាំងបីក្រុមដូចជាចប់អស់ហើយ ត្រូវអស់នៅពេលនេះហើយ។ ជៀសវាងយើងបំភ័ន្តនៃបញ្ហាពេលវេលានេះ នាំឲ្យមានការចម្រូងចម្រាសគ្នា នៅក្នុងការកំណត់កាលបរិច្ឆេទក្នុងការសួរដេញដោលចំពោះសាក្សី ដោយសារយើងអំមិញ អត់បានសួរទៅមេធាវីពីរក្រុមទៀតទេ ថាតើគាត់ត្រូវការពេលវេលាសួរដេញដោលសាក្សីរូបនេះដែរឬទេ?

**លោក ហ្សាស្តេី ប៉ោ៖**

សូមអរគុណលោកប្រធាន ខាងក្រុមមេធាវី នួន ជា នោះគឺគាត់ -- ខាងខ្ញុំហ្នឹងត្រូវការ២០នាទី ហើយខាងក្រុមមេធាវីការពារក្តី អៀង សារី គឺត្រូវការមិនលើសពី១០នាទី ហើយក្រុមមេធាវីលោក ខៀវ សំផន គឺគាត់មិនត្រូវការពេលវេលា ដើម្បីសួរសំណួរនោះទេ។ ដូច្នេះហើយ គឺយើងខ្ញុំត្រូវការសរុបទៅប្រហែលជា៣០នាទីទៀត ក្រោយពេលវេលាអាហារ។

[១២:០២:៥០]

*(ចៅក្រមពិភាក្សាគ្នា)*

[១២:០៣:៥៨]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើនណាស់ ហើយឥឡូវនេះដោយសារពេលវេលាក៏សមល្មមសម្រាក ដើម្បីពិសាថ្ងៃត្រង់ហើយ។ ប៉ុន្តែអំមិញហ្នឹង គឺមានបញ្ហាដោយសារការកំណត់ពេលវេលាក្នុងធ្វើសវនាការនេះ គឺបានលើសពីដែនកំណត់ នៃអង្គជំនុំជម្រះកំណត់ធ្វើសវនាការសម្រាប់ភាគីនីមួយៗ គឺមួយពេលនៃដំណើរការសវនាការ។ ហើយឥឡូវនេះដល់ពេលពេញមួយព្រឹកហើយ ហើយសួរមិនទាន់អស់ទៀត ហើយគាត់ត្រូវពេលវេលាបន្ថែម ដោយសារអង្គជំនុំជម្រះស្តាប់សំណួរទៅ មួយចំនួនគឺសំណួរមិនសូវពាក់ព័ន្ធផ្ទាល់ទៅនឹងអង្គហេតុ ដែលអង្គជំនុំជម្រះបានណែនាំឱ្យមានការពិភាក្សាដេញ ដោលចំពោះសាក្សីរូបនេះ។ ដូច្នេះអង្គជំនុំជម្រះកំណត់បន្ថែមជូនទៅសាក្សី -- ទៅក្រុមមេធាវីការពារក្តីលោក នួន ជា ១០មីនុតក្នុងការសួរសាក្សីរូបនេះនៅរសៀលនេះ ក្រោយពេលអាហារថ្ងៃត្រង់។

[១២:០៥:០៥]

**លោក ហ្សាស្តេី ប៉ោះ៖**

លោកប្រធាន ប្រសិនបើខ្ញុំសូមឆ្លើយតបនោះ គឺ--

**ប្រធានអង្គជំនុំ៖**

អត់ឱ្យឆ្លើយតបផង ហើយយើងបានសម្រេចរួចហើយ ពីព្រោះវាមានបញ្ហា។ សំណួរអំមិញលោកប្រើប្រាស់ពេលវេលា វាសំណួរផ្សេង យើងបានសម្រេចរួចហើយ។

ឥឡូវនេះដល់ពេលសម្រាកដើម្បីពិសាថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកដើម្បីពិសាថ្ងៃត្រង់ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សីនិងអ្នកជំនាញដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលសម្រាកពិសាថ្ងៃត្រង់ ព្រមជាមួយនឹងមេធាវីប្រឹក្សារបស់គាត់ផងដែរ។

អនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់កន្លែងបន្ទប់រង់ចាំនៅខាងក្រោមសាលសវនាការនេះ ហើយនិងឱ្យនាំខ្លួនគាត់ឡើងត្រឡប់មកកាន់បន្ទប់សវនាការនេះវិញនៅរសៀលនេះឱ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០៦ នាទី ដល់ម៉ោង ១៣:៣៣នាទី)*

[១៣:៣៣:៣៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយនិងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

**កញ្ញា អង់តា ហ្គីសសេ៖**

ជម្រាបសួរលោកប្រធាន ជម្រាបសួរលោក លោកស្រីចៅក្រម។ លោកប្រធាន ខ្ញុំសូមការអនុញ្ញាត ដើម្បីសុំការបំភ្លឺពាក់ព័ន្ធទៅនឹងសេចក្តីសម្រេចរបស់លោកប្រធានអម្បាញ់មិញនេះ។ តើលោកប្រធានអនុញ្ញាតដែរឬទេ?

[១៣:៣៤:៣២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ជាបឋមខ្ញុំសូមបញ្ជាក់ថា ខាងមេធាវី ខៀវ សំផន យើងមិនមានសំណួរដើម្បីចោទសួរសាក្សីរូបនេះទេ ក៏ប៉ុន្តែពាក់ព័ន្ធទៅនឹងការគណនាពេលវេលាសម្រាប់ការបែងចែករវាងមេធាវីការពារក្តីនោះ ខ្ញុំគិតថាមានបញ្ហាចោទឡើងសម្រាប់នាពេលអនាគត។ ដូច្នេះហើយបានជាខ្ញុំចង់បានការបំភ្លឺពីអង្គជំនុំជម្រះពាក់ព័ន្ធទៅនឹងការបែងចែកពេលវេលា។ នៅពេលសាក្សីរូបនេះត្រូវបានចោទសួរដោយសហព្រះរាជអាជ្ញា និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំគិតថាគាត់ចាប់ផ្តើមសួរពេលព្រឹក ចុងពេលព្រឹក ថ្ងៃចន្ទ ហើយពេលរសៀលពេលមួយរសៀលថ្ងៃចន្ទទៀត។ ហើយដូច្នេះនៅពេលដែលគណនានោះទៅ ខ្ញុំគិតថាចំពោះខាងមេធាវីការពារក្តី គឺយើងមានតែប្រហែលជា២ម៉ោង

តែប៉ុណ្ណោះ។ ដូច្នេះ ខ្ញុំគិតថាពីដំបូងមក គឺមានការគ្រោងទុករយៈពេលមួយពេលសម្រាប់ខាងសហព្រះរាជអាជ្ញា ដើមបណ្តឹង ហើយនិងមួយពេលសម្រាប់ខាងមេធាវីការពារក្តី។ ដូច្នេះ យើងឃើញថាសហព្រះរាជអាជ្ញា និងមេធាវីការ -- និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីមានពេលច្រើន ហើយលោកចៅក្រម ឡាវ៉ែន៍ ក៏បានយកពេលវេលារបស់ខាងមេធាវីការពារក្តីដើម្បីចោទសួរសាក្សីនោះទៀត។

[១៣:៣៦:១៣]

ដូច្នេះ សម្រាប់ថ្ងៃនេះ និងសម្រាប់ថ្ងៃក្រោយនាពេលអនាគតនោះ គឺថាសូមឲ្យមានសមភាពរវាងភាគីទាំងអស់។ ដូច្នេះខ្ញុំសូមឲ្យអង្គជំនុំជម្រះវិនិច្ឆ័យទៅលើសំណួរពាក់ព័ន្ធ ហើយពាក់ព័ន្ធទៅនឹងការបែងចែកពេលវេលានេះ សូមឲ្យមានការយុត្តិធម៌រវាងភាគីទាំងអស់។ ខ្ញុំលើកឡើងនូវការកត់សម្គាល់បែបនេះ ពីព្រោះខ្ញុំឃើញថាការសម្រេចរបស់លោកប្រធាននោះ គឺពាក់ព័ន្ធទៅនឹងការគណនាពេលវេលានោះ គឺថាវាមិនមានសមភាពរវាងភាគីនោះទេ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

**លោក ខេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមកត់ត្រាដើម្បីជាប្រតិចារឹក គឺថានៅពេលព្រឹក គឺថាពេលព្រឹកមានពេលវែងជាងពេលរសៀល១ -- កន្លះម៉ោង។ ដូច្នេះការដែលសួរដោយចៅក្រម ឡាវ៉ែន៍ គឺនៅតែចំណាយពេល២ម៉ោង ហើយការរសៀលថ្ងៃចន្ទ ហ្នឹង យើងត្រូវការ -- យើងចំណាយពេល២ម៉ោង។ ដូច្នេះជាការមិនត្រឹមត្រូវទេ ដែលយើងលើកឡើងមកនិយាយដូចដែលមេធាវីការពារក្តីលើកឡើងដូច្នេះនោះ។ ហើយខ្ញុំក៏កត់សម្គាល់ផងដែរថា មេធាវីខាង នួន ជា បានប្រើប្រាស់ពេលវេលាជិតកន្លះម៉ោងដើម្បីធ្វើការសួរអំពីការសម្លាប់ទៅលើការសម្លាប់មនុស្សនៅមន្ទីរសុន្តិសុខ។ ហើយពួកគាត់មិនមែនប្រើប្រាស់ត្រឹមតែពីរដងទេ គឺគាត់ស្នើសុំដល់ទៅបីដងនូវសំណើសុំដដែលៗទៅអង្គជំនុំជម្រះ។ នេះគឺជាអ្វីដែលខ្ញុំសូមធ្វើការកត់សម្គាល់។ សូមអរគុណ។

[១៣:៣៧:៥១]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយអង្គជំនុំជម្រះសូមជម្រាបជូនភាគីថា យើងមិនបានយកការវាស់វែងឲ្យបានដាច់ណាត់ សូម្បីតែលើស ឬខ្វះ១នាទី រវាងភាគីទាំងសងខាង ដូចជាមិនមែនទេ។ យើងធ្វើ

សវនាការនេះ នៅជាមួយគ្នាក្នុងការចូលរួមដំណើរការនេះជិតមួយឆ្នាំកន្លងមកហើយ។ មូលហេតុដែលអង្គជំនុំជម្រះបានកត់សម្គាល់ ហើយកាត់បន្ថយមិនតាមសំណើ អង្គជំនុំជម្រះកត់សម្គាល់ឃើញថាមានសំណួរមួយចំនួនដែលសួរទៅវាសំណួរមិនពាក់ព័ន្ធ។ ប្រសិនបើសំណួរសំខាន់ ហើយសុទ្ធតែពាក់ព័ន្ធទាំងអស់ហ្នឹង គឺអង្គជំនុំជម្រះតែងតែផ្តល់ការពន្យារពេល៥មីនុត ឬ១០មីនុត ទៅតាមស្ថានភាពសមស្របយ៉ាងច្រើនបំផុត យើងគ្រាន់តែរំឭកអំពីពេលវេលា ធ្វើយ៉ាងណាក្នុងន័យជំរុញល្បឿននៃកិច្ចដំណើរការពិភាក្សាដេញដោលរបស់យើងឲ្យបានឆាប់រហ័ស តាមតែលទ្ធភាពអាចធ្វើទៅបានប៉ុណ្ណោះ។

[១៣:៣៨:៥៣]

ដោយព្រឹកមិញនេះ យើងកត់សម្គាល់ឃើញថា មានមួយ -- សំណួរខ្លះវាមិនពាក់ព័ន្ធ ឬវាមិនសក្តានុពលនៅក្នុងការប្រើប្រាស់ក្នុងការសួរដូចជាទំនាក់ទំនងរវាងសាក្សី ជាមួយនឹង ហង់រី ឡូកាជាដើម។ សួរពីរឿងការជ្រៀតជ្រែក ឬក៏ឥទ្ធិពលពីរដ្ឋអំណាច ពីអ្នកនេះ អ្នកនោះជាដើម ដែលមិនមានព័ត៏មាន ប្រភពព័ត៏មានអីដែលវាជាក់ច្បាស់ ដែលនាំឲ្យមានការតាំងសំណួរបែបនេះ។ ហើយសំណួរដែលយើងបានកំណត់ឲ្យសួរ គឺសួរដេញដោលអំពីសារធាតុ សំណួរសារធាតុដែលពាក់ព័ន្ធជាមួយនឹងអង្គហេតុដែលអង្គជំនុំជម្រះកំណត់ឲ្យធ្វើសវនាការ។ ហើយសាក្សីរូបនេះ អង្គជំនុំជម្រះបានរំឭកភាគីតាំងពីដើមទីថា សាក្សីនេះ គឺអាចសួរដេញដោលនៅក្នុងក្របខ័ណ្ឌនៃអង្គហេតុនៃការអនុវត្តគោលនយោបាយនៃជម្លៀសដំណាក់កាលទី១ ជាបញ្ហាចម្បង ដោយសារអង្គហេតុនៃមន្ទីរសន្តិសុខពង្រហ្នឹងមិនមែនជាអង្គហេតុដែលមាននៅក្នុងដីកាដំណោះស្រាយទេ។ ទី២ គឺនៅក្នុងចម្លើយហ្នឹង យើងយល់ថាវាមានតម្លៃ ដែលគួរតែសួរបំពេញបន្ថែមនៅលើរចនាសម្ព័ន្ធរដ្ឋបាលមូលដ្ឋាន។ នេះយើងចងចាំថាយើងបានរំឭក បញ្ហានេះ ព្រោះនៅក្នុងថៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងក៏បានជជែក ពិភាក្សាអំពីសារៈសំខាន់នៃការកោះហៅសាក្សីរូបនេះមកផ្តល់សក្ខីកម្ម ឬការមិនហៅដែរ ទើបយើងក្តាប់នូវបញ្ហានេះបាន។ គ្រាន់ តែប៉ុណ្ណឹងទេ យើងមិនដែលបានវាស់សូម្បីតែ ៥នាទី, ១០នាទីហ្នឹងទេ!

សូមអញ្ជើញលោកមេធាវី! មិនមែនមូលហេតុអីដែលថាយើងធ្វើគ្រាន់តែបង្ហាញក្នុងន័យថា ចង់ថាយើងហ្នឹងមិនយុត្តិធម៌ មិនស្មើភាពភាគីនោះទេ។ សំខាន់គឺការ -- បច្ចេកទេសក្នុងការសួរ ពីព្រោះពេលខ្លះយើងក៏វាហួសពីលទ្ធភាពដែលយើងយល់បានអំពីគិត អំពីបច្ចេកទេសក្នុងការសួរដែរ។ ប៉ុន្តែយើងព្យាយាមអត់ធ្មត់ ជៀសវាងបញ្ហាប្រឈមដើម្បីឲ្យដំណើរការប្រព្រឹត្តទៅវារលូន ឲ្យបានចប់ទៅ។

[១៣:៤១:១៤]

**លោក ហ្សាស្តេី ប៉ោះ**

សូមអរគុណលោកប្រធាន។

មុនពេលដែលខ្ញុំបន្តការចោទសួរ ខ្ញុំគ្រាន់តែចង់បញ្ជាក់ឲ្យបានច្បាស់ គឺថាក្រុមមេធាវី នួន ជា ត្រូវការពេល១០នាទី ហើយក្រុម អៀង សារី ត្រូវការពេល១០នាទីបន្ថែម ដើម្បីចោទសួរសំណួរ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានសម្រេចរួចព្រឹកមិញរួចហើយ បញ្ហាដដែល។ នេះជាការសំណួរមួយដែលវាមិនសមស្របទេ វាត្រូវការពេលវេលានៅក្នុងលក្ខខណ្ឌដែលវាមិនគួរមាន ព្រោះអង្គជំនុំជម្រះបានសម្រេចព្រឹកមិញរួចហើយ។

[១៣:៤២:០៥]

**លោក ហ្សាស្តេី ប៉ោះ**

យើងព្យាយាមអត់ធ្មត់ទៅលើការងារទាំងអស់នេះ ហើយខ្ញុំមានសំណួរបន្ថែមខ្លះដើម្បីសួរទៅលើសាក្សី។ ក៏ប៉ុន្តែខ្ញុំសូមចាប់ផ្តើមដោយធ្វើសំណើឲ្យមានការបំភ្លឺបញ្ជាក់ដោយសង្ខេបមួយមុនពេលឈប់សម្រាក។ ខ្ញុំបានសួរសាក្សីថាតើគាត់មានប្រាប់អ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត អំពីសម្ពាធដែលបានដាក់មកលើគាត់ ដោយអាជ្ញាធរ។ ហើយសំណួរនេះត្រូវបានចាត់ទុកថា មិនពាក់ព័ន្ធដោយលោកប្រធាន។

ដូច្នេះ ខ្ញុំអាចនឹងរៀបឃ្លាសា -- ខ្ញុំនឹងមិនចោទសួរប្រសិនបើលោកប្រធានអាចពន្យល់ថា តើហេតុអ្វីបានជាវាមិនពាក់ព័ន្ធ? ហើយថាតើហេតុអ្វីបានជាសាក្សីមិនទទួលបានសម្ពាធ ឬក៏មិនទទួលសម្ពាធ? ហើយថាតើក្នុងឱកាសណាមួយដែលខ្ញុំអាចសាកសួរ ឬក៏អាចធ្វើការដេញដោលអំពីបញ្ហាទាំងអស់នេះ? សូមលោកប្រធានមេត្តាជួយបកស្រាយ។

[១៣:៤៣:១៤]

**ប្រធានអង្គជំនុំ៖**

នៅក្នុងនីតិវិធីនៃការសួរដេញដោលតាំងពីដើម រហូតដល់ចប់ មិនមានប្រភពព័ត៌មានណាមួយថា សាក្សីនេះទទួលនូវឥទ្ធិពល ឬសម្ពាធពីអាជ្ញាធរណាមួយទេ។ ហើយនៅក្នុងកំណត់ហេតុនៃការស្តាប់សក្ខីកម្មរបស់គាត់ ដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតក៏គ្មានដែរ។ អ៊ីចឹងហើយបានជា

យើងមិនឲ្យសាក្សីរូបនេះឆ្លើយ ពីព្រោះជាសំណួរគ្មានមូលដ្ឋានទេ។

**លោក ហ្សាស្តី ប៉ោះ**

សូមអរគុណលោកប្រធានដែលបានបញ្ជាក់បំភ្លឺ ខ្ញុំយល់ស្របជាមួយលោកប្រធាន ដោយសារតែមិនមានការបញ្ជាក់នៅក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សីរបស់ថាមិន -- របស់សាក្សីរូបនេះដែលថាបញ្ជាក់អំពីមានការសម្លាធ ឬក៏ការគាបសង្កត់។ ប៉ុន្តែនៅក្នុងការ -- នៅក្នុងខ្សែអាត់សំឡេងគឺ--

**សួរដោយលោក ហ្សាស្តី ប៉ោះ**

**ស៖** ហេតុដូច្នេះសំណួររបស់ខ្ញុំដែលចង់សួរទៅលោកសាក្សី គឺថាតើលោកសាក្សីមានបាននិយាយប្រាប់ទៅដល់អ្នកស៊ើបអង្កេតថា និយាយអំពី តាឈុន ដែរឬទេ ជាមួយអ្នកស៊ើបអង្កេត?

[១៣:៤៤:៣៥]

**លោក ប៉េជុយ ជីបសែ៖**

**ឆ៖** បាទ ចំពោះឈ្មោះហ្នឹង គឺខ្ញុំមិនបាននិយាយទេ គឺ តាឈុន ហ្នឹងគឺខ្ញុំបដិសេធហើយ គឺមិនបាននិយាយប្រាប់ទៅខាងអង្គ -- ខាងស៊ើបអង្កេតនេះទេ គឺអត់បាននិយាយ។

**ស៖** តើលោកមាននិយាយអំពីអាជ្ញាធរស្រុក ឬក៏មន្ត្រីស្រុកដែលលោកបានទៅលេងផ្ទះគាត់នោះ។ តើលោកមាននិយាយពីមន្ត្រីស្រុក ឬក៏អាជ្ញាធរស្រុកណាមួយ ដែលលោកធ្លាប់ទៅលេងផ្ទះគាត់នោះដែរទេ?

**ឆ៖** ចំពោះការទៅលេងស្រុកអីក៏ដោយ ក៏ខ្ញុំ គឺមិនបាននិយាយអ្វីទាំងអស់ គឺចំពោះរឿងអ្វី គឺខ្ញុំមិននិយាយទាក់ទងទៅនឹងរឿងទាំងអស់នេះទេ គឺមិនដែលនិយាយសោះ។

[១៣:៤៥:៥៣]

**លោក ហ្សាស្តី ប៉ោះ**

ប៉ុន្តែឥឡូវនេះ គឺមានបញ្ហាមួយទៀតហើយ គឺថាជនជាតិហូឡង់ គាត់កំពុងតែព្យាយាមនិយាយភាសាខ្មែរ។ ដូច្នេះ ខ្ញុំស្នើឲ្យលោក អរុណ ដែលជនជាតិកម្ពុជាផងដែរ ឲ្យអានឈ្មោះ ដើម្បីកុំឲ្យលោកយល់ច្រឡំ ដើម្បីឲ្យដឹងច្បាស់ ថាតើយើងកំពុងតែនិយាយឈ្មោះអ្នកណាគេនៅពេលនេះ។ សូមអញ្ជើញលោក អរុណ។

**លោក សុន អរុណ៖**

ឈ្មោះ ឆុង១។

**សួរដោយលោក ហ្សាស្តេី ប៉ៅ៖**

**ស៖** ដូច្នេះ សំណួររបស់ខ្ញុំជាថ្មីម្តងទៀត គឺថាតើលោកមានបាននិយាយជាមួយអ្នកស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត អំពីបុគ្គលម្នាក់ឈ្មោះ ឆុង នេះឬទេ?

**លោក ប៉េជុយ ដឹបសែ៖**

**ឆ៖** ខ្ញុំចង់និយាយអំពីឈ្មោះ ឆុង នេះ គឺគាត់ជាអ្នកតាំងពីឆ្នាំ១៩៩១ ជាមួយ ហង់រី ឡូកា គឺគាត់បាននាំឲ្យខ្ញុំទៅជួបលោក ហង់រី ឡូកា ទេ ហើយឈ្មោះ ឆុង នេះ ចំពោះខាងក្រុមស៊ើបអង្កេតក្រោយនេះ គឺខ្ញុំអត់បាននិយាយប្រាប់ពីរឿងដែលគាត់ធ្វើយ៉ាងម៉េចៗអី ពីព្រោះខ្ញុំ តាំងពី ហង់រី ឡូកា សួរខ្ញុំមក ខ្ញុំក៏ភ្លេចឈ្មោះ តាឆុង ហ្នឹងទៅ។ ដូច្នេះ សូមបញ្ជាក់ថា ឈ្មោះ ឆុង នេះគឺជាអ្នកមានតាំងពីសម័យដែល ហង់រី ឡូកា បានសម្ភាសជាមួយខ្ញុំ។

**ស៖** ដូច្នេះ តើលោកមានបានប្រាប់សហចៅក្រមស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតថា លោក ឆុង បានដាក់សម្ពាធ ឬក៏គាបសង្កត់លោកឲ្យឆ្លើយសំណួរទៅតាមវិធី ឬក៏ទៅចម្លើយណាដែលគាត់ចង់បានដែរឬទេ?

[១៣:៤៨:០៥]

**ឆ៖** ចំពោះឈ្មោះ ឆុង ដែលខ្ញុំនិយាយជាមួយក្រុមស៊ើបអង្កេតនោះ គឺខ្ញុំមិនចាំៗ សោះហើយដល់ពេលហ្នឹង គឺថាមិនបាននិយាយប្រាប់ខាងក្រុមស៊ើបអង្កេត ដែលទៅស៊ើបអង្កេតក្រោយហ្នឹង គឺខ្ញុំអត់ចាំ។ មិនដឹងជាបាននិយាយ ឬក៏មិនបាននិយាយ នោះគឺសូមប្រាប់ថា ខ្ញុំភ្លេច។

**ស៖** តើលោកមានបានប្រាប់អ្នកស៊ើបអង្កេត នៃការិយាល័យសហចៅក្រមស៊ើបអង្កេតថា លោក ឆុង ហ្នឹង បានគាបសង្កត់ ឬក៏ដាក់សម្ពាធទៅលើលោកដែរឬទេ?

**ឆ៖** កន្លែងហ្នឹងខ្ញុំសូមប្រាប់លោកថា ខ្ញុំវាមិនចាំតែម្តង។ មិនដឹងជាបាននិយាយ ឬក៏មិនបាននិយាយ។ ដូច្នេះ ខ្ញុំបដិសេធថាឆ្លើយមិនរួច បាទ។

**ស៖** សូមអរគុណ។ ដូច្នេះ ខ្ញុំចង់រំឭកដល់ការចងចាំរបស់សាក្សី ដោយសូមអនុញ្ញាតចាក់នូវខ្សែអាត់សំឡេងនៃការសម្ភាសរបស់សហ -- ជាមួយសហចៅក្រមស៊ើបអង្កេត ហើយវាមានពេលតិចជាង១នាទី មានពេលមិនដល់១នាទីផង ដែលសាក្សីនិយាយអំពីលោក ឆុង ហើយនិងអំពីការដែល ឆុង បានគាបសង្កត់ទៅលើសាក្សី ហើយនេះគឺជាចំណុចល្អមួយ។ ហើយនៅពេលដែលយើងបានស្តាប់ទៅលើខ្សែអាត់រួចហើយ ពេលនោះ សាក្សីគាត់អាចនឹងបញ្ជាក់ថា ជាសំឡេងរបស់គាត់ ឬក៏មិនមែន

ហើយគាត់អាចនឹងជួយបំភ្លឺ ឬក៏ជួយបង្ហាញអំពី ថាតើគាត់ត្រូវបានគេគាបសង្កត់ ដាក់សម្ពាធ ដែរឬក៏អត់នោះ។ ហើយវានឹងជួយជាព័ត៌មានដល់អង្គជំនុំជម្រះ។ ហេតុដូច្នេះ ខ្ញុំសូមអនុញ្ញាតចាក់នូវខ្សែអាត់សំឡេងនៅក្នុងអង្គសវនាការនេះទាំងមូលតែម្តង។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

លោកប្រធាន។ ជាគោលការណ៍ យើងមិនជំទាស់ទៅលើការចាក់ខ្សែអាត់សំឡេងនោះទេ ប៉ុន្តែមេធាវីការពារក្តីបាននិយាយយោង ទៅលើហេតុការណ៍ដែលកើតតាំងពី៨១មក។ ដូច្នេះហើយខ្ញុំគិតថាវាហាក់ដូចជាមិនសូវជាពាក់ព័ន្ធ ឬក៏ពាក់ព័ន្ធតិចតួចបំផុតសម្រាប់ពេលនេះ។ ការដែលមេធាវីការពារក្តីចង់ឲ្យបង្ហាញនូវខ្សែអាត់ថតសំឡេង ជាផ្នែកមួយនៃប្រតិចារឹកនោះ វាហាក់ដូចជាជាបញ្ហាមួយ គឺថាយើងនៅទីនេះគឺ យើងទៅជាស្តាប់ខ្សែអាត់សំឡេង ហើយទៅពិចារណាថាតើសាក្សីនិយាយអំពីអ្វីហើយនេះវាគ្រាន់តែជាការចង់បង្កើត ឲ្យមានជាកំណត់ត្រានៃប្រតិចារឹកតែប៉ុណ្ណោះ។ ដូច្នេះ ខ្ញុំគិតថាវាជាបញ្ហាមួយដែលមេធាវីការពារក្តី នៅពេលនាទីចុងក្រោយបែរជាស្នើសុំ ឬក៏ទាមទារឲ្យចាក់ខ្សែអាត់សំឡេងទៅវិញ។

[១៣:៥១:២៨]

**លោក ហ្សាស្តើ ប៉ោ៖**

លោកប្រធានខ្ញុំសូមឆ្លើយដោយសង្ខេប។ ខ្សែអាត់សំឡេងត្រូវបានគេពិភាក្សាជាច្រើនដងរួចមកហើយ ដូច្នេះហើយគឺវាមិនច្បាស់លាស់ថាតើខ្សែអាត់ណាមួយដែលមាន ខ្សែអាត់ណាមួយដែលមិនមានហើយមិនដឹងថាតើវាជាចម្លើយរបស់សាក្សី ឬក៏អត់។ ដូច្នេះ យើងគ្រាន់តែចង់ឲ្យសាក្សីគាត់បញ្ជាក់ច្បាស់ថាតើគាត់បាននិយាយពីលោក ឆុង ហើយថាតើលោក ឆុង បានដាក់សម្ពាធទៅលើគាត់ ឬអត់នោះ។ ដូច្នេះ ខ្ញុំស្នើសុំអនុញ្ញាតចាក់នូវខ្សែអាត់សំឡេង។

ដូច្នេះ ខ្ញុំទទួលបាននូវការអនុញ្ញាតពីអង្គជំនុំជម្រះពីពេលមុនហើយដែលឲ្យចាក់ខ្សែអាត់សំឡេង។ ដូច្នេះ វាជាការសំខាន់ចំពោះអង្គជំនុំជម្រះសាលាដំបូង ក៏ដូចជាសាធារណៈ ដើម្បីស្តាប់នូវខ្សែអាត់ថតសំឡេង ហើយនិងដឹងអំពីការដំណើរការសម្ភាសរបស់សហចៅក្រមស៊ើបអង្កេត។ ខ្ញុំគិតថាវាមិនចំណាយពេលយូរនោះទេ ដូច្នេះខ្ញុំសូមអនុញ្ញាតបង្ហាញឲ្យមានការ ចាក់ខ្សែអាត់សំឡេងត្រឹមតែ១នាទី

ប៉ុណ្ណោះ ហើយយើងអាចដឹងអំពីបញ្ហាទាំងអស់នេះ។

ដូច្នេះ ខ្ញុំសូមអនុញ្ញាតដល់អង្គជំនុំជម្រះ មេត្តាជួយចាក់ត្រឹមតែខ្សែអាត់សំឡេងដែលមានរយៈពេលខ្លីតែប៉ុណ្ណោះ ដើម្បីនិយាយអំពីការដាក់សម្ពាធនេះ ហើយយើងនឹងបន្តទៅមុខទៀត។ ប្រសិនបើលោកប្រធានអនុញ្ញាត។ សូមលោកប្រធានមេត្តាអនុញ្ញាត។

[១៣:៥២:៥៣]

**ប្រធានអង្គជំនុំ៖**

លោកអាចបង្ហាញបានទេ ខ្សែអាត់ហ្នឹងនៅមីនុតទីប៉ុន្មាន អីទីប៉ុន្មានទៅប៉ុន្មានទៅ? ដើម្បីឲ្យជាប្រតិចារឹកផង ហើយយើងបញ្ជាទៅអ្នកខាងសោតទស្សន៍ហ្នឹងគេក្តាប់បាន ហើយចាក់ឲ្យចំផង ជៀសវាងយើងបញ្ជាទៅទទេៗ ទូទៅៗហ្នឹងមានន័យថាម៉េចទៅ?

**លោក ហ្សាស្តេី ប៉ោ៖**

គឺក្នុងនាទី ១ម៉ោង ៣៨នាទី និង៤០វិនាទី នៅក្នុងខ្សែអាត់សំឡេងជាភាសាខ្មែរ។ ហើយខ្ញុំគិតថាខាងសោតទស្សន៍គាត់មាននូវផ្នែកដែលពាក់ព័ន្ធ នូវខ្សែអាត់ដែលពាក់ព័ន្ធដើម្បីចាក់ភ្លាមៗតែម្តង លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីខាងសោតទស្សន៍ចាក់ខ្សែអាត់ថតសំឡេង តាមសំណើសុំរបស់មេធាវីអន្តរជាតិការពារក្តីលោក នួន ជា ផ្នែកដែលពាក់ព័ន្ធទៅនឹងសំណើគឺ នាទី -- ១ម៉ោង ៣៨នាទី ៤៨វិនាទី។

[១៣:៥៤:២៣]

(ការបង្ហាញឯកសារជាសំឡេង)

*"ស៖ តើលោកកមានចំណុចអីត្រូវបន្ថែមទៀតទេ ដែលខ្ញុំមិនបានសួរ? ឆ៖ ខ្ញុំក៏ និយាយទៅខ្ញុំមិនមែនថាលាក់កន្លែងណាទេ គឺថា ខ្ញុំគ្រាន់តែនិយាយប្រាប់លោកថា ដែលខ្ញុំទៅរាយការណ៍ឲ្យលោកនៅខាងសណ្ឋាគារប្រ៊ូគដ់អូតែលហ្នឹង គឺថាខាងស្រុក គេគាបសង្កត់ខ្ញុំ មិនឲ្យខ្ញុំនិយាយមិនឲ្យអស់សេចក្តីដូចនិយាយប្រាប់លោកពេលនេះទេ ហើយគាត់ថាយើង -- គាត់និយាយ នៅផ្ទះគាត់ ផ្ទះគាត់នៅសៀមរាប គាត់តាឆុងៗ ថាយើងនិយាយតែពីរឿងកន្លែងណាដែលល្អទៅបានហើយ។ គាត់និយាយអ៊ីចឹងណ៎ា ដូច្នេះហើយខ្ញុំក៏ គាត់ប្រាប់អ៊ីចុះហើយក៏ខ្ញុំទៅនិយាយនឹងលោកខាងបារាំងហ្នឹងក៏មានកម្រិត។*

*ព្រោះគាត់ទៅ ដល់ខ្ញុំនិយាយ គាត់ទៅឈរនៅកន្លែងអ៊ីចេះ! គាត់ តាឌុង នោះណា គាត់ទៅឈរដែរ ក៏ខ្ញុំគាត់ប្រាប់អ៊ីចុះហើយ មិនបាននិយាយឲ្យអស់ដូចពេលនេះទេគឺថា។ ប៉ុន្តែខ្ញុំរាយការណ៍ពេលនេះ ក៏ខ្ញុំថាការចងចាំរបស់ខ្ញុំមិនបាន១០០ភាគរយទេ គឺថាមានកន្លែងខ្លះក៏វាភ្លេចភ្លាំងខ្លះដែរ ប៉ុន្តែខ្ញុំដែលថាលោកចង់ជួបខ្ញុំថ្ងៃក្រោយទៀត ខ្ញុំនឹងរកនឹកឲ្យអស់តែម្តង។ បាទ គឺថាមិនឲ្យមាននៅសល់កន្លែងណាទេ គឺថាបញ្ជាក់ឲ្យច្បាស់ បាទ"*។

(បញ្ចប់ការបង្ហាញឯកសារសំឡេង)

[១៣:៥៦:១៣]

**លោក ហ្សាស្តើ ប៉ោ៖**

សូមអរគុណលោកប្រធាន ហើយក៏សូមអរគុណអង្គជំនុំជម្រះសាលាដំបូង ដែលបានអនុញ្ញាតឲ្យចាក់នូវខ្សែអាត់សំឡេងមួយនេះ។

**សួរដោយលោក ហ្សាស្តើ ប៉ោ៖**

**ស៖** សំណួររបស់ខ្ញុំចង់សួរលោកគឺ ចង់ឲ្យលោកធ្វើការបញ្ជាក់បំភ្លឺ លោកបាននិយាយអំពីការគាបសង្កត់ ដែល តាឌុង គាត់បានគាបសង្កត់ទៅលើលោក។ តើលោកអាចពន្យល់បានដែរឬទេ ថាតើ តាឌុង ហ្នឹងគាត់បានគាបសង្កត់លោកទៅលើអ្វីខ្លះ? តើតាមវិធីណាខ្លះ?

**លោក ប៉េជុយ ជីបសែ៖**

**ឆ៖** បាទ ដែលអម្បាញ់មិញ សម្តីអម្បាញ់នេះគឺខ្ញុំពិតជាបាននិយាយមែន ពីព្រោះ តាឌុង គាត់បានគាបសង្កត់ខ្ញុំត្រង់ថា ឲ្យរាយការណ៍ឲ្យលោក ហង់រី ឡូកា ឲ្យគឺថា កុំឲ្យអស់អ៊ីចុះមែន គឺថាសម្តីហ្នឹងគឺជាសម្តីខ្ញុំពិត។ ពីព្រោះ តាឌុង ហ្នឹង គាត់ថា បើយើងរាយការណ៍ច្រើនទៅ ខ្លាចអត់បានលុយកាក់ពីលោក ហង់រី ឡូកា គឺលោក ហង់រី ឡូកា គឺគាត់ជាជនជាតិបរទេស។ ដូច្នេះ ដើម្បីឲ្យបានប្រាក់ច្រើនទាំងឲ្យខ្ញុំផង និងគាត់ផង គាត់ឲ្យខ្ញុំ គាត់គាបសង្កត់ឲ្យខ្ញុំរាយការណ៍ដូច្នោះ។ ដូច្នេះ ខ្ញុំក៏បានប្រាប់ទៅខាងសហស៊ើបអង្កេតពិតប្រាកដមែន។ ហើយខ្ញុំពេលនោះខ្ញុំបាននិយាយ ប៉ុន្តែដល់ពេលនេះគឺថា ខ្ញុំក៏ភ្លេច។ ដូច្នេះគឺការភ្លេចភ្លាំងរបស់ខ្ញុំគឺមានច្រើន។

[១៣:៥៨:១៦]

**ស៖** សូមអរគុណ។ ដូច្នេះ អ្វីដែលបានបញ្ជាក់បំភ្លឺអស់រួចរាល់ហើយ។ ដូច្នេះ ខ្ញុំនៅសល់សំណួរចុងក្រោយតែមួយគត់ ហើយខ្ញុំគិតថា ខ្ញុំប្រហែលជានៅសល់ពេល។ ហើយបន្តទៅទៀតនេះ គឺខ្ញុំ

និយាយអំពី ស៊ីវ ហេងឌ័រ គឺជាបុគ្គលិក ដែលធ្លាប់ធ្វើការនៅការិយាល័យសហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត ហើយគាត់បានរៀបរាប់អំពីឋានានុក្រម ក៏ដូចជាកម្រិតនៃឋានៈបញ្ជា នៅថ្នាក់ស្រុកផងដែរ។ ក៏ដូចជា និយាយអំពីតួនាទីសំខាន់ៗរបស់លេខាស្រុក ដែលនិយាយអំពីការសម្លាប់នៅទូទាំងប្រទេស។

[១៣:៥៩:០០]

លោកសាក្សី លោកមិនអាចផ្ដល់អំពីការ -- ផ្ដល់សក្ខីកម្មអំពីការសម្លាប់នៅទូទាំងប្រទេស ហើយក៏ប្រហែលជាមិនអាចនិយាយអំពីការសរសេររបស់លោក ស៊ីវ ហេងឌ័រ ហើយខ្ញុំនឹងមិនសួរលោកផងដែរ អំពីការនិពន្ធរបស់លោក ស៊ីវ ហេងឌ័រ ទេ។ ប៉ុន្តែកាលពីថ្ងៃចន្ទ លោកបានបញ្ជាក់ថា ខ្ញុំសូមដកស្រង់ គឺវាមាននៅទំព័រ៩៩ គឺនៅប្រតិចារឹក៧៩ នៃភាសាខ្មែរ។ ខ្ញុំសូមដកស្រង់ "ពាក់ព័ន្ធទៅនឹងសៀវភៅកត់ត្រាចេញចូល គឺសៀវភៅកត់ត្រាចេញចូល ត្រូវនិយាយរៀបរាប់អំពីបុគ្គលនីមួយៗ ថាតើបុគ្គលនីមួយៗ ប្រព្រឹត្តធ្ងន់ ឬក៏ស្រាល ហើយថ្នាក់ស្រុកគឺជាអ្នកសម្រេចថាតើត្រូវធ្វើយ៉ាងណា ចំពោះបុគ្គលទាំងអស់នេះ ថាតើត្រូវសម្លាប់ ឬក៏ត្រូវដោះលែង ហើយនិងកំណត់អំពីរយៈពេល ដែលត្រូវឃុំឃាំងបុគ្គលរូបនោះ"។ ដូច្នេះ សំណួរដែលខ្ញុំចង់សួរលោកគឺថា តាមបទពិសោធន៍របស់លោកផ្ទាល់ ថាតើលោកធ្លាប់ជួបនូវបទពិសោធន៍បែបនេះដូចគ្នាដែរឬទេនៅថ្នាក់ស្រុក នៅថ្នាក់ស្រុក ដែលស្រុកគឺជាអ្នកសម្រេចថាតើត្រូវធ្វើបែបណាជាមួយអ្នកទោស ថាតើស្រុកគឺជាអ្នកសម្រេចថាត្រូវសម្លាប់ ឬមួយក៏ធ្វើយ៉ាងណាជាមួយអ្នកទោសដែរឬទេ? តើលោកអាចបញ្ជាក់បានដែរទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

លោកប្រធាន យើងសូមជំទាស់ទៅលើការចោទសំណួរបែបនេះ វាមិនមានហេតុផលស្របច្បាប់ណាមួយដែលមេធាវីការពារក្ដីចាប់ផ្ដើមអាននូវសម្រង់របស់លោក ស៊ីវ ហេងឌ័រ ហើយបន្ទាប់មកហើយដូចជានាំមុខ ឬក៏ជំរុញឲ្យសាក្សីផ្ដល់សក្ខីកម្មទៅតាមរបៀបនេះ របៀបនោះ គឺថាអង្គជំនុំជម្រះបានជម្រាបគាត់ច្រើនដងហើយ មិនឲ្យធ្វើបែបនេះ ឬក៏មិនឲ្យអនុវត្តបែបនេះ។

ហើយចំណុចទី២ទៀត គឺគាត់ហាក់ដូចជាលើកយកតែចំណុចល្អ ឬក៏និយាយតែមួយចំណុចមួយផ្នែកតូចរបស់សាក្សី ដែលថាគាត់ដឹងថា តើថ្នាក់ស្រុកត្រូវសម្រេច ឬក៏មិនត្រូវ។ ហើយថាតើ

ថ្នាក់ស្រុកទទួលបញ្ជាពីខាងលើ ឬក៏អត់នោះ។ អានេះគឺជាអ្វីដែលយើងគួរតែចាំ។ ហើយដោយសារតែហេតុផលទាំងពីរនេះ គឺខ្ញុំសូមជំទាស់ទៅលើការចោទសំណួរបែបនេះ។

[១៤:០១:២៨]

**លោក ហ្សាស្តើ ប៉ោះ៖**

លោកប្រធាន ខ្ញុំសូមជំទាស់ទៅលើការដែលសហព្រះរាជអាជ្ញាបានជំទាស់មកយើងខ្ញុំ បែបនេះ។ យើងសូមជំទាស់យ៉ាងខ្លាំង។ ហើយម្យ៉ាងទៀត គឺគាត់មិនបានបញ្ជាក់ថា តើគាត់ដឹង ឬមិនដឹងអំពីថ្នាក់ស្រុក។ ខ្ញុំមិនមែនលើកយកតែចំណុចល្អ ឬក៏លើកយកតែមួយចំណុចតូចណាមួយនោះទេ។ ខ្ញុំសួរគាត់អំពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់សាក្សី។ នេះគឺជាអ្វីដែលសាក្សីគួរតែផ្តល់សក្ខីកម្ម ហើយខ្ញុំដឹងថា ខាងព្រះរាជអាជ្ញាហាក់ដូចជាគ្រាន់តែសន្មតបន្ថែមទៅលើចំណេះដឹងរបស់សាក្សីតែប៉ុណ្ណោះ។

ខ្ញុំសួរសាក្សីតែអំពីចំណេះដឹងរបស់គាត់ ហើយសាក្សីគាត់អាចផ្តល់ចម្លើយដែលច្បាស់លាស់ផ្អែកទៅលើបទពិសោធន៍ផ្ទាល់ខ្លួនរបស់គាត់។ សំណួរគឺច្បាស់លាស់ គឺយើងសួរថាតើគាត់ដឹង ៗត្រឹមកម្រិតណា ហើយគាត់អាចប្រាប់យើងបានត្រឹមកម្រិតណាអំពីការប្រព្រឹត្តចំពោះសាក្សី -- ចំពោះអ្នកទោសនៅកម្រិតស្រុក។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតឲ្យសាក្សីឆ្លើយទៅលើ សំណួរដែលខ្ញុំបានចោទសួរនេះ។

[១៤:០២:៤៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:០៣:២៩]

**ប្រធានអង្គជំនុំ៖**

លោកមេធាវី លោកគប្បីរៀបចំនូវសំណួរឡើងវិញ ហើយលោកមិនគប្បីសួរសំណួរភ្ជាប់ទៅអ្វីដែលជាស្នាដៃរបស់លោក ហេដឌ័រ នោះទេ។ សួរនូវសំណួរទាំងឡាយដែលជាបទពិសោធន៍របស់សាក្សីនៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលមូលដ្ឋាន ដែលគាត់មានលទ្ធភាពដឹងផ្ទាល់ខ្លួនទៅបានហើយ ជៀសវាងអូសបន្លាយភ្ជាប់នូវបញ្ហាផ្សេងៗមក គឺគ្រាន់តែបង្កើតនូវបញ្ហាដែលនាំឲ្យមានការជំទាស់តវ៉ា ឬក៏វាពិបាកពិចារណានៅក្នុងហេតុការហេតុផលសមស្រប ឬមិនសមស្របនៃសំណួរនោះ។

សំណួរលោកគឺរៀបចំឡើងវិញ ធ្វើយ៉ាងម៉េចឲ្យសាក្សីហ្នឹង គាត់យល់អំពីសំណួរហើយជាការបញ្ជាក់បង្ហាញអំពីការយល់ដឹង ការចងចាំរបស់គាត់លើរដ្ឋអំណាចបញ្ជារបស់គណៈស្រុក របស់អាជ្ញាធរមូលដ្ឋានថ្នាក់ស្រុកនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ព្រោះលោកបានដកស្រង់នូវចម្លើយរបស់

សាក្សីរូបនេះគឺសមស្របហើយ ដែលគាត់ឆ្លើយមានការពាក់ព័ន្ធទៅលើបញ្ហាដែលលោកលើកឡើងជាមូលដ្ឋានក្នុងការសួរនេះ។

[១៤:០៤:៤៣]

**លោក ហ្សាស្តេ ប៉ៅ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងព្យាយាមសួរសំណួរសាមញ្ញ។

**សួរដោយលោក ហ្សាស្តេ ប៉ៅ៖**

**ស៖** លោកសាក្សី ផ្អែកតាមបទពិសោធន៍ឆ្លងកាត់ផ្ទាល់របស់លោកក្នុងរបបខ្មែរក្រហម តើបទពិសោធន៍របស់លោកដែលបានឆ្លងកាត់នោះ គឺថាប្រធានស្រុកទេជាអ្នកសម្រេចថាតើសម្លាប់ប្រជាជនឬក៏មិនសម្លាប់? ហើយជាអ្នកសម្រេចថាតើត្រូវប្រព្រឹត្តយ៉ាងណាចំពោះប្រជាជន? តើអ៊ីចឹងដែរឬទេប្រធានស្រុកជាអ្នកមានសិទ្ធិសម្រេចដូច្នេះ?

**លោក ប៉េជុយ ជីបសែ៖**

**ឆ៖** ខ្ញុំសូមឆ្លើយនូវសំណួររបស់លោក។ ចំពោះចម្លើយ -- សំណួរនេះគឺខ្ញុំ បើសេចក្តីរាយការណ៍ដែលយកឈ្មោះអ្នកទោស ដែលសួរចម្លើយហើយ ដែលមកកន្លែងស្រុកហ្នឹងគឺថា ខ្ញុំមិនមែនថាស្រុកជាអ្នកសម្រេចទាំងស្រុងទេ ពីព្រោះគេយកមកតែមេគឺ -- ដូចជាតាគុណៗយកឈ្មោះអ្នកសួរចម្លើយហើយមកសម្រេចនៅកន្លែងស្រុក។ ហើយត្រង់ថាគេសម្រេចទៅថ្នាក់លើទៀតអីទៀត អាហ្នឹងគឺខ្ញុំផុតការដែលខ្ញុំដឹងហើយ ពីព្រោះថា គ្រាន់តែដឹងថាពេលដែលមកដល់ គេប្រាប់ពីនោះមកថាទៅប្រជុំកន្លែងស្រុក ឥឡូវដល់ប្រជុំរួចហើយគេទៅវិញ គេនឹងចាត់ចែងចំពោះអ្នកដែលជាប់ទោសទាំងអស់។ ហើយគេក៏សម្រេចថាចំពោះអ្នកទោស ដែលមានខ្សែងក្រហមគឺមានន័យថាអ្នកទោសនោះត្រូវតែសម្លាប់។ ដូច្នេះគឺមេខ្មែរ -- មេសន្តិសុខគេប្រាប់ថា ស្រុកជាអ្នកសម្រេច។ ដូច្នេះខ្ញុំដឹងតែប៉ុណ្ណឹង ត្រង់ថាគេយកមកជំនុំថាត្រូវឡើងទៅតំបន់ទៀតអីទៀត អានោះគឺផុតការដឹងរបស់ខ្ញុំហើយ ខ្ញុំដឹងតែត្រឹមថាគេប្រាប់ពីនោះមកថា យកមកស្រុក ហើយនិងទៅវិញប៉ុនន៎ុងឯង។

[១៤:០៧:០៨]

**លោក ហ្សាស្តេ ប៉ៅ៖**

សូមអរគុណ។ ក្រុមមេធាវីការពារក្តីគឺសួរបានចប់សព្វគ្រប់ហើយ។ ក្នុងនាមខ្ញុំ និងលោក សុន អរុណ ដែលជាមេធាវីការពារក្តីលោក នួន ជា សូមថ្លែងអំណរគុណដល់លោក ដែលបានឆ្លើយទៅនឹង

សំណួររបស់យើងខ្ញុំ។ ដើម្បីជាប្រតិចារឹកគឺថា គឺខាងតំណាងសហព្រះរាជអាជ្ញា គឺមានពេលវេលាពេញមួយពេលរបស់គាត់ ដែលបានសួរសំណួរទៅកាន់សាក្សី ហើយនៅចំពោះយើងខ្ញុំវិញគឺថាលោកចៅក្រម ឡាវែន៍ បានចំណាយពេលកន្លះម៉ោង បានសួរដេញដោលទៅលើសាក្សី។ សូមអរគុណ។

[១៤:០៧:៥៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយច៍!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយច៍៖**

ខ្ញុំគ្រាន់តែចង់កត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងនេះ គឺពាក់ព័ន្ធទៅនឹងការចោទប្រកាន់យ៉ាងធ្ងន់ធ្ងរចំពោះ -- ពីក្រុមជនជាប់ចោទទាំងបី។ យើងដឹងថាពេលវេលា៣ ឬ៥នាទីនេះ គឺយើងខ្ញុំបានចំណាយមែន ក៏ប៉ុន្តែយ៉ាងណាក៏ដោយគឺថា យើងបានធ្វើការសម្រេច បានបញ្ជាក់រួចមកហើយនៅក្នុងសេចក្តីបង្គាប់របស់អង្គជំនុំជម្រះ ដែលលោកប្រធានបានបញ្ជាក់ហើយ វាមានភាពយុត្តិធម៌ចំពោះយើង។ ដូច្នេះហើយកុំលើកបញ្ហាចោទប្រកាន់តូច តិចតួចទៅលើចំណុចនេះ។

[១៤:០៨:៥១]

**ប្រធានអង្គជំនុំ៖**

ជាបន្ត អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី អៀង សារី ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម។ សួស្តីសហព្រះរាជអាជ្ញា សហភាតា ហើយក៏សួស្តីលោក អ្នកទាំងឡាយដែលបានចូលរួមនៅក្នុងសវនាការនេះ ទោះនៅក្នុងបន្ទប់ក្តី ឬនៅក្រៅបន្ទប់ក្តី។

**សួរដោយលោក អាង ឧត្តម៖**

**ស៖** សួស្តីផងដែរលោក ប៉េជុយ ជីបសែ! ហើយខ្ញុំអាង ឧត្តម ហើយខាងស្តាំខ្ញុំគឺលោកម៉ៃខល កាណាវាស។ យើងខ្ញុំជាសហមេធាវីការពារក្តីលោក អៀង សារី។ មុននឹងខ្ញុំចាប់ផ្តើមសំណួរហើយសំណួររបស់ខ្ញុំមិនមានច្រើនទេ ប្រហែលជាពីរ ឬបីទេ។ ហើយក៏មិនសំណួរច្រំដែលទៀត ជាសំណួរថ្មី ដើម្បីបញ្ជាក់ឡើងវិញ។ ប៉ុន្តែមុនខ្ញុំសួរ ខ្ញុំសូមបញ្ជាក់ពីការគាំទ្ររបស់ខ្ញុំ ចំពោះសំណួររបស់

ក្រុមមេធាវីការពារក្តីលោក នួន ជា ព្រឹកមិញ ដែលស្នើសុំឱ្យសាលាដំបូងចាក់ខ្សែអាត់បានសម្ភាស លោក ជីបសែ ប្រហែលជា២នាទីកន្លះ ដើម្បីជាភាពយុត្តិធម៌ដល់គាត់ ដើម្បីឱ្យគាត់ចងចាំថាជាសំឡេងរបស់គាត់មែនអត់ ពីព្រោះព្រឹកមិញ គាត់បញ្ជាក់ថាគាត់អត់បាន ហើយអត់ចាំថាជាសំឡេងរបស់គាត់ទេ។ ប៉ុន្តែអំមិញនេះ គាត់បានស្តាប់ខ្លះដែរ។ សូមបញ្ជាក់ថានេះជាភាគតែមួយទេ ក្នុងខ្សែអាត់នោះ។

លោក ជីបសែ លោកបានឆ្លើយនឹងសំណួររបស់លោកចៅក្រម និល ណុន ហើយនិងលោកចៅក្រម ឡាវែន៍ ហើយនិងក្រុមមេធាវីការពារក្តីលោក នួន ជា ហើយដែរថា ហើយលោកមានកិច្ចសម្ភាសន៍ពីរជាមួយនឹងមន្ត្រីស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ហើយលោកបានអះអាងទៀតដែរថា មុននឹងមកផ្តល់សក្ខីកម្មនៅបន្ទប់សវនាការនេះ លោកបានពិនិត្យមើលចម្លើយកំណត់ហេតុនៃការស្តាប់ចម្លើយរបស់លោកហើយដែរ ដើម្បីជួយរំឭកការចងចាំរបស់លោក។ ខ្ញុំចង់សួរលោកថា តើលោកបានអានកំណត់ហេតុនៃការយកចម្លើយរបស់លោកចំនួនប៉ុន្មាន មុននឹងមកផ្តល់សក្ខីកម្មនេះ?

[១៤:១១:១៨]

**លោក ប៉េជុយ ជីបសែ៖**

**ឆ៖** បាទ មុននឹងមកឆ្លើយនៅសំណួរនៅក្នុងអង្គជំនុំនេះគឺខ្ញុំបានមើលនូវសំណួរចម្លើយ ប៉ុន្តែចំនួនប៉ុន្មានហ្នឹង ខ្ញុំអត់ចាំទេ គឺបានមើលហើយលើសក្ខីកម្មដែលខ្ញុំបានឆ្លើយចំពោះខាងស៊ើបអង្កេតនោះ។ ខ្ញុំបានអាន ហើយក៏ចំនួនប៉ុន្មានសំណួរហ្នឹង គឺខ្ញុំអត់ចាំ។

**ស៖** បាទ សូមអរគុណ។ ឥឡូវខ្ញុំសូមចូលទៅដល់សាច់រឿង ហើយខ្ញុំមិនចូលស៊ីជម្រៅទេ ដោយសារតែរឿងនេះវាទាក់ទងរឿងប្រតិបត្តិការមន្ទីរសន្តិសុខ ឬទៅវិញ ដែលជាក្នុងសំណុំរឿង ០០២/០១ នេះ មិនអនុញ្ញាត។ ក៏ប៉ុន្តែយ៉ាងណាក្តី ដោយសារភាគីបានសួរដេញដោលលោកច្រើន ខ្ញុំសួរលោកតែមួយសំណួរ ឬក៏ពីរសំណួរទេទាក់ទងរឿងបញ្ហានេះដែរ។

**លោក អាង ឧត្តម៖**

លោកប្រធានខ្ញុំមានឯកសារមួយក្នុងការ ដើម្បីបង្ហាញសាក្សី ដែលឯកសារនេះមាននៅក្នុងសំណុំរឿងស្រាប់ គឺឯកសារ D125/125។ ខ្ញុំសូមប្រគល់ឯកសារនេះជូនដល់សាក្សី និងសូមបញ្ចាំងលើកញ្ចក់ទូរទស្សន៍ផង។ ខ្ញុំនឹងមិនទាន់សួរសំណួរដល់អង្គសេចក្តីទេ តាមក្រឹត្យក្រមរបស់យើង ខ្ញុំសូមសំណួរសួរសំណួរផ្តើមសិន ក្នុងករណីថាសាក្សីនេះបានស្គាល់ លោក ជីបសែ បានស្គាល់សាក្សីនេះ ឬ

អត់? បានខ្ញុំបន្តសំណួរតាមក្រឹត្យក្រមដែលយើងបានកំណត់រួចហើយ។ សូមអរគុណលោកប្រធាន។

[១៤:១៣:១៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីមេធាវីយកទៅជូនសាក្សីពិនិត្យ!

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

**សួរដោយលោក អាង ឧត្តម៖**

**ស៖** លោក ជីបសែ ហើយឯកសារដែលខ្ញុំនឹងសួរលោកនេះ គឺនៅក្នុងឯកសារ D125/125 នៅក្នុងលេខ ERN ជាភាសាខ្មែរ 00224060, នៅលើភាសាអង់គ្លេសគឺ 00240039, ភាសាបារាំង 00240044។ លោក ជីបសែ លោកបានឆ្លើយនឹងសំណួរមុនៗ ដូចជាសំណួររបស់លោកប្រធាន សំណួររបស់ភាគីផ្សេងៗថា លោកបម្រើការនៅមន្ទីរសន្តិសុខពង្រ ពីឆ្នាំ១៩៧២ ឬ៧៣ ដល់ឆ្នាំ១៩៧៧ ហើយលោកអះអាងថាក្នុងតួនាទីជាបុគ្គលិក ហើយក្នុងចម្លើយរបស់លោកជាស្មៀន។ តើលោកនៅរក្សាចម្លើយទាំងនេះដែរឬទេ?

**ឆ៖** ខ្ញុំគឺ ចំពោះពាក្យថា "ស្មៀន" ហ្នឹង គឺថាខ្ញុំនឹកឃើញដោយខ្លួនឯងទេ ពីព្រោះថាវានៅជាប់ជាមួយពួក តាគុណ ហ្នឹង គឺគេឲ្យសរសេរពីរឿងចម្លើយ សំណួរចម្លើយដែលសួរពីអ្នកដែលជាប់ទោសនៅក្នុងសន្តិសុខពង្រ។ ដូច្នេះពាក្យហ្នឹង គឺគេទាំងអស់គ្នាក៏ចាត់ទុកថាខ្ញុំជាស្មៀនហើយ ក៏ខ្ញុំមិនជាកែប្រែអីទេ វាជាអ្នកកាន់ខាងឯកសារទៅហើយ ក៏ខ្ញុំអាចរក្សាទុកពាក្យហ្នឹងដដែលក៏បានដែរ។

[១៤:១៦:០៥]

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងឯកសារដែលខ្ញុំជូនលោកនេះ សូមលោកកុំទាន់បញ្ជាក់ឈ្មោះសាក្សីដែលមាននៅក្នុងឯកសារនេះ នោះគឺនៅទំព័រទី១ នៅទំព័រមុខហ្នឹង លោកអាចឃើញហើយ។ តើលោកស្គាល់ឈ្មោះសាក្សីហ្នឹងទេ?

**ឆ៖** បាទ ខ្ញុំឈ្មោះហ្នឹងគឺខ្ញុំស្គាល់។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមជម្រាបថា ឈ្មោះនេះបានផ្តល់សក្ខីកម្មទៅដល់អ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត នៅកាលបរិច្ឆេទជាមួយគ្នានឹងការផ្តល់បទសម្ភាសរបស់លោកដែរ។ ក៏ប៉ុន្តែរបស់សាក្សីរូបនោះគឺធ្វើមុនលោក គឺធ្វើនៅពេលព្រឹក ហើយលោកគឺធ្វើនៅពេល

រសៀល។ នៅក្នុងទំព័រដែលខ្ញុំជម្រាបជូនអម្បាញ់មិញ បើនិយាយឱ្យងាយស្រួលទៅភាសាខ្មែរនៅទំព័រ៤ ហ្នឹង ខ្ញុំសូមអាននូវសម្ដីរបស់សាក្សីនោះ ហើយខ្ញុំមិនអានទាំងស្រុងទេ គឺអានតែខ្លឹមសារ។ ក្នុងករណីដែលមានសំណួរថា "តើប្រធានមន្ទីរសន្តិសុខនៅពង្រនោះឈ្មោះអ្វី?" ហើយលោកបានឆ្លើយថា "ឈ្មោះ គុណ ជាប្រធានសន្តិសុខ"។ ខ្ញុំបន្តទៅទៀត "ខ្ញុំស្គាល់ឈ្មោះ នាថ ជាអនុប្រធាន និងឈ្មោះ ប៉េជុយ ជីបសែ ជាសមាជិក"។ បានន័យជាសមាជិកនៃមន្ទីរសន្តិសុខពង្រហ្នឹងឯង។ តើលោកមានការអះអាងយ៉ាងណាចំពោះសម្ដីរបស់សាក្សីរូបនេះ ដែលថាលោកជាសមាជិកនៃមន្ទីរសន្តិសុខពង្រ?

[១៤:១៨:១៥]

**ឆ៖** អេ្ហ! មនុស្សភាគច្រើនណាស់ដែលថា ខ្ញុំហ្នឹងជាអ្នកដែលទទួលខុសត្រូវនៅកន្លែងសន្តិសុខពង្រ ពីព្រោះថាខ្ញុំហ្នឹងវានៅជាប់នឹង តាគុណ។ ដូច្នេះអ្នកទាំងនោះយល់ច្រឡំថា ខ្ញុំហ្នឹងជាថាជាអនុប្រធាន ឬមួយក៏ជាអ្នកសមាជិកក៏ថាបាន។ ប៉ុន្តែក្នុងរចនាសម្ព័ន្ធ គឺថាខ្ញុំអាចបដិសេធ ពីព្រោះថានៅក្នុងអង្គការសម្ងាត់របស់វា គឺគ្មានឈ្មោះខ្ញុំនៅក្នុងនោះទេ គឺមានតែឈ្មោះ គុណ ជាបក្ខជន, នាថ ជាបក្ខជន ហើយក្រុមសម្ព័ន្ធយុវកកមួយចំនួន ដែលខ្ញុំមិនចាំហ្នឹង ហើយឈ្មោះខ្ញុំហ្នឹងគឺមានតែឈ្មោះទេ ប៉ុន្តែគ្មានបានចូលទៅក្នុងអង្គការសម្ងាត់របស់ពួកខ្មែរក្រហមទេ។

[១៤:១៩:២៤]

**ស៖** សូមអរគុណ។ ហើយតើលោកដឹងថា ឈ្មោះ ថាសាក្សីឈ្មោះហ្នឹងគាត់មានតួនាទីធ្វើអីដែរនៅមន្ទីរសន្តិសុខពង្រហ្នឹង?

**ឆ៖** បាទ ចំពោះឈ្មោះនេះគឺថា ខ្ញុំមិនចាំតួនាទីរបស់គាត់ទេ គឺមិនដឹងជាគាត់ទទួលធ្វើជាមុខងារខាងណាទេ ពីព្រោះកន្លែងដែលគាត់នៅគឺនៅ គេហៅ ព្រៃស្វាយនៅខាងភូមិពន្លឺព្រះផុស ព្រោះថា សាខារបស់អាសន្តិសុខពង្រហ្នឹង វាមាន គឺថាកន្លែងសាខាវាតូចមួយនៅម្ដុំគេហៅព្រៃស្វាយ។ នៅមិនមែននៅក្នុងភូមិពន្លឺព្រះផុសទេ នៅគឺថាឆ្ងាយពីភូមិពន្លឺព្រះផុសបន្តិចដែរ ហើយឈ្មោះ តុងហោ ហ្នឹងក៏បានគាត់ខាង តាគុណ ហ្នឹង គាត់ទទួលនៅខាងព្រៃស្វាយហ្នឹង។ អាហ្នឹងគឺ ខ្ញុំដឹងតែប៉ុណ្ណឹង។

**ស៖** បាទ សូមអរគុណ។ ប៉ុន្តែបើយើងងាកមួយជំហានទៀតមកក្រោយ ពិនិត្យមើលចម្លើយទី១ របស់គាត់នៅក្នុងឯកសារហ្នឹងដដែល គាត់បានអះអាងថា "បន្ទាប់មកទៀតនៅឆ្នាំ១៩៧៥ គេបានចាត់តាំងខ្ញុំឱ្យទៅនៅមន្ទីរសន្តិសុខពង្រ"។ អំមិញ លោកបានអះអាងថា ប្រហែលសាក្សីនោះច្រឡំ ឬគេចេះតែហៅគ្រប់គ្នាទេ តើលោកអះអាងឱ្យច្បាស់ជាងនេះទៅទៀតទៅថា តំណែងដែលលោកសាក្សីនោះ

អះអាងសម្រាប់លោកនៅមន្ទីរសន្តិសុខពង្រហ្នឹង តើលោកអះអាងឲ្យប្រាកដយ៉ាងម៉េចថា សាក្សីហ្នឹងនិយាយមិនត្រូវ ច្រឡំ ឬយ៉ាងម៉េច? សូមបញ្ជាក់ឲ្យច្បាស់ចំណុចនេះ ខ្ញុំនឹងលែងសួរលោកទៀត។

[១៤:២១:៥១]

**ឆ:** បាទ ចំពោះចម្លើយសាក្សីរូបនេះ ដែលថាខ្ញុំជាសមាជិកហ្នឹង គឺខ្ញុំសូមបដិសេធ ពីព្រោះខ្ញុំគ្រាន់តែជាអ្នកដែលជាស្មៀនក៏ពិតមែន ប៉ុន្តែនៅក្នុងការពួកតាគុណ ហ្នឹងថាខ្ញុំជាអនុធនកណ្តាលមិនអាចឲ្យចូលជាអង្គការសម្ងាត់របស់វាបានទេ។ ដូច្នេះ ការដែលគាត់លើកឡើងថា ខ្ញុំជាសមាជិក គឺខ្ញុំសូមបដិសេធ។

**លោក អាង ឧត្តម៖**

សូមអរគុណលោក ប៉េជុយ ជីបសែ ហើយយើងខ្ញុំអស់មានសំណួរសួរលោកហើយ តែយ៉ាងណាក្តីតាងនាមលោក អៀង សារី យើងខ្ញុំសូមអរគុណចំពោះលោក ដែលបានឡើងមកថ្លែងសក្ខីកម្មដល់តុលាការ ក្នុងការជួយស្វែងរកការពិត ហើយសូមអរគុណលោក ហើយសូមជូនពរលោកបានសុខសប្បាយពេលធ្វើដំណើរត្រឡប់ទៅវិញ ហើយក៏សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ម៉េចទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន មានការផ្លាស់ប្តូរកែប្រែចិត្តអីទេ?

[១៤:២៣:០៨]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ក្នុងនាមលោក ខៀវ សំផន យើងខ្ញុំអត់មានសំណួរអីសម្រាប់សាក្សីនេះទេបាទ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ លោក ប៉េជុយ ជីបសែ ការស្តាប់សក្ខីកម្មរបស់លោករហូតដល់ពេលនេះ បានចប់ហើយ។ ហើយវត្តមានរបស់លោកនៅ អ.វ.ត.ក នេះ លែងមានភាពចាំបាច់ទៀតហើយ លោកអាចត្រឡប់ទៅលំនៅដ្ឋានរបស់លោក ឬក៏គោលដៅណា ដែលលោកមានបំណងចង់ទៅបានហើយ។

អង្គជំនុំជម្រះសូមអរគុណចំពោះលោក ដែលបានចំណាយពេលវេលាដ៏មានតម្លៃមកចូលរួមផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះក្នុងរយៈពេល ២ថ្ងៃនេះ ហើយប្រកបដោយភាពអត់ធ្មត់ និងខិតខំអស់ពីលទ្ធភាពដែលខ្លួនមាន។ ហើយសក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិត

នៃរឿងក្ដីនេះ ហើយសូម ជីបស៊ែ ជួបតែសំណាងល្អ និងធ្វើដំណើរត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួល ជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សីរូបនេះវិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់ ឬក៏ទីកន្លែងដែលគាត់ ជាគោលដៅនៃបំណងដែលគាត់ចង់ទៅបានហើយ ហើយលោក ជីបស៊ែ អាចចាកចេញពីបន្ទប់សវនាការត្រឡប់ទៅវិញហើយ ហើយមេធាវីប្រឹក្សាសាក្សីគឺ ក៏អាចចេញត្រឡប់ទៅវិញដូចគ្នានឹងសាក្សីដែរ។

[១៤:២៤:២៣]

ហើយឥឡូវនេះ ដល់ពេលសម្រាកហើយដែរ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបីខ្វះម្ភៃនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយសវនាការបន្តនេះ អង្គជំនុំជម្រះនឹងស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណី ដែលមានរហស្សនាម TCCP-82។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:២៤ នាទី ដល់ម៉ោង ១៤:៤៤ នាទី)*

[១៤:៤៤:១១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ដូចអង្គជំនុំជម្រះបានជម្រាបជូនភាគី និងសាធារណជនរួចហើយអំមិញនេះថា ជាបន្តនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម TCCP-82។ ហើយអង្គជំនុំជម្រះក៏សូមជម្រាបភាគីថា អង្គជំនុំជម្រះបានទទួលពាក្យសុំរបស់ជនជាប់ចោទ អៀង សារី ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១២ ឯកសារ E231/1 តាមរយៈមេធាវីការពារក្ដីរបស់គាត់សុំលះបង់សិទ្ធិមានវត្តមាន នៅក្នុងកិច្ចដំណើរការសវនាការពិភាក្សាដេញដោលដើមបណ្ដឹងរដ្ឋប្បវេណីចំនួន១៤រូប ក្នុងចំណោមដើមបណ្ដឹងរដ្ឋប្បវេណីចំនួន១៤រូប ក៏មានដើម

បណ្តឹងរដ្ឋប្បវេណី TCCP-82 មួយរូបដែរ។ ហើយនៅពេលនេះ លោក អៀង សារី ស្នើសុំលះបង់សិទ្ធិមានវត្តមាន នៅក្នុងកិច្ចដំណើរការសវនាការពិភាក្សាដេញដោលស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនដោយមានដែនកំណត់ ដោយគាត់មានបញ្ហាសុខភាព តែរូបកាយ និងស្មារតីសមស្រប។

អង្គជំនុំជម្រះសម្រេចធ្វើសវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី ដែលមានរហស្សនាម TCCP-82 ដោយមិនមានវត្តមានលោក អៀង សារី ដោយអនុវត្តតាមវិធាន៨១(៥) នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

មន្ត្រីរដ្ឋបាលតុលាការ អញ្ជើញដើមបណ្តឹងរដ្ឋប្បវេណី TCCP-82 ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

*(មន្ត្រីតុលាការនាំដើមបណ្តឹងរដ្ឋប្បវេណីចូលក្នុងបន្ទប់សវនាការ)*

[១៤:៤៧:១១]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីដើមបណ្តឹងរដ្ឋប្បវេណី។ តើលោកឈ្មោះអី?

**លោក មាស សារ៉ាន់៖**

**ឆ៖** ខ្ញុំបាទឈ្មោះ មាស សារ៉ាន់។

**ស៖** បាទ អរគុណលោក មាស សារ៉ាន់ តើលោកអាចប្រាប់អំពីថ្ងៃខែឆ្នាំកំណើតរបស់លោកដល់អង្គសវនាការបានដែរឬទេ? តើលោកកើតថ្ងៃខែឆ្នាំណា?

**ឆ៖** ខ្ញុំបាទកើតថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៤៩។

**ស៖** អរគុណ ហើយតើលោកមានទីកន្លែងកំណាត់នៅទីកន្លែងណា?

**ឆ៖** ខ្ញុំកើតនៅឃុំបមន ស្រុករំដួល ខេត្តស្វាយរៀង។

**ស៖** បាទ អរគុណ។ ហើយលោក មាស សារ៉ាន់ តើសព្វថ្ងៃនេះលោកមានទីលំនៅនៅទីកន្លែងណា ហើយមានមុខរបរធ្វើអ្វីដែរ?

**ឆ៖** ខ្ញុំនៅក្នុងភ្នំពេញ នៅក្នុងក្រុងភ្នំពេញហ្នឹង ហើយខ្ញុំធ្វើការជាពេទ្យ។

[១៤:៤៨:១៨]

**ស៖** បាទ អរគុណ។ ហើយឪពុកបង្កើតរបស់លោកឈ្មោះអី?

**ឆ៖** ឪពុកបង្កើតរបស់ខ្ញុំឈ្មោះ មាស ខាវ សរសេរក្នុងក្រដាសនេះច្រឡំ។ មាស ខាវ។

**ស៖** បាទ អរគុណ។ ចុះម្ដាយបង្កើតរបស់លោក គាត់ឈ្មោះអី?

**ឆ៖** ម្ដាយខ្ញុំបាទ អ៊ុំ ឈាង។

**ស៖** បាទ អរគុណ។ ហើយតើលោកមានប្រពន្ធឬទេ? ហើយប្រពន្ធរបស់លោកគាត់ឈ្មោះអី? មានកូនប៉ុន្មាននាក់?

**ឆ៖** ខ្ញុំបាទមានប្រពន្ធ។ ប្រពន្ធឈ្មោះ មាន គឹមលីត។ ហើយខ្ញុំមានកូនមួយដែលប្រពន្ធខ្ញុំហ្នឹងពរពោះ៨ខែ នៅពេលដែលបែកភ្នំពេញ។

**ស៖** បាទ អរគុណ។ ហើយអ៊ីចឹងសព្វថ្ងៃនេះលោកពោះម៉ាយ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ខ្ញុំសម្រេចថាខ្ញុំមិនយកប្រពន្ធទៀតទេ។

[១៤:៤៩:៣៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី អនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងផ្ដល់វេទិកា ជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសួរដេញដោលដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ មុននឹងភាគីដទៃទៀតនៃរឿងក្ដី។ ហើយសូមបញ្ជាក់ថា មេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី រួមទាំងតំណាងសហព្រះរាជអាជ្ញាផងគឺពេលកន្លះថ្ងៃក្នុងការសួរដេញដោលដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។ នេះជាពេលវេលាអតិបរមាដែលកំណត់។

លោក មាស សារ៉ាន់ ក្នុងនាមលោកជាដើមបណ្ដឹងរដ្ឋប្បវេណីនៅទីបំផុតនៃការសួរដេញដោលអង្គជំនុំជម្រះជម្រាបលោកថា លោកអាចថ្លែងរៀបរាប់ដល់អង្គសវនាការអំពីស្ថានភាពទុក្ខវេទនា ឬ/និងព្យសនកម្មដែលកើតមានឡើងចំពោះលោក ដែលមានជាអាទិ៍ការខូចខាតខាងផ្លូវចិត្ត ផ្លូវកាយ សម្ភារៈ ហើយព្យសនកម្មនោះ ជាព្យសនកម្មផ្ទាល់ខ្លួនដែលជាបច្ច័យដោយផ្ទាល់ពីបទឧក្រិដ្ឋ និងបានកើតមានឡើងពិតប្រាកដរហូតដល់បច្ចុប្បន្ន ដែលនាំឲ្យលោកសម្រេចចិត្តប្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់លើជនជាប់ចោទ ដែលប៉ះពាល់ចំពោះលោកនៅក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ។

សូមអញ្ជើញតំណាង អ៎! ក្រុមមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន។ គឺមេធាវី គ្រីស្ទីន ឡើងចោទសំណួរ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញបាទ!

[១៤:៥១:៤៣]

**លោកស្រី គ្រីស្ទីន ម៉ាទីណូ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកប្រធាន អស់លោក លោកស្រីចៅក្រមជាទីគោរព និងភាគីទាំងអស់ជាទីគោរព!

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី គ្រីស្ទីន ម៉ាទីណូ៖**

**ស៖** ជម្រាបសួរលោកមាស សាវ៉ាន់! យើងនឹងចាប់ផ្ដើមនិយាយអំពីស្ថានភាពរបស់លោកមុនថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥។ នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់លោក លោកបានរៀបរាប់ -- ខ្ញុំសូមផ្ដល់លេខយោងដោយសារពេលវេលាខ្លី។ គឺថាឯកសារ D22/418 ហើយជាភាសាបារាំងនោះគឺថា 00362202, ជាភាសាខ្មែរ 00362176, ជាភាសាអង់គ្លេស 002196 (ស៊ីក)។

[១៤:៥២:៥២]

លោកបាននិយាយថា "លោកស្ថិតនៅក្នុងប្រម៉ូទី៨ នៃគិលានុបដ្ឋាក គឺថាលោកបានសិក្សាផ្នែកគិលានុបដ្ឋាកនេះ ហើយនៅមុនឆ្នាំ១៩៧៥ នោះលោកជាគិលានុបដ្ឋាកហើយ តើលោកអាចរៀបរាប់អំពីប្រវត្តិមុខរបររបស់លោកមុនឆ្នាំ១៩៧៥ នេះបានដែរឬទេ?

[១៤:៥៣:៣០]

**លោក មាស សាវ៉ាន់៖**

**ឆ៖** អរគុណលោកប្រធាន។ ខ្ញុំបានចូលសាលា ចូលសាលារៀនគិលានុបដ្ឋាករដ្ឋនៅឆ្នាំ៦៩។ ខ្ញុំចេញនៅឆ្នាំ៧២ ដូចជាគិលានុបដ្ឋាករដ្ឋទាំងប៉ុន្មានដែលនៅក្នុងស្រុកខ្មែរយើង ខ្ញុំ តាមក្បួននៃៗប្រទេសហ្នឹងគឺថាបានរៀន។ ហើយពេលចេញពីសាលា ខ្ញុំបានមកធ្វើការនៅមន្ទីរពេទ្យព្រះកេតុមាលាភ្នំពេញ មន្ទីរព្រះកេតុមាលាភ្នំពេញ។ នៅកន្លែងនេះ ខ្ញុំធ្វើការនៅអគាររបេង ដែលឈ្មោះថា "អគារពិនដាវ៉ាសុដារ៉េត"។

**ស៖** សូមអរគុណលោក។ នៅភ្នំពេញរហូតដល់ឆ្នាំ១៩៧៥ នៅមន្ទីរពេទ្យនោះ ឬក៏យ៉ាងម៉េច ហើយមន្ទីរពេទ្យយ៉ាងម៉េចដែរ? ហើយលោកត្រូវបានផ្ទេរ ឬក៏បញ្ជូនទៅមន្ទីរពេទ្យផ្សេងទៀតដែរឬទេ?

**ឆ៖** មន្ទីរពេទ្យព្រះកេតុមាលាគឺជាមន្ទីរពេទ្យរដ្ឋធំពីរនៅក្នុងទីក្រុងភ្នំពេញ គឺមន្ទីរពេទ្យព្រះកេតុមាលាមួយ និងមន្ទីរពេទ្យសូវៀតមួយ។ ហើយខ្ញុំនៅក្នុងមន្ទីរពេទ្យព្រះកេតុមាលាហ្នឹង មិនមានដូរទៅកន្លែងណាទៀតទេ រហូតដល់ពេលខ្ញុំត្រូវបំពេញកិច្ចដែលៗគេហៅថាទៅៗ បំពេញធ្វើជាទាហាននោះ។ ទាហានដែលហៅថា *អាប៉ាឡេស្ស៊ីឡាប៉ូៗ* ខ្ញុំបានទៅនៅឆ្នាំ៧២ ៧៣ៗបាទ។ មកហើយ ខ្ញុំនៅពេទ្យព្រះកេតុមាលារហូតត្រាតែទៅបំពេញជាៗកងទ័ព ពេទ្យកងទ័ព។

**ស៖** នៅពេលដែលលោកនិយាយថា លោកបានក្លាយជាយោធានោះ តើលោកជាសមាជិកកងទ័ព ឬក៏ក្នុងឋានៈជាបុគ្គលិកពេទ្យ។ តើកាលណោះនោះ ស្ថានឋានៈជាយោធារបស់លោកហ្នឹងយ៉ាងម៉េចដែរ ឬក៏លោកបានបំពេញកាតព្វកិច្ចយោធា?

[១៤:៥៦:១១]

**ឆ៖** គឺជាកាតព្វកិច្ចដែលរដ្ឋតម្រូវ បុគ្គលិកទាំងអស់ បុគ្គលិកពេទ្យទាំងអស់ត្រូវបំពេញ១៨ខែជាៗទាហាន ហើយដោយសារខ្ញុំហ្នឹងជាពេទ្យ ម្ល៉ោះហើយវាទៅជាទាហានពេទ្យ។ ម្ល៉ោះហើយខ្ញុំៗបំពេញដូចដែលគេដែលរដ្ឋបានបំពេញហ្នឹង។ ម្ល៉ោះហើយជាទាហានពេទ្យ។

**ស៖** អ៊ីចឹងលោកត្រូវបានបញ្ជូនទៅទីណាដែរទៅពេលនុំង?

**ឆ៖** មិនមែនបញ្ជូនទៅ ដូចថានៅពេលដែលៗយើង ដែលរដ្ឋតម្រូវឲ្យទៅៗបំពេញកិច្ចជាទាហាន១៨ខែហ្នឹង គេយកជំនាន់ខ្ញុំដែលមានគ្នា១៥០នាក់ហ្នឹងមកពីទីស្តីការដ្ឋមន្ត្រីក្រសួងសុខាភិបាល រួចហើយគេជ្រើសរើសអ្នកលេខ១ លេខ២ លេខ៣ ទៅរើសប៉ុស្តិ៍ដែលសរសេរនៅក្នុងតាប្លូមួយយ៉ាងធំ ម្ល៉ោះហើយលេខ១ យកកន្លែងមួយ រួចហើយលេខ២ មកយកបន្តៗៗរហូត។ ខ្ញុំៗលេខ១០។ ខ្ញុំលេខ១០ ខ្ញុំយកស៊ីសុផុន ដោយខ្ញុំយល់ថា ស៊ីសុផុនគឺជាកន្លែងមួយដែលមិនទាន់មានធ្ងន់ធ្ងរ ឬចម្បាំងទេ។ ម្ល៉ោះហើយខ្ញុំសម្រេច ពេលនុំងខ្ញុំមិន -- ខ្ញុំសម្រេចអ៊ីចឹងឯង យល់អ៊ីចឹងឯង ខ្ញុំក៏យកស៊ីសុផុនជាកន្លែងធ្វើការគឺនៅក្នុងមជ្ឈមណ្ឌលហ្វឹកហ្វឺនទាហានលេខ៤ ដាក់ថា "*សេអ៊ីកាត់សង់ដាំងហ្វីសុង នាមុយរ៉ូកាត់*"។

[១៤:៥៨:០៦]

**ស៖** តើលោកបានធ្វើការងារជាគិលានុបដ្ឋាក ឬក៏ជាយោធា ឬក៏គ្រាន់តែជាការងារជាយោធានោះទេ?

**ឆ៖** នៅក្នុងមជ្ឈមណ្ឌលហ្វឹកហ្វឺនទ័ពថ្មើជើងលេខ៤ មានគិលានដ្ឋានមួយនៅខាងក្នុងនុ៎ង ហើយខ្ញុំទទួលបន្ទុកនៅក្នុងគិលានដ្ឋាននោះឯងបាទ។ មិនមែនជាអ្នកចម្បាំង គឺថាអ្នកមើលជំងឺ ពីព្រោះវាមានអ្នកទាហានដែលមករើសនៅកន្លែងហ្នឹងរាប់ពាន់អ្នក។

**ស៖** នៅពេលដែល -- តើលោកបានបញ្ចប់កាតព្វកិច្ចជាយោធានោះនៅពេលណាដែរ? ហើយលោកបានត្រឡប់មកភ្នំពេញវិញពេលណាដែរ? ហើយមកតាមរបៀបណាដែរ?

**ឆ៖** ចុងឆ្នាំ១៧៤ ខ្ញុំចប់ៗមុខនាទីជាៗបំពេញកិច្ច១៨ខែ ខ្ញុំត្រឡប់មកភ្នំពេញវិញ។ ក្នុងប្រលោះនុ៎ង ដែលក្នុងប្រលោះនៃកិច្ចការនៅស៊ីសុផុននុ៎ងដែលៗៗខ្ញុំនេះបានប្រពន្ធនៅស្រុកនុ៎ង។ បើសិនណាខ្ញុំអត់ទៅស្រុកនុ៎ង ប្រហែលជាខ្ញុំមានប្រពន្ធនៅកន្លែងណាទៀតក៏មិនដឹង។ ប៉ុន្តែនៅពេលនុ៎ង ទៅដល់ស្រុកស៊ីសុផុននុ៎ងធ្វើការនៅនុ៎ង ខ្ញុំបានប្រពន្ធហើយ។ ខ្ញុំមកដល់ភ្នំពេញ ចុង៧៤ ដោយយន្តហោះ។

**ស៖** ជាមួយគាត់ឬយ៉ាងម៉េច?

**ឆ៖** ជាមួយនឹងប្រពន្ធខ្ញុំដែលមានផ្ទៃពោះ។

**ស៖** នៅពេលដែលលោកបានត្រឡប់មកទីក្រុងភ្នំពេញវិញ តើលោកធ្វើការនៅកន្លែងណាដែរនៅភ្នំពេញ?

**ឆ៖** នៅពេលដែលខ្ញុំមកដល់ភ្នំពេញ ខ្ញុំនៅមិនទាន់បានចូលទៅមន្ទីរពេទ្យកាល់ម៉ែតដែលជាកន្លែងចាស់របស់ខ្ញុំទេ។ គឺច្បាប់ដែលមកពីស៊ីសុផុនមក មកកន្លែងនុ៎ងឲ្យមកជួបជុំគ្នានៅកន្លែងមួយនៅបុរីកីឡា។ ម្ល៉ោះហើយខ្ញុំធ្វើការនៅក្នុងកន្លែងមន្ទីរពេទ្យ ហៅថាមន្ទីរពេទ្យទៅចុះ ពីព្រោះកន្លែងនុ៎ងវាមានកន្លែងរះប្រាំកន្លែង ៗនៅក្នុងបុរីកីឡាហ្នឹង។ ម្ល៉ោះហើយគេឲ្យទៅធ្វើការនៅកន្លែងនុ៎ង។

**ស៖** លោក មាស សារ៉ាន់ ខ្ញុំភ្លេចសួរលោក អង្កាល់នុ៎ងលោកជារដ្ឋការ លោកនៅក្រោមឱវាទរដ្ឋ ហើយរដ្ឋហ្នឹងជាអ្នកចាត់តាំងឲ្យលោកទៅធ្វើការ ឬមួយក៏យ៉ាងម៉េច?

[១៥:០១:៣០]

**ឆ៖** ខ្ញុំជាបុគ្គលិករបស់រដ្ឋ។ រដ្ឋបានបញ្ជូនខ្ញុំទៅស៊ីសុផុន ខ្ញុំត្រឡប់មកវិញចូលបំពេញកិច្ចការរដ្ឋ ហើយរដ្ឋហ្នឹងឲ្យខ្ញុំទៅនៅកន្លែងបុរីកីឡាហ្នឹងដែលពេលនុ៎ងគេដាក់ថា "*សង់ដឺទ្រីយ៉ាស*" បុរីកីឡាមានកន្លែងរះកាត់ប្រាំកន្លែង។

**ស៖** តើមណ្ឌលនោះមានស្រាប់ហើយឬ នៅពេលដែលលោកចេញទៅ? ខ្ញុំចង់និយាយពីបុរីកីឡានេះ មុនពេលលោកចេញទៅស៊ីសុផុននោះ មណ្ឌលនៅបុរីកីឡានេះមានស្រាប់ហើយ ឬក៏មិនទាន់

មានទេ?

**ឆ៖** ខ្ញុំមិនដឹង ពេលដែលខ្ញុំទៅៗស៊ីសុផុន។ ខ្ញុំកន្លែងហ្នឹងច្បាស់ជាអត់មានទេ ប៉ុន្តែនៅពេលដែលខ្ញុំត្រឡប់មកវិញ ត្រឡប់ពីស៊ីសុផុនមកវិញក្នុងរយៈពេលប្រាំបីដណ្ដប់ខែ គឺខ្ញុំឃើញកន្លែងហ្នឹងតែម្ដង ដោយគេឲ្យខ្ញុំទៅធ្វើការកន្លែងហ្នឹង។ ថ្មីថែស ដែលទើបនឹងដាក់ ទើបនឹងមានៗថ្មីៗបាទ។

[១៥:០២:៥៧]

**ស៖** តើលោកអាចពន្យល់ទាក់ទងទៅនឹងមន្ទីរពេទ្យហ្នឹង ដែលត្រូវបានបង្កើតឡើងប្រហាក់ប្រហែលខ្ទង់ឆ្នាំ១៩៧៤ ហើយសាងសង់ហ្នឹងមូលហេតុអីបានសាងសង់? ហើយដំណើរការយ៉ាងម៉េចដែរទាក់ទងទៅនឹងសេវាកម្មពេទ្យនៅក្នុងទីក្រុងភ្នំពេញនេះ?

**ឆ៖** បើនិយាយថា ជាមន្ទីរពេទ្យវាមិនមែនជាមន្ទីរពេទ្យទេ។ កន្លែងហ្នឹងគេដាក់ថា "*សង់ដឺទ្រីយ៉ាស*" គឺជាទាហានអ្នកកាន់កាប់កន្លែងហ្នឹង។ ទាហានអ្នកកាន់កាប់សេចក្ដីថា មេហ្នឹងជាទាហាន ៗ ហើយដោយសារមានការមានគ្រាប់បែកធ្លាក់ គ្រាប់បែកដែលផ្លោងពីក្រៅមកធ្លាក់នៅក្នុងភ្នំពេញហ្នឹងគ្រប់កន្លែង វាមានរបួស ធ្លាក់កន្លែងណាក៏ត្រូវៗ ដែរ ធ្លាក់កន្លែងណាក៏មានរបួសដែរ។ ម្ល៉ោះហើយរបួសហ្នឹងច្រើនពេក គឺជារដ្ឋទេ ដែលពេលនុំងបានធ្វើកន្លែងហ្នឹងជាកន្លែងទទួលជំងឺទី១។ នៅពេលដែល មានរបួស ពេលគ្រាប់បែកធ្លាក់ដឹកមកបុរីកីឡា ហើយគឺពួកក្រុមខ្ញុំហ្នឹងហើយនៅក្នុងមន្ទីរវះកាត់ប្រាំហ្នឹងដែលអ្នកទទួលអ្នកជំងឺហ្នឹងមុនបង្អស់ មុននឹងដាក់ទៅមន្ទីរពេទ្យផ្សេងៗទៀត។

[១៥:០៤:២០]

ម្ល៉ោះហើយកន្លែងហ្នឹងគឺជាកន្លែងទទួល និងថាជាមន្ទីរពេទ្យមិនមែនជាមន្ទីរ ជាមជ្ឈមណ្ឌលទទួលបន្ទាន់មួយនៅក្នុងក្រុងភ្នំពេញ។ ហើយទាំងក្រុងភ្នំពេញទាំងមូលយកមកដាក់កន្លែងហ្នឹង។

**ស៖** ហើយឥឡូវយើងហៅកន្លែងហ្នឹងថាមន្ទីរពេទ្យទៅ។ តើកន្លែងហ្នឹងបើទទួលតែទាហានទេ ឬក៏ទទួលជនស៊ីវិលផងដែរ?

**ឆ៖** នៅកន្លែងបុរីកីឡាហ្នឹងទទួលទាំងអស់។ ខ្ញុំមើលមិនឃើញ ៗថាស៊ីវិល ឬទាហាន អ្នកណាដែលៗរបួសគេដឹកមកកន្លែងហ្នឹងទាំងអស់។ រដ្ឋបានរៀបចំកន្លែងហ្នឹង គឺជាកន្លែងមួយដែលទទួលមនុស្សត្រូវគ្រាប់ មនុស្សធ្លាក់មាន -- មានមនុស្សដែលថាត្រូវគ្រាប់ ធ្លាក់ផ្លោងមកហ្នឹងហើយដែលៗដឹកមកកន្លែងហ្នឹងទាំងអស់។ គឺជាកន្លែងទទួលបន្ទាន់មួយនៅក្នុងភ្នំពេញ មិនគិតថាទាហាន មិនគិតថាស៊ីវិល។

**ស៖** តើមន្ទីរពេទ្យហ្នឹងមានដំណើរការយ៉ាងម៉េចដែរ? លោកនិយាយថាមានមន្ទីរពិសោធន៍ប្រាំ អ៎! កន្លែងវះកាត់នុំងប្រាំ តើមានពេទ្យវះកាត់ ឬក៏បុគ្គលិកជាគិលានុបដ្ឋាក ឬក៏អ្នកជំនួយផ្នែកពេទ្យហ្នឹងនៅកន្លែងហ្នឹង? ហើយអ្នកណាជាអ្នកដឹកនាំមន្ទីរពេទ្យហ្នឹង?

**ឆ៖** កន្លែងមន្ទីរពេទ្យ អ៎! មែនមន្ទីរពេទ្យ យើងៗ ឥឡូវហ្នឹងយើងគិតថាកន្លែងហ្នឹងមន្ទីរពេទ្យទៅចុះ។ កន្លែងហ្នឹងវាមានទាហានជាអ្នកកាន់កាប់។ ទាហានជាអ្នកកាន់កាប់ហ្នឹង លោកឧត្តមសេនីយ៍ ឃុន សុងសឿង ជាអ្នកកាន់កាប់កន្លែងហ្នឹង គឺជាមេៗនៃកន្លែងវះកាត់ប្រាំហ្នឹង។ គាត់ជាអ្នកៗ ធំជាងគេបង្អស់នៅកន្លែងនុំង ពីព្រោះគាត់ៗទាហានណ៎ាកន្លែងនុំង។ មានបុគ្គលិកធ្វើការច្រើន ពីព្រោះកន្លែងវះកាត់ប្រាំ មិនមែនអ្នកវះប្រាំទេ វាមានអ្នករួមចំណែកក្នុងការវះកាត់ហ្នឹងមួយប្លុកៗហ្នឹងវាច្រើនគ្នា។ លើសពីហ្នឹងទៅទៀត ក្នុងពេលនុំងរដ្ឋបានប្រកាសសុំឲ្យនិស្សិត សុំឲ្យលោកគ្រូពេទ្យ សុំឲ្យនិស្សិតទាំងសាលាៗគ្រូពេទ្យ សាលាអាំងហ្វេរីយ៉េ មកជួយផងដែរនៅកន្លែងនុំង។ ម្ល៉ោះហើយកន្លែងនុំងមានមនុស្សច្រើនមកៗៗធ្វើការ ដែលមកធ្វើហ្នឹងគឺជាធ្វើការជួយ ធ្វើការជួយដោយសាររឿងរបួសច្រើនពេក ដែលគ្រាប់បែកផ្លោងមកពីក្រៅ ធ្លាក់នៅក្នុងភ្នំពេញ។

[១៥:០៧:៥៨]

**ស៖** មុនថ្ងៃ១៧ មេសា ចំពោះលោក តើស្ថានភាពយ៉ាងម៉េចដែរ? តើលោកដឹងពីការដែលខ្មែរក្រហមចូលមកទីក្រុងភ្នំពេញ ឬក៏នៅជុំវិញភ្នំពេញ? តើនៅក្នុងមន្ទីរពេទ្យលោកនោះ លោកមានត្រៀមលក្ខណៈអីទេ ឬក៏មានគេចេញបញ្ជា ឬក៏ជាយោបល់ថាយោបល់ដើម្បីប្រឈម ឬក៏ដោះស្រាយបញ្ហាដែលនឹងមកដល់ទេ? តើមានការរៀបចំណាមួយដែរឬទេ ចំពោះស្ថានភាពនឹងកើតមានឡើងហ្នឹង?

**ឆ៖** នៅក្នុងមន្ទីរពេទ្យមិនមានការរៀបចំថានឹងៗៗទទួលរឿងអ្វីមួយដែលនឹងកើតមានបន្ទាប់ពីថ្ងៃដែលខ្ញុំនៅកន្លែងនុំងទេ មិនមានទេ។ ក៏ប៉ុន្តែថ្ងៃចុងក្រោយ នៅមុនថ្ងៃចុងក្រោយប៉ុន្មានថ្ងៃ សភាព-ការណ៍នៅក្នុងភ្នំពេញពិបាកនឹងរៀបរាប់ ពីព្រោះថាមនុស្សភ័យទាំងអស់គ្នា។ មនុស្សភ័យ ភ័យដោយសារគ្រាប់ធ្លាក់ច្រើនពេក ដោយសារគ្រាប់ផ្លោងមក មនុស្សភ័យរត់ពីក្រៅចូលមកនៅក្នុងក្រុង។ មកនៅក្នុងក្រុងគ្រាប់បែកណា គ្រាប់បែកធ្លាក់វាមានរបួសទាំងអស់ គ្រាប់បែកធ្លាក់មានងាប់ គ្រាប់បែកធ្លាក់មានៗដាច់ដោយមនុស្ស។ ម្ល៉ោះហើយមនុស្សភ័យៗ ភ័យក្នុងសភាពមួយដែលៗៗថា អញងាប់ -- អញធ្លាក់មកកន្លែងហ្នឹង អញងាប់។ ហើយនិងអរ នឹកឃើញថាអរដែល ប្រហែលជាៗនេះហើយ ប្រហែលជាបើកាលណាខ្មែរក្រហមមកជិតៗអីចឹង ប្រហែលជាៗចប់ក្នុងពេលឆាប់ៗហ្នឹងហើយ។ ហើយបើសិន

ណាចប់ ប្រហែលជាលែងមានចម្បាំងហើយ ប្រហែលជាលែងមានចម្បាំងហើយ ប្រហែលជាលែងមានទទួលគ្រាប់បែកទៀតហើយ។ នេះដែលចិត្តរបស់ខ្ញុំបាទ។

[១៥:១០:១៣]

**ស៖** ខ្ញុំមិនដឹងថា ខ្ញុំយល់មិនច្បាស់ ឬក៏យ៉ាងម៉េចទេ ប្រហែលជាមានបញ្ហាបកប្រែហើយមើលទៅ។ តើលោកពិតជានិយាយអំពីអ្វីដែលកើតមានឡើងនៅមុនថ្ងៃ១៧ មេសា ឆ្នាំ៧៥ ដែរឬទេ? គឺថាស្ថានភាពដែលលោកទើបតែរៀបរាប់នេះ គឺថាកើតមានឡើងនៅមុនថ្ងៃទី១៧ មេសា ៧៥ ឬក៏យ៉ាងម៉េច? ព្រោះថា ខ្ញុំយល់អម្បាញ់មិញ តាមរយៈការបកប្រែនោះ ហាក់ដូចជាក្រោយថ្ងៃ១៧ មេសា។

**ឆ៖** គឺថា សំណួរអម្បាញ់មិញនេះ សួរខ្ញុំថា សភាពការណ៍នៅថ្ងៃ មុនថ្ងៃ១៧ ហ្នឹងយ៉ាងដូចម្ដេច? ខ្ញុំឆ្លើយមុនថ្ងៃ១៧ គឺថា នៅក្នុងភ្នំពេញហ្នឹងគឺ ទាំងខ្ញុំ ទាំងគេទាំងអស់នៅក្នុងភ្នំពេញហ្នឹងជាពិសេសខ្ញុំតែម្ដង ដែលខ្ញុំនៅរស់ ហើយខ្ញុំយករឿងហ្នឹងមកនិយាយប្រាប់។ ពេលហ្នឹង យប់ថ្ងៃទី១៦ បើកាលណា ចង់ឲ្យខ្ញុំនិយាយយប់ថ្ងៃទី១៦ ព្រឹកឡើងថ្ងៃទី១៧ ថ្ងៃទី១៦ ខ្ញុំនៅធ្វើការ ខ្ញុំឡើងទៅនៅជាន់ខាងលើ ជាន់ខាង ពីព្រោះបូរីកីឡាវាមានខ្ពស់អ៊ីចេះ វាមើលទៅឃើញ ខ្ញុំមើលទៅជ្រោយ -- មកត្រង់ស្ពានជ្រោយចង្វាឃើញឆេះសន្ធោសន្ធៅ ហើយយប់ហ្នឹងគ្រាប់ផ្លោងធ្លាក់ច្រើន។ ម្ល៉ោះហើយខ្ញុំខ្លួនឯងហ្នឹង ខ្ញុំគិតថាស្ថានការណ៍នឹងចប់ក្នុងពេលឆាប់ៗនេះឯង ហើយមនុស្សភ័យគ្រប់គ្នា ភ័យមិនដឹងជាគ្រាប់ធ្លាក់កន្លែងណាទៀត។ ហើយខ្លួនខ្ញុំ ខ្ញុំភ័យខ្លួនខ្ញុំដែរ ខ្ញុំខ្លាចគ្រាប់ធ្លាក់មកចំកន្លែងខ្ញុំ ហើយខ្ញុំអរដែរបើសិនណាស្ថានការណ៍ហ្នឹងវាត្រូវបញ្ចប់ លែងមានសភាពអ្នកភ័យហ្នឹងតទៅទៀត។

**ស៖** លោកនិយាយអំពីយប់មុនថ្ងៃ១៧ មេសា គឺថាថ្ងៃទី១៦ បើសិនខ្ញុំយល់មិនខុសទេគឺថា ពេលយប់នោះ លោកធ្វើការនៅមន្ទីរពេទ្យ។ ដូច្នេះគឺថា នៅព្រឹកថ្ងៃទី១៧ មេសា លោកនៅមន្ទីរពេទ្យនុ៎ងដែរ។ តើលោកដឹងថាខ្មែរក្រហមនោះ បានចូលមកក្នុងទីក្រុងភ្នំពេញនោះ តាមរបៀបណាដែរ? ហើយពេលចូលមកដំបូងនោះមាន -- កើតមានរឿងអីកើតឡើងដែរ?

[១៥:១៣:១៥]

**ឆ៖** មួយយប់ថ្ងៃទី១៦ គ្នាខ្ញុំដែលធ្វើការនៅក្នុងបូរីកីឡាហ្នឹង បានទទួលអ្នកជំងឺច្រើនក្នុងយប់ហ្នឹងមានជំងឺច្រើនដែលចូល ពីព្រោះគ្រាប់វាធ្លាក់មកច្រើនកន្លែង ម្ល៉ោះហើយការដែលដឹកអ្នកជំងឺមកឡានពេទ្យ ឡានអំប៊ុយឡង់ហ្នឹង បានដឹកមកដាក់កន្លែងហ្នឹងច្រើន ម្ល៉ោះហើយ ខ្ញុំទទួលជំងឺហ្នឹងច្រើន។

ព្រឹកឡើង យប់ហ្នឹងបានសេចក្ដីថា ខ្ញុំគ្រាន់តែដឹង ខ្ញុំឮសូរៗកាំភ្លើង គឺច្រើនកន្លែងណាស់ គឺមិន

ដឹងកាំភ្លើងស្អីៗ គឺវាច្រើនកន្លែង ឮចុងខាងជើង ឮចុងខាងត្បូង ហើយដែលខ្ញុំឮស្គរ កាលណាតែឮស្គរ យើងខ្ញុំនេះ ខ្លួនឯងហ្នឹងចង់ដឹងណាស់ ខ្ញុំអើតទៅមើលខាងលើ ឡើងទៅខាងលើ ខ្ញុំឃើញមានភ្លើងឆេះ ពីព្រោះវាភ្លឺត្រង់ម្ដុំស្ពានជ្រោយចង្វា ឮស្គរគ្រាប់ធ្លាក់ គ្រាប់ធំៗធ្លាក់ខ្លួងៗនៅកន្លែងនុ៎ង ហើយមើលទៅឃើញឆេះ ហើយប្រាកដជាមានឆេះនៅយប់ថ្ងៃទី១៦ ម្ដុំស្ពានជ្រោយចង្វា។ ព្រឹកឡើង ខ្ញុំត្រូវចប់កិច្ចការរបស់ខ្ញុំ ដែលខ្ញុំយាមថ្ងៃទី១៦ ហើយ ខ្ញុំចប់ហើយ ខ្ញុំត្រូវទៅផ្ទះ។ ក៏ប៉ុន្តែអ្នកដែលមកដូរខ្ញុំ មិនទាន់មកដល់ទេ អ្នកដែលដូរខ្ញុំនេះមិនទាន់មកដល់ទេ។ ម្ល៉ោះហើយ ខ្ញុំអត់ទាន់ទៅទេៗ មនុស្សនៅធ្វើការទាំងអស់គ្នា ដោយសារមនុស្សមានរបួសច្រើន មនុស្សនៅច្រើនគ្នាដែរ។ ក៏ប៉ុន្តែដល់ពេលព្រឹកព្រហាមឡើងហ្នឹង ពេលដែលមិនទាន់បានដូរអ្នកដែលមកហ្នឹង មនុស្សដូចថា អ្ហឺ! ភ័យណាស់ៗ វាកាន់តែពិបាកហើយ វាកាន់តែកៀករឿងដែលថាមិនដឹងជាស្អីនឹងបន្ទាប់មកទៀត មិនដឹងយ៉ាងម៉េច។ មនុស្សចាប់ចេញ។ ម្ល៉ោះហើយអ្នកខ្លះនាំគ្នាចេញពីមន្ទីរពេទ្យហ្នឹង។ ចំណែកឯខ្ញុំ ខ្ញុំអត់ទៅណាទេ ពីព្រោះថាកន្លែង អាកន្លែងខ្ញុំហ្នឹង អាអ្នកដែលមកដូរខ្ញុំអត់ទាន់មក។ ម្ល៉ោះហើយខ្ញុំ ខ្ញុំនៅ។

[១៥:១៥:៤២]

**ស៖** តើលោកបានឮ គេនិយាយថាខ្មែរក្រហមបានចូលនៅ -- ចូលទីក្រុងភ្នំពេញនៅពេលណា? តើនៅពេលណាមួយនោះ ជួនថាលោកអាចឃើញខ្មែរក្រហមចូលមកដោយខ្លួនឯង ជួនលោកអាចឮគេនិយាយថា ខ្មែរក្រហមបានចូលមកហើយ តើលោកដឹងតាមរបៀបណាដែរ?

**ឆ៖** ព្រឹកនោះ ខ្ញុំធ្វើការដូចដែលព្រឹកពីម្សិល ហើយថាមានមនុស្សច្រើន មានមនុស្សដូចថាត្រូវរបួសហ្នឹងគេដឹកមកជាបន្តៗ ហើយពេលវេលាកាន់តែផុតមកហើយ ម្ល៉ោះហើយព្រឹកហ្នឹងឮស្គរកាំភ្លើងនៅខាង បើកាលណាខ្ញុំឈរនៅចំពីមុខស្តាតអូឡាំពិក គឺថានៅជ្រុងខាងនេះ។ ឧបមាថាស្តាតអូឡាំពិកអ៊ីចេះ គឺថានៅជ្រុងខាងនេះមានកាំភ្លើង ៗកាំភ្លើងមិនមែនជាកាំភ្លើងបាញ់តតាំងគ្នាទេ មានកាំភ្លើងដូចជាបាញ់ ដូចបាញ់ផាំងៗៗ ច្រើនកន្លែងដែលពីជ្រុងខាងណោះ។

[១៥:១៦:៤២]

រួចហើយពេលនុ៎ងម៉ោងវាបីប្រាំជាងហើយៗ ដល់ប្រាំបីជាង ខ្ញុំៗចង់ មិនដឹងជាយ៉ាងម៉េចទេ ចង់ឃើញដែរ ចង់ឃើញ។ មានកិច្ចការច្រើននៅក្នុងមន្ទីរពេទ្យហ្នឹង ប៉ុន្តែខ្ញុំចង់ឃើញ ៗថាស្អីដែរឮស្គរៗ គេអ៊ុលៗ ស្រែកពីខាងក្រៅៗ។ ខ្ញុំចេញមកខាងក្រៅ ខាងក្រៅបុរីកីឡាពីច្រកហ្នឹង ចេញមកវាមានច្រកមកពីខាងត្បូង ហើយខ្ញុំចេញទៅច្រកពីខាងត្បូងហ្នឹង គឺខ្ញុំអើតទៅតាមរបងហ្នឹង ខ្ញុំឃើញទាហានខ្មែរ

ក្រហមដែលដើរជាជួរពីខាងលិចមក ហើយនៅឯឆ្ងាយពីខាង ពីជួរហ្នឹង ហើយដែលខ្ញុំមកដល់ហ្នឹង វាមានអ្នកខ្លះផុតទៅមុខហើយ ហើយមានអ្នកខ្លះហ្នឹងដើរពីក្រោយមក។ ហើយនៅចុងខាងក្រោយនោះដែលខ្ញុំមើលឃើញពីចម្ងាយ មានរថក្រោះមួយដែលមានមនុស្សនៅលើនុំងច្រើន។ ហើយមានលើកកាំភ្លើងឡើងលើអ៊ីចេះ ហើយលើហ្នឹងមានអ្នកដែលមិនមែនជាៗយោធាខ្មែរក្រហមហ្នឹងឃើញនៅលើឡាន លើអាៗ -- មិនដឹងជាអ្នកណាទេ ប៉ុន្តែអ្នកខ្លះអត់មានអាវនៅលើនុំងដែរ។ ហើយក្រុមអ្នកដែលខ្មែរក្រហមដែលខ្ញុំឃើញជាលើកដំបូងហ្នឹង ដើរកាត់អបៗបុរីកីឡាហ្នឹង អាផ្លូវខាងត្បូង តម្រង់ទៅខាងកើតៗ។ នេះដែលខ្ញុំឃើញ។

[១៥:១៨:២៣]

**ស៖** នៅពេលដែលលោកនៅខាងក្រៅមន្ទីរពេទ្យហ្នឹង គឺថានៅលើផ្លូវនោះ ហើយពេលនោះលោកឃើញខ្មែរក្រហមដើរកាត់នោះ។ បន្ទាប់មកលោកបានធ្វើអី ហើយលោកបាននិយាយយ៉ាងម៉េចដែរ? តើមានបុគ្គលិកផ្សេងទៀតនៃមន្ទីរពេទ្យនៅទីនោះ ដែលចេញជាមួយលោកដែរឬទេ? ពេលដែលឃើញខ្មែរក្រហមហើយ លោកត្រឡប់ចូលមន្ទីរពេទ្យវិញ ឬក៏យ៉ាងម៉េច?

**ឆ៖** នៅពេលដែលខ្ញុំចេញមកក្រៅ ខ្ញុំមើលនៅតាមរបង ពីព្រោះវាមិនជាឆ្ងាយប៉ុន្មានទេពីកន្លែងបុរីកីឡា និងរបង វានៅកៀកគ្នាហ្នឹងឯង។ ពេលដែលខ្ញុំដើរទៅ ឃើញនៅពីចម្ងាយ ឃើញទ័ពដើរចុះមកអ៊ីចេះ ហើយនៅពេលនុំង ខ្ញុំឃើញខ្មែរក្រហមមួយ ឃើញទាហានខ្មែរក្រហមមួយចូលមកក្នុងបុរីកីឡា ចូលមកតាមច្រកខាងមុខហ្នឹងឯង។ ម្នាក់មានកាន់កាំភ្លើង ស្លៀកខ្មៅ ស្លៀកខោខ្មៅ អាវខ្មៅមានស្បែកខ្មៅ ស្បែកជើងកង់ឡានខ្មៅ ពាក់មួក ពាក់មួកកាតិប ហើយមានកាំភ្លើងនៅនឹងដៃ ដើរចូលមកក្នុងបុរីកីឡា។ ដើរចូលមកបុរីកីឡាហ្នឹង ក្នុងបុរីកីឡាហ្នឹង វាមានផ្ទះ មានអគារមួយនៅខាងឆ្វេងដៃបើកាលណា យើងចូលមកពីផ្លូវខាងត្បូង វានៅខាងស្តាំដៃ។ បើកាលណាយើងទៅពីខាងនេះ វានៅខាងឆ្វេងដៃ។ ខាងក្រោយអគារហ្នឹង វាមានបឹងមួយៗ។ ដល់ខ្មែរ -- ទាហានខ្មែរក្រហមដែលចូលមកហ្នឹងក៏មកដល់ៗទន្ទឹមនឹងអគារហ្នឹង ដោយសារអគារហ្នឹងខាងក្រោយនោះវាមានបឹង ទាហានខ្មែរក្រហមហ្នឹងក៏បោះគ្រាប់បែកមួយចូលក្នុងបឹងនោះក្លួង មិនដឹងជាគាត់រមាស់ដៃអីគាត់ ខ្ញុំក៏អត់យល់ ក្លួងបោះគ្រាប់បែកមួយ។ ហើយគាត់ក៏ចូលទៅក្នុងអគារ អគារអ្នកយាមនៅខាងមុខហ្នឹង ដែលៗខ្ញុំជម្រាបអម្បាញ់មិញនេះ គឺថានៅថាៗនៅខាងឆ្វេងដៃ បើកាលណាខ្ញុំចូលក្នុងទៅ ដែលក្នុងហ្នឹងមានអ្នកយាមនៅក្នុងនេះឯង មានមនុស្សប្រហែលជា៧, ៨នាក់នៅក្នុងហ្នឹងជាគ្រួសារ ហើយទាហានហ្នឹង ទាហានខ្មែរក្រហម

នោះចូលទៅក្នុងនុ៎ង ខ្ញុំមានបំណងចង់សួរៗទៅ សួរដូច សួរ ពីព្រោះខ្ញុំអត់ដែលបាននិយាយជាមួយៗទាហានខ្មែរក្រហម ខ្ញុំអត់ដែលបានៗនិយាយទេ ខ្ញុំធ្លាប់បានមើលៗខ្មែរក្រហមហ្នឹងឈឺ អង្គាល់នៅៗខ្ញុំនៅៗព្រះកេតុមាលា ពីព្រោះវាមានរបួសខ្មែរក្រហមវាយកមកដាក់ ខ្ញុំធ្លាប់មើលគាត់ ខ្ញុំធ្លាប់ព្យាបាល។ ប៉ុន្តែមកហ្នឹងខ្ញុំចង់សួរ ខ្ញុំចង់ណាស់ ប៉ុន្តែខ្ញុំអត់មានបាននិយាយជាមួយគាត់ទេ គាត់ចូលទៅក្នុងផ្ទះនុ៎ងៗហើយខ្ញុំនេះខ្ញុំចង់ៗជួបណាស់ ហើយខ្ញុំនៅចាំៗ ប្រហែលជាជិតកន្លះម៉ោង ហើយទាហានហ្នឹងក៏ចេញមកវិញ ក៏ចេញពីផ្ទះហ្នឹងមកវិញ។ ចេញពីផ្ទះហ្នឹងមកវិញ ក៏ខ្ញុំឈរចំមាត់ទ្វារ ខ្ញុំមើល គាត់ចេញមកវិញ គាត់រឹងដើរទៅៗក្រៅវិញភ្លាម ដែលគ្នាគាត់ដែលដើរជាជួរហ្នឹងនៅតែជួរបន្តទៅៗមុខទៀត។

[១៥:២១:៤២]

នៅក្នុងផ្ទះដែលទាហានខ្មែរដែលចូលទៅក្នុងនុ៎ង វាមានកូនក្មេងស្រីអាយុប្រហែលជា១៨-១៩ឆ្នាំពេលនុ៎ងខ្ញុំឃើញតាមមាត់ទ្វារ ក្មេងស្រីនុ៎ងយកសារុងធ្វើចងអីចេះ ហើយយំពីរនាក់។ ខ្ញុំនឹកក្នុងចិត្តភ្លាមថាមានហេតុអីមិនស្រួលដូចតែមនុស្សប្រុសទាំងអស់គិតអ៊ីចឹង។ ខ្ញុំភ័យ ខ្ញុំត្រឡប់មកមន្ទីរពេទ្យវិញ។ ម្ល៉ោះហើយខ្ញុំអត់មានបានសួរទាហានខ្មែរក្រហមមួយម៉ាត់ណា ដែលខ្ញុំចង់នោះ។

**ស៖** លោកត្រឡប់ចូលទៅក្នុងមន្ទីរពេទ្យ ហើយលោកចូលទៅកន្លែងប្លុកដែលលោកធ្វើការហើយនៅពេលនោះ គឺបុគ្គលិកថែទាំជំងឺនៅទីនុ៎ងដដែល ហើយតើលោកធ្វើអីទៅនៅពេលនុ៎ង? នៅក្នុងចម្លើយរបស់លោកនោះ គឺថាលេខយោងដដែលហ្នឹង ខ្ញុំកំពុងតែវះកាត់ នេះគឺជាការបកប្រែជាភាសាអង់គ្លេស ប្រហែលជាមិនត្រូវទាំងស្រុងទេ អ៎! ជាបារាំងប្រហែលជាមិនត្រូវទាំងស្រុងទេ។ អ៊ីចឹងបានន័យថាលោកត្រឡប់ចូលទៅធ្វើការវិញ ហើយៗប្រហែលជាជួយវះកាត់អ្នកជំងឺមុននឹងចាកចេញពីមន្ទីរពេទ្យ តើអ៊ីចឹងមែនទេ?

[១៥:២៣:១៨]

**ឆ៖** ពេលខ្ញុំត្រឡប់មកវិញកិច្ចការនៅក្នុងបុរីកីឡាហ្នឹង អាកន្លែងវះ វាគេធ្វើបន្តៗអ៊ីចេះវាប្រាំនៅក្រោមគេដាក់គ្រែប្រហែលជា៥០គ្រែ។ ប្រហែលជា៥០គ្រែនៅផ្ទាល់នឹងដីអ៊ីចេះ។ ៥០គ្រែវែងបណ្ដោយពីជើងទៅត្បូង ហើយវាមានប្រលោះៗគ្រែហ្នឹងពេញទាំងអស់ ហើយមនុស្សនៅសល់ដាក់នៅតាមៗ តាមមាត់ទ្វារខាងៗអ៊ីចេះ សុទ្ធតែមនុស្សដែលមកថ្មីៗ។ នៅពេលដែលខ្ញុំមកដល់ហ្នឹង គឺថាអ្នកថ្មីៗនេះគេមកដាក់នៅៗគរនៅនេះ។ នៅគរអាកន្លែងខាងមុខហ្នឹង មានក្មេង មានចាស់ មកស្អីអ៊ីចឹងទៅ។

នៅក្នុងបុរីកីឡា ខ្ញុំៗសូមជម្រាបអ៊ីចេះ នៅក្នុងបុរីកីឡាហ្នឹងអ្នកដែលៗថ្ងៃទី១៧ ខ្ញុំជម្រាបអំពីអ្វី

ដែលខ្ញុំឃើញថ្ងៃទី១៧, ថ្ងៃទី១៦ និងថ្ងៃទី១៧ ព្រោះជាថ្ងៃដែលខ្ញុំធ្វើការ ថ្ងៃដែលខ្ញុំយាម។ ថ្ងៃទី១៧ហ្នឹង ខ្មោចដែលស្លាប់នៅក្នុងបុរីកីឡា ដែលយកមកហើយស្លាប់ អត់ទាន់មានអ្នកណាយកចេញក្រៅទេ នៅលើក្រាលដាងខាងលើ នៅខាងលើ ហើយខាងក្រោមក៏អ្នក អ្នករបួសដាក់តាមៗនេះទៅ ពីព្រោះដោយសារវាៗចំនួនច្រើន។

[១៥:២៤:៣២]

ចំណែកឯខាងក្រោមមានអ្នកដែលមកថ្មីៗ ពេលដែលខ្ញុំមកដល់ពីៗឃើញហេតុការណ៍ដែលខ្ញុំឃើញដែលខ្ញុំជម្រាបអម្បាញ់មិញនេះ ខ្ញុំឃើញក្មេងស្រីមួយ ដែលធ្លាយពោះៗ -- សូមទោសពីព្រោះខ្ញុំ -- សូមទោសដោយសារខ្ញុំៗពេលខ្ញុំនិយាយហ្នឹង ខ្ញុំរស់ពេលនុ៎ងឡើងវិញ។ ក្មេងតូចហ្នឹងវាធ្លាយពោះ ប្អូនវាស្លាប់ គេយកមកដាក់នៅកន្ទេលខាងមុខ។ ហើយវាធ្លាយពោះ អាយុប្រហែល៨ឆ្នាំ។ ធ្លាយពោះ ពោះវៀនវាចេញមកក្រៅ។ ខ្ញុំទៅៗចូលទៅក្នុងប្លុកយកចានដែកៗនៅប្លុក ចានដែកធ្វើពីដែកណ៎ា ចានដែកស្អាតនុ៎ង យកមក ខ្ញុំដាក់ស៊ីរ៉ូមហ្វីហ្សូណូហ្សិក ទៅខាងក្នុងហ្នឹង រួចហើយខ្ញុំជួយកូនហ្នឹងដោយរុញអាពោះវៀនហ្នឹងចូលក្នុង ពីព្រោះពោះវៀនវាចេញក្រៅ។ រុញពោះវៀនហ្នឹងចូលក្នុង រួចហើយខ្ញុំៗក៏បិទពោះហ្នឹង បិទពោះហ្នឹងទៅវិញ ហើយៗមុខកូនហ្នឹងវានៅនឹងកូនខ្ញុំរហូតទល់តែឥឡូវ។

ម្ល៉ោះហើយខ្ញុំធ្វើបន្តកិច្ចការផ្សេងទៀត ដែលវាមានអ្នក-- មានម្នាក់នោះកំបុតជើង គេៗទើបយកមក ហើយគេយកចូលប្លុក ចេញមកវិញរុំហើយវាឃើញឈាមហូររហាចនៅៗនៅតាមៗក្បាលជង្គង់ ហើយក្នុងពេលនុ៎ងៗ ក្នុងពេលម៉ោង ពេលហ្នឹងម៉ោងប្រហែលជាៗជាងប្រាំបួនហើយ ម៉ោងប្រាំបួនជាងជិតដប់ ម៉ោងប្រាំបួនជិតដប់។ ពេលនុ៎ង ដូចៗមិនមានអ្នកណាដឹកមកទៀតទេ អ្នកដែលនៅប៉ុន្មានហ្នឹង នៅតែប៉ុណ្ណឹង ហើយអ្នកធ្វើការចាប់ផ្តើមរត់ចេញ ចាប់ផ្តើមចេញទៅ ចេញចោលកន្លែងពេលនុ៎ងដោយៗ ដោយភ័យៗខ្លាច មិនដឹងជាទៅយ៉ាងម៉េច ឮសូរកាំភ្លើង ឮសូរគ្រាប់បែកខ្ទរខ្ទួងនៅខាងមុខអំមិញនេះផង ម្ល៉ោះហើយមនុស្សរត់ចេញ។

[១៥:២៧:១៤]

ហើយអ្នកជំងឺនៅហ្នឹងទាំងអស់ អ្នកខ្លះក៏នាំគ្នា អ្នកដែលថារបួសល្មមៗហ្នឹង គ្រួសារនាំយកទៅនាំយកចេញដោយមិនមានថា ពេទ្យដឹកយកទៅផ្ទះអី អត់មានទេ មនុស្សហ្នឹងចេញៗដោយៗមធ្យោបាយខ្លួនឯង។ ហើយចំពោះកូនមួយដែលខ្ញុំឃើញហ្នឹង ម្តាយឪពុក -- ខ្ញុំសួរវា ម្តាយឪពុកវាស្លាប់នៅកន្លែងត្រូវគ្រាប់ ត្រូវធ្លាក់គ្រាប់ កន្លែងធ្លាក់គ្រាប់ ហើយវានៅរស់ ហើយរស់ៗតែម្នាក់ឯង ធ្លាយពោះ

ទៀត។ ប្អូនវាដែលស្លាប់ដាក់នៅកន្ទេល។ មកហើយ ខ្ញុំៗ ខ្ញុំនៅធ្វើការៗ ព្រោះខ្ញុំៗ ខ្ញុំទៅណា អួយយ៉ូយ ខ្ញុំពេលហ្នឹងភ័យផង ស្ទើផង ម្ល៉ោះហើយអាមនុស្សច្រើនផង មិនដាច់ចិត្តនឹងទៅ សុទ្ធតែៗរបួស។ ម្ល៉ោះហើយខ្ញុំនៅធ្វើការ។

**ស៖** លោកបានបន្តធ្វើការទៀត លោកមិនមាននៅតែម្នាក់នោះទេ ទោះបីជាបុគ្គលិកមួយចំនួននោះបានចាកចេញពីមន្ទីរពេទ្យហើយ។ ហើយតើនៅ -- តើលោកចេញពីមន្ទីរពេទ្យនៅពេលណាដែរ? ហើយដឹងថាត្រូវតែចេញពីមន្ទីរពេទ្យ ឬក៏ទីក្រុងហ្នឹងនៅពេលណា? អ្នកណាជាអ្នកបញ្ជាលោក? គឺថានៅពេលខ្មែរក្រហមចូលមកដល់ក្នុងមន្ទីរពេទ្យតែម្តង ឬក៏មានបុគ្គលិកផ្សេងទៀត ដែលបានផ្តល់ដំណឹងឲ្យលោកថាត្រូវតែចេញពីមន្ទីរពេទ្យនេះ?

[១៥:២៩:០៦]

**ឆ៖** នៅពេលបន្ទាប់នុ៎ង មានអ្នកដែលចុះមកពីប្តូក ចុះមកពីខាងលើ ចុះមកពីកន្លែងវះ ចុះពីកន្លែងវះ ហើយនិងអ្នកដែលធ្វើការនៅជ្រុងខាងក្រោយ នៅជ្រុងខាងក្រោយនៃអគារ អាបណ្តោយគ្រែហ្នឹងវាវែងទៅខាងត្បូង ហើយអ្នកនៅខាងត្បូងហ្នឹងៗមិនដឹងជាៗអ្នកណាដែលខ្ញុំៗ ខ្ញុំអត់មាននឹកឃើញថាខ្ញុំអត់មាននឹកឃើញថាៗជាមិត្តភក្តិនិយាយ ឬក៏ស្ទើទេ មានអ្នកដែលនិយាយនៅខាងក្រោយហ្នឹងថាយោធាប្រាប់ថាឲ្យចេញពីមន្ទីរពេទ្យ។ អ្នកពីខាង ចុះពីប្តូកមក ចុះពីកន្លែងវះមកនិយាយដូចគ្នាថាឲ្យចេញពីមន្ទីរពេទ្យ ឲ្យនាំគ្នាចេញពីមន្ទីរពេទ្យៗ ឲ្យចេញពីមន្ទីរពេទ្យពីព្រោះមានទម្លាក់គ្រាប់បែក មានអាមេរិកាំងទម្លាក់គ្រាប់បែក។ នេះជាៗជាទី១ ដែលខ្ញុំឮនៅក្នុងបុរីកីឡា។ ពេលនុ៎ងប្រហែលជាម៉ោងជិតដប់ហើយ។

[១៥:៣០:០៨]

**ស៖** ហើយនៅពេលនោះ តើលោកធ្វើអ្វីដែរទៅ?

**ឆ៖** ទី១ ខ្ញុំគិតទៅលើកូនក្មេងនោះឯង កូនក្មេងដែលខ្ញុំមើលឃើញថា ខ្ញុំអត់ទាន់បានបំពេញកិច្ចឲ្យបានចប់សព្វគ្រប់ទៅលើកូនក្មេងនុ៎ង តើខ្ញុំយកវាដាក់ទៅមន្ទីរពេទ្យណា? ពីព្រោះកន្លែងហ្នឹងមិនមែនកន្លែងមន្ទីរពេទ្យសម្រាប់ទទួលមើលជំងឺហ្នឹងចប់រហូតទេ។ វាត្រូវទៅដាក់នៅមន្ទីរពេទ្យ ដូចជាមន្ទីរពេទ្យព្រះកេតុមាលា មន្ទីរឫស្សីកែវ អីអ៊ីចឹងទៅ។ ប៉ុន្តែខ្ញុំ ខ្ញុំគិតរឿងៗៗកូនហ្នឹងឯង តើខ្ញុំធ្វើៗៗយ៉ាងម៉េចៗ? ហើយពេលនុ៎ង ដែលឮថាឲ្យចេញ ឮឲ្យចេញរួចហើយពេលហ្នឹង ដែលខ្ញុំគិតថា ហើយចុះប្រពន្ធ ហើយខ្ញុំធ្វើម៉េចនេះ? ខ្ញុំទៅៗៗត្រូវតែទៅជួបប្រពន្ធខ្ញុំ។ តាំងតែពីព្រឹកខ្ញុំចង់ទៅ ព្រោះខ្ញុំមិនដាច់ចិត្តសោះ

ដោយសាររបួសច្រើនពេក ខ្ញុំចេះតែនៅ។ ឥឡូវហ្នឹងខ្ញុំត្រូវចេញទៅរកប្រពន្ធខ្ញុំ ម្ល៉ោះហើយពេលហ្នឹងខ្ញុំមិនដឹងធ្វើម៉េច ខ្ញុំមិនដឹងធ្វើម៉េចនៅក្នុងស្ថានភាពដែលខ្ញុំឃើញនៅក្នុងប្រហែលម៉ោងដប់ហ្នឹង ដែលអ្នកជំងឺនៅៗទាំងអស់ ហើយតម្រូវឲ្យៗមនុស្សចេញពីមន្ទីរពេទ្យ។

[១៥:៣១:២៤]

ក៏ប៉ុន្តែខ្ញុំមានចិត្តមួយនឹកដែរ ខ្ញុំហ្នឹងខ្លួនឯងមានចិត្តមួយនឹកដែរថា អើ! បើសិនណាថាចេញពេលខ្មែរក្រហមមកដល់ប្រាកដជាគេទទួលមើលជំងឺ មើលអ្នកឈឺហ្នឹងទៅទៀតហើយ។ មានចិត្តមួយនឹកដែរ នឹកអ៊ីចឹងដែរៗ។ ម្ល៉ោះហើយកាលដែលថា អាណិតអាសូរស្រណោះទៅលើកូនមួយដែលមុខវានៅនឹងខ្ញុំរហូតទាល់សព្វថ្ងៃ ដូចជាឲ្យខ្ញុំរយាលបន្តិចដែរ។ មួយទៀត ខ្ញុំនេះ ខ្ញុំត្រូវទៅរកប្រពន្ធខ្ញុំ ខ្ញុំមានប្រពន្ធ ប្រពន្ធខ្ញុំពោះធំ ៨ខែ។ ម្ល៉ោះហើយខ្ញុំត្រូវរកមធ្យោបាយដើម្បីទៅយកប្រពន្ធខ្ញុំ ទៅជួបប្រពន្ធខ្ញុំបាទ។ ម្ល៉ោះហើយខ្ញុំមិនដឹងធ្វើម៉េច ពេលនុ៎ងអ្នកដែលនៅក្នុងមន្ទីរពេទ្យហ្នឹង រុញគ្រែពេទ្យហ្នឹងចេញមកក្រៅ រុញគ្រែពេទ្យដែលអ្នកជំងឺនៅក្នុងពេលហ្នឹង។ អ្នកជំងឺដេកនៅលើពេទ្យ នៅលើគ្រែ ហើយមានអ្នកជំងឺរុញៗ ចេញមក។ មិនមែនទាំងអស់ទេ ក៏ប៉ុន្តែមួយដែលបន្ទាប់ពីខ្ញុំដើរចេញមក។

[១៥:៣២:២៣]

ចំណែកឯ មីកូនស្រីដែលខ្ញុំជម្រាបៗៗអំមិញនេះ ខ្ញុំមានកម្មមានពារហ្នឹងវារហូត ពីព្រោះវានៅក្នុងមុខខ្ញុំរហូត។ វាចាប់អាវខ្ញុំ វាថាឲ្យយកវាទៅផង វាចាប់អាវខ្ញុំជាប់។ ខ្ញុំមិនដឹងធ្វើម៉េចៗៗៗទេ។ ម្ល៉ោះហើយមុខវាហ្នឹងខ្ញុំនៅមើលឃើញវារហូតទល់ឥឡូវហ្នឹង។ ខ្ញុំទៅរកប្រពន្ធខ្ញុំ ប្រពន្ធខ្ញុំវានៅជ្រុងខាងណោះ នៅជ្រុង -- នៅនុ៎ង បើត្រូវចេញពីបុរីកីឡាទៅជ្រុងខាងៗជើងឆៀងខាងកើត ពីព្រោះប្រពន្ធខ្ញុំនៅផ្លូវប៉ាស្ទ័រ នៅបណ្ណាល័យប៉ាស្ទ័រ នៅនុ៎ង។ ម្ល៉ោះហើយខ្ញុំរត់ទៅខាងនុ៎ងៗ កន្លែងនុ៎ងកំពុងតែបាញ់ផ្លុងៗៗ មិនដឹងជាបាញ់ស្អីនៅកន្លែងនុ៎ង។ បាញ់ផ្លុងៗៗ មនុស្សរត់ផាយពីនុ៎ងមក ថាទៅមិនបានទេគេបាញ់ងាប់ឥឡូវ ទៅមិនបានទេគេបាញ់ងាប់ ទៅមិនបានទេគេបាញ់ងាប់ឥឡូវ។ មនុស្សរត់មកខាងត្បូង ពេលនុ៎ងហើយដែលគេប្រាប់ថាឲ្យទៅរកខាងៗផ្លូវជាតិលេខ១។ ម្ល៉ោះហើយខ្ញុំមិនដឹងជាឆ្ងៀតអាម៉េចទៅបានជួបប្រពន្ធ ទៅជួបប្រពន្ធខ្ញុំដែលនៅៗផ្លូវប៉ាស្ទ័រហ្នឹង។ ម្ល៉ោះហើយខ្ញុំរត់ជាមួយគេជាមួយឯង ចេញតាមផ្លូវខាងៗត្បូងបុរីកីឡាទៅរកផ្លូវទៅៗផ្លូវជាតិលេខ១។

[១៥:៣៣:៥៥]

ប៉ុន្តែផ្ទះខ្ញុំនៅ មែនទែននេះវានៅខាងត្បូង អ៎! វានៅខាងៗខាងកើតវត្តមហាមន្ត្រី ម្ល៉ោះហើយខ្ញុំ

ទៅឆ្លងកាត់ផ្ទះដែលខ្លួនឯងជួលនៅនោះ ឆ្លងផ្ទះនុ៎ងដែរ ចូលក្នុងផ្ទះនុ៎ង។ ខ្ញុំបានយកអាវប្រពន្ធខ្ញុំចេញពីផ្ទះ បានអាវប្រពន្ធខ្ញុំមួយយកទៅជាមួយ តែប៉ុណ្ណោះឯង។

**ស៖** លោក មាស សារ៉ាន់ បើសិនជាខ្ញុំយល់មិនខុសទេ គឺថាចំពោះអ្នកដែលមានវត្តមាននៅទីនេះនោះ យើងមិនទាន់យល់ច្បាស់ទេថា ហេតុអ្វីបានជាប្រពន្ធលោកនៅផ្លូវ៥១ ហើយផ្ទះរបស់លោកនៅសង្កាត់ផ្សេងវិញទៅវិញ ថានៅខាងត្បូងភ្នំពេញ។ តើលោកអាចពន្យល់បានទេថា ហេតុអ្វីបានជាភរិយារបស់លោកនៅភាគខាងជើងនៃទីក្រុងភ្នំពេញ នៅពេលនុ៎ង នៅពេលយប់ថ្ងៃ១៦ ហើយនិងព្រឹកថ្ងៃទី១៧មេសានោះ ហេតុអីក៏មួយនៅខាងត្បូង មួយទៀតនៅខាងជើង?

**ឆ៖** បើគិតពីចម្ងាយ វាមិនមែនឆ្ងាយគ្នាប៉ុន្មានទេ វត្តមហាមន្ត្រីទៅផ្លូវប៉ាស្ទ័រ។ ក៏ប៉ុន្តែយប់នុ៎ងខ្ញុំយាម ប្រពន្ធខ្ញុំ ខ្ញុំរស់នៅនៅក្នុងផ្ទះជួលមួយនៅខាងវត្តមហាមន្ត្រីហ្នឹង តែពីរនាក់ប្ដីប្រពន្ធទេ។ យប់ខ្ញុំយាម ខ្ញុំមិន១ទុកប្រពន្ធខ្ញុំឲ្យនៅម្នាក់ឯងទេ គ្នា១ពោះធំផង រួចហើយក៏យកទៅដាក់ផ្ទះបងប្អូនខ្ញុំដែលនៅផ្លូវប៉ាស្ទ័រ ពីព្រោះខាងនុ៎ងមានបងប្អូននៅនោះឯង ហើយបងប្អូនខ្ញុំមួយហ្នឹងមានទទួលបងប្អូនច្រើនទៀតមកនៅជាមួយ មិនមែនតែម្នាក់ ប៉ុន្មានគ្រួសារនៅនឹងផ្ទះនុ៎ង។ ម្ល៉ោះហើយប្រពន្ធខ្ញុំហ្នឹង ខ្ញុំយកទៅដាក់នុ៎ង ដល់ពេលនឹកថាពេលស្អែកឡើងខ្ញុំទៅយកប្រពន្ធមកនៅផ្ទះខ្លួនខ្ញុំវិញ ដូចដែលសព្វមួយដង។ ត្រង់ហ្នឹងហើយដែលខ្ញុំ ហេតុអីបានថាខ្ញុំយកប្រពន្ធទៅដាក់កន្លែងនុ៎ង។

[១៥:៣៦:០៩]

**ស៖** សូមអរគុណ។ ដូច្នេះលោកព្យាយាមមិនបានជោគជ័យ ព្រោះថាគេបង្ខំ គេរាំងមិនឲ្យលោកទៅផ្ទះដែលប្រពន្ធលោកស្នាក់នៅ។ ហើយលោកក៏បានត្រឡប់មកសង្កាត់របស់លោកវិញ គឺថានៅផ្ទះលោកវិញ។ តើស្ថានភាពនៅក្នុងស្ថានភាពលោកនោះ ពេលនោះយ៉ាងម៉េច ថាកាលនោះប្រហែលជាម៉ោង ប្រហែលជាដប់ពីរ ឬក៏ម៉ោងមួយរសៀលហើយ បើតាមការរៀបរាប់របស់លោកហ្នឹង។ តើញាតិជិតខាងរបស់លោកនៅទីនោះនៅឡើយទេ? ហើយមានខ្មែរក្រហមនៅក្នុងសង្កាត់នោះទេ? តើលោកអាចរៀបរាប់ដោយខ្លីបានទេអំពីអ្វី ដែលបានកើតឡើងនៅក្នុងសង្កាត់លោកនោះ?

**ឆ៖** នៅពេលដែលខ្ញុំគេចពីមនុស្សដែលរត់ពីជ្រុងបុរីកីឡាខាងជើងឆៀងខាងកើត មានស្គរ -- មានបាញ់ផាំង១១ មិនជាគេបាញ់ស្អី ខ្ញុំអត់មើលឃើញ ប៉ុន្តែខ្ញុំឮ ហើយមនុស្សរត់ចេញថា កុំឲ្យទៅខាងនុ៎ង! គេមិនឲ្យទៅខាងនុ៎ងទេ! គេសម្លាប់។ ម្ល៉ោះហើយខ្ញុំនេះ ខ្ញុំខ្លាច ខ្ញុំរត់មកខាងនេះ ទៅដល់ផ្ទះខ្ញុំដែលនៅខាងកើតវត្តមហាមន្ត្រី។ នៅពេលដែលខ្ញុំទៅដល់ខាងកើតវត្តមហាមន្ត្រី ពេលនុ៎ងម៉ោងវាជាង

ដប់ហើយ ជាងដប់ៗថ្ងៃព្រឹកហ្នឹង។ នៅពេលដែលខ្ញុំទៅដល់ហ្នឹង កន្លែងហ្នឹងវាស្ងាត់មនុស្ស រត់បាត់អស់ហើយ មនុស្សទៅបាត់អស់ហើយ មនុស្សនៅមួយជួរជិតផ្ទះខ្ញុំហ្នឹងទៅបាត់អស់រលីងៗ។ ខ្ញុំចូលទៅក្នុងផ្ទះខ្លួនឯង សោរផ្ទះខ្ញុំចាក់ ផ្ទះខ្ញុំមិនដឹងថាយកៗអីទេ ពីព្រោះថានៅពេលៗដែល នៅតាមផ្លូវៗ ដែលទៅដល់ផ្ទះហ្នឹង គេអ្នកដែលដើរតាមហ្នឹង អ្នកដែលដើរនៅតាមៗផ្លូវហ្នឹង ដែលកំពុងប្រទូស្តប្រទាំងមនុស្សរត់ឆ្វេចឆ្វាចហ្នឹង ថាគេឲ្យចេញៗ ឲ្យចេញ៣ថ្ងៃៗៗ ទៅឲ្យរហ័ស ពីព្រោះអាមេរិកាំងទម្លាក់គ្រាប់បែកនៅលើភ្នំពេញ។

[១៥:៣៨:១៤]

ម្ល៉ោះហើយ វាៗៗខ្ញុំ ឮអ៊ីចឹងខ្ញុំភ័យៗ ទម្លាក់គ្រាប់បែក ម្ល៉ោះហើយខ្ញុំចូលក្នុងផ្ទះ យកបានតែអាវប្រពន្ធមួយគត់ៗ ហើយអាវហ្នឹងខ្ញុំយកដាក់តាមខ្លួនរហូតទៅដល់ស្រុកប្រពន្ធខ្ញុំ។ នៅពេលនុ៎ងបាត់មនុស្សអស់ហើយ ម្ល៉ោះហើយខ្ញុំចេញពីនុ៎ងគឺថាគេចធ្វើដំណើរឆ្ពោះទៅតាមហ្វូងមនុស្សដែលរត់ ដែលបណ្តើរបន្តៗៗទៅអ៊ីចឹង ដើម្បីទៅដល់ផ្លូវជាតិ អ៎! ទៅដល់ផ្លូវមុនីវង្សៗ។ ដើរហ្នឹងគេចៗៗ អ៊ីចឹង ហើយចំពោះទាហានខ្មែរក្រហម ទាហានខ្មែរក្រហមប្រសេចប្រសាច ដើរៗៗអ៊ីចឹង ប៉ុន្តែអត់មានៗៗ និយាយអីជាមួយៗៗយើង គេមានកិច្ចការគេ ដែលខ្ញុំអត់ដឹង។ ហើយពេលនោះទាហានហ្នឹងចេះតែដើរទៅខាងៗកើត ឃើញដើរតែទៅខាងកើតអ៊ីចេះ។ ម្ល៉ោះហើយខ្ញុំហ្នឹង គឺទាំងមនុស្សទាំងហ្វូងហ្នឹង ក៏ពីព្រោះគេប្រាប់ ពីព្រោះទាហាននៅពេលដែលទាហានខ្មែរក្រហមចូលមកក្នុងពេលដែលខ្ញុំឃើញ ដែលខ្ញុំឃើញថ្ងៃនុ៎ង គឺថាទាហានកាន់កាំភ្លើង មិនមែនកាន់កាំភ្លើងដាក់នៅនឹងស្មាក្រោយខ្នងទេ កាន់កាំភ្លើងធ្វើអ៊ីចេះកាន់កាំភ្លើងអ៊ីចេះៗ កាន់កាំភ្លើងអ៊ីចឹង ច្រើន ភាគច្រើនកាន់កាំភ្លើងអ៊ីចឹងៗ មិនដឹងជាចង់បាញ់ស្អីពេលនុ៎ងខ្ញុំមិនដឹង។ ក៏ប៉ុន្តែដែលមានឮសូរកាំភ្លើងបាញ់ហ្នឹងវាច្រើនកន្លែង។ បាញ់មិនមែនបាញ់របៀបប្រយុទ្ធគ្នាគឺថាដូចបាញ់ឡើងលើ ឬក៏បាញ់ ដែលខ្ញុំៗ -- ប៉ុន្តែដែលខ្ញុំឮ។ រួចហើយខ្ញុំឃើញមនុស្សហ្នឹងច្រើនអ៊ីចឹងខ្ញុំក៏ធ្វើដំណើរតាមគេជាមួយគេជាមួយឯង រហូតដែលខ្ញុំៗឡើងទៅជួបមនុស្សដែលៗ ដល់ផ្លូវមុនីវង្សមនុស្សណែននៅក្នុងផ្លូវមុនីវង្សហ្នឹង លើផ្លូវមុនីវង្សមនុស្សណែននៅលើផ្លូវមុនីវង្សហ្នឹង មនុស្សណែននៅលើផ្លូវនុ៎ង ចង្អៀត។

**ស៖** លោក មាស សាវ៉ាន់ លោកចេញពីផ្ទះលោក ហើយពេលនោះញាតិមិត្តជិតខាងរបស់លោកនោះចេញអស់ទៅហើយ ហើយលោកទៅដល់លើផ្លូវមុនីវង្ស លោកឃើញខ្មែរក្រហម លោកក៏និយាយថា មិនដឹង -- ពួកគេនោះមិនមែនលក្ខណៈគំរាមកំហែងដោយផ្ទាល់ទេ គឺថាអ្នកដែលដើរតាមផ្លូវ

នោះ ប្រជាជននោះ គាត់និយាយគ្នាទេ ហើយគេទាំងអស់គ្នាគេជឿថាមានការទម្លាក់គ្រាប់បែកទេ ហើយរូបលោកផ្ទាល់នោះ តើលោកជឿថា មានការទម្លាក់គ្រាប់បែកទេ ឬក៏លោកមានគំនិតអីផ្សេងពីនុ៎ងហើយនៅពេលនោះ?

[១៥:៤០:៥៩]

**ឆ៖** ខ្ញុំជម្រាបដោយត្រង់ នៅពេលនុ៎ង ខ្ញុំជឿៗថា អ្នកដែលនិយាយប្រាប់មកខ្ញុំហ្នឹង គឺរឿងពិតណាស់ ថាទម្លាក់គ្រាប់បែកហ្នឹងណា។ ខ្ញុំជឿ ហើយខ្ញុំភ័យ អារឿងគ្រាប់បែកនេះឯង។ ខ្ញុំភ័យរឿងគ្រាប់បែកហ្នឹង។ អ្នកទាំងអស់គ្នាដែលដើរទៅជាមួយគ្នាតែពីរឿងហ្នឹង ខំធ្វើម៉េចឲ្យបានចេញឲ្យផុតពីព្រោះថា បើទម្លាក់គ្រាប់បែកមកមនុស្សច្រើនអ៊ីចឹង មិនដឹងជាងាប់ប៉ុន្មានទេ។ ម្ល៉ោះហើយ វាភ័យទាំងអស់គ្នា ទាំងខ្ញុំទាំងគេភ័យទាំងអស់គ្នា ភ័យរឿងទម្លាក់គ្រាប់បែកហ្នឹង។ មិនទាន់ទាំងបានទៅដល់ក្បាលថ្នល់ហ្នឹងផង ស្រាប់តែវាមានឮសូរបាញ់ប្រទូស្តប្រទាំងៗ គឺការបាញ់គ្នាជាមួយនឹងខ្មែរក្រហមមួយក្រុមជាមួយនឹងទាហានម្នាក់ ដែលទាហានហ្នឹងអត់ដាក់អាវុធ រួចហើយបាញ់គ្នាៗ ម្ល៉ោះហើយអ្នកដែលរត់ទាំងប៉ុន្មានហ្នឹងភ័យទាំងអស់គ្នា ភ័យខ្លាចត្រូវគ្រាប់ៗដែលគេបាញ់គ្នានុ៎ង។ អ្នកដែលទាហាន អ្នកដែលបាញ់ជាមួយនឹងខ្មែរក្រហម ប្រហែលជាប្រាំពីរ ប្រាំបីនាក់។ ខ្ញុំឃើញខ្មែរក្រហមត្រូវគ្រាប់ ក៏ប៉ុន្តែទាហាននុ៎ងស្លាប់ដែរ រួចហើយញ៉ូវ យើងភ័យញ៉ូវដោយសារឃើញការប្រយុទ្ធនឹងភ្នែក។ ម្ល៉ោះហើយយើងខ្ញុំនេះ ខ្ញុំគិតថា អត់ស្រួលទេ អត់ស្រួលអ៊ីចឹងតែម្តង អត់ស្រួលទេ។ ម្ល៉ោះហើយក៏ធ្វើដំណើរជាមួយគេជាមួយឯងបន្តិចម្តងៗ មហាក្តៅ ពីព្រោះពេលហ្នឹងថ្ងៃកាន់តែនេះហើយ ម៉ោងមួយ ម៉ោងពីររសៀលហើយ កាន់តែក្តៅទៅ ខ្ញុំឃើញមនុស្សទាំងអស់ជុំគ្នាដែលទៅហ្នឹង ខ្ញុំឃើញមនុស្សម្នាក់។ មនុស្សម្នាក់នោះគ្រួសារមួយនោះ ចាស់ពេក គេបងប្អូនហ្នឹងដាក់ចោលនៅលើគ្រែតែម្តង ហើយទៅបាត់ ហើយគាត់ៗដើរអត់រួច គាត់នៅលើគ្រែៗមួយនៅចិញ្ចើមថ្នល់។ មិនដឹងជា យើងអត់មានពេលសួរថា អ្នកណាអីអ្នកណាទេ ម្ល៉ោះហើយយើងទៅរហូតទៅដល់ជិតដល់ស្ពានជ្រោយចង្វា អ៎! ស្ពានអី ស្ពានមុន្នីវង្ស។

[១៥:៤៣:២០]

**ស៖** នៅពេលដែលលោកចេញពីក្រុងភ្នំពេញ ដែលស៊ីពេលអស់រាប់ម៉ោងនេះ តើខ្មែរក្រហមមានរៀបចំ ធ្វើការរៀបចំអ្វីមួយ ដើម្បីជួយអ្នកភ្នំពេញក្នុងការចេញពីទីក្រុងឬទេ ឬក៏មានគេផ្តល់ជាទឹកឬក៏ជាចំណីអាហារហូបចុក គឺថា ឧទាហរណ៍ដូចជា មនុស្សចាស់ដែលនៅលើគ្រែនេះ ដែលលោកបានឃើញ។ តើខ្មែរក្រហមមានបានធ្វើអ្វីទេ ដើម្បីជួយមនុស្សចាស់ជរាហ្នឹង ដើម្បីឲ្យគាត់ចាកចេញពី

ទីក្រុងភ្នំពេញបាននោះ? តើលោកអាចរៀបរាប់អំពីចំណាប់អារម្មណ៍របស់លោកបានទេ ទាក់ទងនឹងចំណុចនេះ?

**ឆ៖** គេប្រាប់ថា ឲ្យយើងចេញពីភ្នំពេញ ពីព្រោះអាមេរិកាំងនឹងទម្លាក់គ្រាប់បែកឥឡូវនេះឯង ឲ្យចេញឲ្យផុត។ ខ្មែរក្រហមជួយកន្លែងហ្នឹង ជួយថា ឲ្យចេញទៅអាមេរិកាំងទម្លាក់គ្រាប់បែកហើយ។ ប៉ុន្តែ អត់មានទម្លាក់គ្រាប់បែកផង។ ម្ល៉ោះហើយកុហកមួយ។ ចេញផុតទៅ ចេញផុតមិនទាន់ផុតទេ នៅតាមផ្លូវមានតើ អត់មានអ្នកណាម្នាក់ដែលប្រាប់ថា នែ៎នេះទឹក នេះបាយ ឬក៏ស្អីមួយ អត់មានទេ។ អត់ មនុស្សទៅទាំងហ្វូងដូចគោ មនុស្សទៅជាហ្វូងដែលអត់មានអ្នកណាជួយអ្នកណាស្អីទេ ទៅទាំងហ្វូងទៅម្តងតាមផ្លូវជាតិលេខ១ ចេះទៅដល់ស្ពានមុន្នីវង្សនេះឯង។ ម្ល៉ោះហើយ អត់មានទេ អត់មានថាជារបៀបថា ដឹកអ៊ីចេះ ឲ្យអ៊ីចេះ នេះគឺទទេ គឺសូន្យតែម្តងបាទ។ អត់មានទេៗ។

**ស៖** នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោក គឺថាមានលេខយោងដដែលនុ៎ង លោកបានឆ្លើយថា "លោកបានស្នាក់នៅក្បែរស្ពានមុន្នីវង្សនោះប្រហែលជា១៥ថ្ងៃ ហើយលោកបានឆ្លងស្ពាននោះហើយលោកនៅនឹងក្រោមស្ពាននោះប្រហែលជា១៥ថ្ងៃ"។ លោកអាចពន្យល់បានទេថា ហេតុអ្វីបានជាលោកអាចស្នាក់នៅកន្លែងនុ៎ងបានក្នុងពេលនុ៎ង? អ៊ីចឹងសូមឆ្លើយនឹងសំណួរហ្នឹងមួយសិន។

[១៥:៤៥:៥៨]

**ឆ៖** ខ្ញុំជម្រាបអ៊ីចេះ។ ខ្ញុំមកដល់ជិតស្ពានមុន្នីវង្សហើយ មកដល់ជិតស្ពានមុន្នីវង្ស មនុស្ស មកដល់ជិតស្ពានមុន្នីវង្ស -- ស្ពានវាតូច អាមនុស្សទៅនេះវាច្រើន ម្ល៉ោះហើយ វាកាន់តែយឺតៗ។ នៅខាងឆ្វេងដៃ បើកាលណាយើងឡើងស្ពានពីខាងលិចទៅ វានៅខាងឆ្វេងដៃ មានខ្មោចពីរនាក់ មនុស្សពីរនាក់ដែលស្លាប់នៅខាងឆ្វេងដៃ នៅខាងក្រោមហ្នឹង ម្ល៉ោះហើយយើងកាន់តែភ័យ ដោយសារឃើញខ្មោចខ្មោចពីរនៅខាងហ្នឹង។ ឆ្លងស្ពានយូរណាស់ បាទៗ *(ឮមិនច្បាស់)* ម្ល៉ោះហើយរហូតដល់មកកាន់តែល្ងាចហើយបានឆ្លងផុត។ ឆ្លងស្ពាន ខ្ញុំ ខ្ញុំនេះ ខ្លួនឯងនេះដែលខ្ញុំគិតថា អាមេរិកាំងមកទម្លាក់នេះ ខ្ញុំផុតហើយពីព្រោះថាបើវាទម្លាក់ៗនៅក្នុងភ្នំពេញ។ ម្ល៉ោះហើយខ្ញុំឆ្លងផុតហើយ ខ្ញុំនៅត្រើយ ត្រើយម្ខាង។

[១៥:៤៦:៥៤]

ម្ល៉ោះហើយ ដែលគេឲ្យអ្នកនៅភ្នំពេញចេញពីភ្នំពេញឲ្យផុតពីភ្នំពេញហ្នឹង គឺមិនមានរបៀបរៀបមិនមានរបៀបថា ណេះអញនាំឯងចេញទៅកន្លែងនេះៗ អត់មានទេ ឲ្យចេញផុតគឺជាមនុស្ស គឺប្រភេទបើៗខ្ញុំគិត ដែលខ្ញុំចង់និយាយថា មិនមែនជាមនុស្សទេ អ្នកឯងចប់ហើយ អ្នកឯងចេញក្រៅហើយ។

បន្ទាប់ពីហ្នឹងទៀត អ្នកឯងនឹងមានរឿងនឹងត្រូវធ្វើស្អីទៀត នឹងត្រូវជម្រះបញ្ជីស្អី ប៉ុន្តែឲ្យឯងចេញផុតពីភ្នំពេញសិន។ ម៉្លោះហើយ ខ្ញុំនៅខាងត្រើយម្ខាងជាមួយនឹងមនុស្សច្រើនណាស់ ពីព្រោះតាំងខ្ញុំ ចំពោះខ្លួនខ្ញុំតែម្តងហ្នឹង ខ្ញុំនៅតែមានចិត្តជឿមួយទៀតថា បីថ្ងៃ ម៉្លោះហើយតើខ្ញុំទៅឯណាបីថ្ងៃហ្នឹង? ខ្ញុំត្រូវតែនៅចាំដើម្បីត្រឡប់ចូលវិញ។ ខ្ញុំនៅមាននឹកចិត្តមួយថា ត្រឡប់ចូលមកភ្នំពេញវិញ។ ពីព្រោះប្រាប់ទាំងអស់គ្នា ប្រាប់ទាំងអស់គ្នាហ្នឹង គេប្រាប់ដល់ថា កុំឲ្យយកសម្លៀកបំពាក់ មិនបាច់យកស្អីទាំងអស់ ពីព្រោះតែបីថ្ងៃ។ ម៉្លោះហើយខ្ញុំនៅជាមួយនឹងមនុស្សទាំងផង ទាំងពួង ខ្ញុំនៅក្បាលស្ពានខាងកើតស្ពានមុន្នីវង្សជាមួយមនុស្សច្រើន ដែលក្នុងចំណោមមនុស្សហ្នឹងផ្ទះខ្លះបិទទ្វារ ផ្ទះខ្លះមនុស្សមិនដឹងជាទៅណាបាត់ គេរត់ទៅឯណា អីណីខ្ញុំមិនដឹង។

[១៥:៤៨:២៥]

ក៏ប៉ុន្តែ ច្រើនដែលនៅកកៗនៅខាងក្បាលស្ពាន ខាងកើតនៃស្ពានមុន្នីវង្ស។ ហើយយោធាដែលជាយោធាខ្មែរក្រហមហ្នឹងចុះឡើងៗ មានឡានគេដឹក មានអ្នកខ្លះជិះម៉ូតូ មានអ្នកខ្លះជិះកង់ ហើយទៅមកៗ ដែលមិនមានការឆ្លើយឆ្លងអីជាមួយនឹងមនុស្សទាំងហ្វូងៗហ្នឹងទេ។ ហើយមិនមានអ្នកណា មិនមានថា អ្ហឺ! អ្នកភូមិហ្នឹង មេឃុំ ភូមិក្បាលថ្នល់ខាងកើតហ្នឹងយកទឹកមកឲ្យទទួលទាន ឬក៏មានទាហានណាយកស្អីមកឲ្យទទួលទាន យកទឹកអីមកទទួលទាន អត់មានអ្នកណាជួយអ្នកណា គឺថាអត់មានតែម្តង អត់មាន។

**ស៖** តើគេឆ្លងស្ពានមុន្នីវង្សនោះអស់រយៈពេលប៉ុន្មាន? ប្រជាជនចេញពីទីក្រុងភ្នំពេញ ដែលគេបណ្តេញចេញពីទីក្រុងភ្នំពេញហ្នឹង ហើយឆ្លងស្ពានមុន្នីវង្សនោះ ដើម្បីចេញរួចនោះរយៈពេលប៉ុន្មានដែរ ហើយចរាចរណ៍នោះ តើលំហូរចរាចរណ៍ហ្នឹងយ៉ាងម៉េចដែរ នៅពេលដែលលោកនៅក្បែរស្ពានហ្នឹងឃើញចេញទៅដូចស្រួល ឬក៏ចេញពិបាក?

[១៥:៤៩:៤៩]

**ឆ៖** ពេលចេញហ្នឹងគឺថា ថ្ងៃ -- ខ្ញុំជម្រាបអ៊ីចេះ ខ្ញុំនិយាយអំពីថ្ងៃទី១៧។ ឥឡូវហ្នឹង ខ្ញុំមកល្ងាចទី១៧ហើយ ល្ងាចទី១៧ជិតយប់ហ្នឹង ខ្ញុំនៅឆ្លងផុតស្ពានហើយ ឆ្លងផុតស្ពាន។ ខ្ញុំនៅក្បាលស្ពានហើយ។ នៅពេលនុ៎ងយប់មកដល់ហើយ អ្នកដែលមិនទាន់ចេញផុតមកពីៗស្ពានហ្នឹង នៅត្រើយម្ខាងខាងលិចហ្នឹង មិនទាន់មកអស់ទេៗ។ ហើយខ្ញុំអត់ៗ វាត្រូវតែៗរកស្អីទទួលទាន វាល្ងាចខ្ញុំទទួលទានស្អីតាំងតែពីថ្ងៃមកមានបាយទទួលអីណា អត់មានបាយអីផងហ្នឹង។ ម៉្លោះហើយត្រូវតែរកមធ្យោបាយធ្វើម៉េចឲ្យខ្ញុំ

បានទទួលទាន ម្ល៉ោះហើយខ្ញុំរករបៀបដែលបានទទួលទានហ្នឹង។ សុំទោស ខ្ញុំជម្រាបអ៊ីចេះ នៅពេលដែលខ្ញុំមកដល់ក្បាលស្ពាន មកដល់ក្បាលស្ពានហ្នឹងនៅក្នុងឃ្លាំង១ដែលនៅខាង១១ជើងក្បាលស្ពានខាងលិចនៃស្ពានមុន្នីវង្សមានឃ្លាំងគេដាក់ស្ករ គេដាក់ស្ករឃ្លាំងធំណាស់សុទ្ធតែស្ករ ស្ករស។ រួចហើយខ្ញុំមាន១អ្នកដែលគេទៅ១ចូលកន្លែងនុំងទៅយកស្ករ ខ្ញុំទៅតាមគេ ខ្ញុំបានយកស្ករនឹងគេដែរ។ ម្ល៉ោះហើយយកស្ករនឹងគេដែរហ្នឹង គឺថាដូចអត់មែនរបស់ខ្ញុំទេ ក៏ដូចថាខ្ញុំលួចតែម្តង ពេល១ស្ករវាច្រើន ម្ល៉ោះហើយទម្លាក់ អ្នកណាក៏យក១។ ខ្ញុំក៏យកស្ករហ្នឹងដែរទៅជាមួយ ម្ល៉ោះហើយខ្ញុំលីស្ករហ្នឹងដើម្បីយកទៅជាមួយនៅផុតស្ពានមុន្នីវង្សហ្នឹង។ ហ្នឹងហើយទៅដល់ស្ពានមុន្នីវង្សហ្នឹងខ្ញុំនៅជាមួយគេជាមួយឯងអ៊ីចឹងទៅ។

[១៥:៥១:២៦]

ចំណែកឯយប់ហ្នឹងមនុស្សដែលមក នៅតែមានទាំង១យប់ហ្នឹង ដែលថាបន្តបន្ទាប់ -- ពីព្រោះវាណែន តាំងតែពីអាផ្លូវជំនាខាងហ្នឹងវាណែនមកផ្លូវជាតិលេខ១ ទាំងអស់។ វាចេញផ្លូវជាតិលេខ១ ម្ល៉ោះហើយវាណែនបាទ។

**ស៖** តើលោកអាចពន្យល់ប្រាប់តុលាការបានទេថា តើលោកឆ្លងកាត់រយៈពេល ១៥ថ្ងៃ ដែលលោកស្នាក់នៅក្រោម ឬក៏ជិតស្ពានហ្នឹងជាមួយនឹងអ្នកផ្សេងទៀត តើលោកធ្វើយ៉ាងម៉េចដើម្បីរកអាហារបរិភោគ ទឹកបរិភោគ ឬក៏ដើម្បីសម្រាន្តពេលយប់ជាដើមហ្នឹង តើស្ថានភាពក្នុងរយៈពេល ១៥ថ្ងៃនេះយ៉ាងម៉េចដែរ?

**ឆ៖** ថ្ងៃទី១ដំបូង ថ្ងៃ១៧ហ្នឹង ថ្ងៃទីដប់១ ចម្លែកណាស់ មានថ្ងៃនុំងមានភ្លៀង១។ ខ្ញុំអត់មាន១អីទាំងអស់មកជាមួយ។ មានស្ករដែលយកនៅកន្លែងឃ្លាំង រួចហើយទៅកន្លែងនុំងវាមាន១ គឺក្មេង១ជំទង់១វាដេញជ្រូក វាឃើញជ្រូកមួយ វាចាប់១ជ្រូក១។ ហើយខ្ញុំនេះមិនដឹងជាយ៉ាងម៉េចទេ ពេលនុំង ខ្ញុំឥឡូវហ្នឹងក៏ខ្ញុំគិតមិនឃើញហេតុអីម៉េចបានខ្ញុំធ្វើអ៊ីចុង។ ពេលដែលខ្ញុំប្រាប់អាក្មេង១ហ្នឹងវិញថា អត់ទេជ្រូកហ្នឹង ជ្រូករបស់ខ្ញុំ ជ្រូករបស់ខ្ញុំតើ។ គ្រាន់តែជ្រូករបស់ខ្ញុំតើ។ អាក្មេងហ្នឹង វាហាក់ដូច វាគិតថាអើ!ប្រហែលជារបស់គាត់មែន វាថាឥឡូវយក -- សម្លាប់ជ្រូកហ្នឹងទៅ ចែកគ្នា។ នៅពេលនុំងអាក្មេង -- ខ្ញុំក៏ប្រាប់ភ្លាមថា អត់អីទេ ឥឡូវយើងធ្វើអ៊ីចឹងទៅ បើឯងអ្នកធ្វើ ហ្នឹងហើយ។ ម្ល៉ោះហើយក្មេងនុំងវាធ្វើជ្រូកហ្នឹង ហើយវាឲ្យខ្ញុំពាក់កណ្តាល។ អាគ្រឿងក្នុងអី ខ្ញុំអត់មាននេះទេ ខ្ញុំយកតែពាក់កណ្តាល។ គឺពាក់កណ្តាលហ្នឹងហើយ ដែលខ្ញុំបានដោះដូរបានអង្ករ បានអីទទួលទាន។ ម្ល៉ោះហើយសាច់ជ្រូកហ្នឹងដែលខ្ញុំយកជាមធ្យោបាយបានទទួលទានល្ងាចនុំង។

[១៥:៥៣:៥៨]

**ស៖** ហើយចំពោះភេសជ្ជៈវិញ? ហើយនៅក្នុងរយៈពេល ១៥ថ្ងៃនោះ គឺថាត្រូវការចំណីអាហារ ហើយនិងទឹកអីជាដើម តើអ្នក -- មានខ្មែរក្រហមជួយលោកទេ? គេមកយកទឹកមកឱ្យលោកទេ?

**ឆ៖** មិនមានខ្មែរក្រហមណាម្នាក់យកទឹក មិនមានខ្មែរក្រហមណាម្នាក់មកគិតគូរអំពីរឿងយើងថា អាណាទៅណា អាណាទៅណា អត់មានទេ។ យើង -- ហើយទឹក តើខ្ញុំបានទឹកពីណាទទួលទានពីព្រោះទឹកទន្លេ ទឹកទន្លេនៅជិត នៅខាងក្រោមហ្នឹង ម្ល៉ោះហើយចុះយកទឹកទន្លេហ្នឹងទទួលទៅ។ ទទួលទានទឹកទន្លេហ្នឹងទៅ ហើយអាផ្នាំង ក៏ខ្ចះនៅជិតៗហ្នឹងអីយកអាផ្នាំងស្ងោរសាច់ហ្នឹងទទួលទាន ទទួលទានហើយនៅហ្នឹង ពីព្រោះថា ១ថ្ងៃ ២ថ្ងៃ ៣ថ្ងៃ នឹកថា អើ ! អញបានចូលវិញហើយ ៣ថ្ងៃ ទ្រាំទៅ៣ថ្ងៃ វាបានចូលវិញហើយ។ ហើយវាទ្រាំរួច៣ថ្ងៃ អត់មានឮហៅៗចូលវិញ អត់មានឮហៅចូលវិញ ខ្ញុំក៏ចាប់នេះហើយ ចាប់ៗ មានចិត្តមួយថាប្រហែលជាអត់មែនទេ ហើយវាអត់មានឮស្គរទម្លាក់គ្រាប់បែកសោះ វាអត់មានឮស្គរទម្លាក់គ្រាប់បែកនៅក្នុងៗភ្នំពេញ។ ម្ល៉ោះហើយខ្ញុំៗគិត ខ្ញុំពេលនុ៎ងខ្ញុំគិតថា អ្ហឺ! ប្រហែលជាបន្តិចទៀត ក៏ប៉ុន្តែការដែលសង្ឃឹមថានឹងចូលភ្នំពេញចាប់ៗបាត់ហើយៗ។ រួចហើយខ្ញុំនឹកឃើញពីរឿងថាតើខ្ញុំទៅៗឯណា? ខ្ញុំទៅរកគ្រួសារឪពុកម្តាយខ្ញុំ ឬមួយខ្ញុំទៅរកប្រពន្ធខ្ញុំ ពេលនុ៎ង? ម្ល៉ោះហើយក៏អត់មានៗអ្នកណា អត់មានខ្មែរក្រហមណាមកប្រាប់ថា ណេះឯងត្រូវទៅជិះអានេះ ឬក៏ឯងណោះទៅយកទឹកកន្លែងនោះមកទទួលទាន ឬអត់មានអ្នកណាម្នាក់មកធ្វើអីចឹងទេ។

[១៥:៥៦:០១]

**ស៖** ក្រោយពី ៣, ៤ថ្ងៃដំបូងនោះ ដែលលោកសង្ឃឹមថាត្រឡប់មកទីក្រុងភ្នំពេញវិញបាន តើលោកមានមានស្តាប់ឮការប្រកាសផ្សាយរបស់ពួកខ្មែរក្រហម? តើអ្នកដែលនៅម្តុំលោកដែរនោះ ដែលបានឆ្លងស្ពានដូចលោកដែរហ្នឹង អ៎! គេមានឆ្លងស្ពានត្រឡប់មកទីក្រុងភ្នំពេញដែរឬទេ? ហើយលោកមានបានឮគេប្រាប់ថាមានក្រុមគ្រួសារគេបានត្រឡប់ចូលមកក្រុងភ្នំពេញវិញហើយ។ លោកមានធ្លាប់ជួបប្រទះរឿងទាំងអស់ហ្នឹងទេ?

**ឆ៖** យើងឆ្លងផុត៣ថ្ងៃរួចហើយ។ ៣ថ្ងៃដែលៗថា ដែលប្រាប់ពីក្នុងពីកន្លែងបុរីកីឡាហ្នឹងថា ៣ថ្ងៃ។ ឥឡូវចប់៣ថ្ងៃហើយ។ ខ្ញុំនៅសង្ឃឹមថាបានត្រឡប់ចូលភ្នំពេញវិញ ពីព្រោះគេនិយាយ៣ថ្ងៃ។ ខ្ញុំជឿ ខ្ញុំៗជឿ។ ម្ល៉ោះហើយអត់មានទេ។ ថ្ងៃទី៤, ទី៥ ប្រហែលជាថ្ងៃទី៥, ទី៤ ឬទី៥ ថ្ងៃហ្នឹង។ គេចាប់ស្រែកពីក្នុងភ្នំពេញជាមីក្រូ។ មីក្រូហ្នឹងស្រែកហៅរកអ្នករដ្ឋការ ទាហាន នាយទាហាន ដើម្បីចូលទៅ

ក្នុងភ្នំពេញ ដើម្បីធ្វើការស្រោចស្រង់ជាតិ ធ្វើការជួយជាតិឡើងវិញ ពីព្រោះយើងអស់ចម្បាំងហើយ។ ម្ល៉ោះហើយមីក្រូស្រែក ហើយមាន ក្នុងពេលនុ៎ងមានមនុស្សនៅជាក្រុមៗ ជជែកគ្នាៗ ហើយមានអ្នកដែលនាំគ្នាទៅចូលទៅក្នុងនុ៎ងជាៗព្រុយៗទៅតាមៗស្ពានមុន្នីវង្ស។ ពេលនុ៎ងស្ពានមុន្នីវង្សមានមនុស្សទៅមកតិចណាស់ ភាគវាអស់ហើយ វាចេញផុតមកអស់រលីងហើយ ចេញផុតមកៗត្រើយខាងកើត។ ម្ល៉ោះហើយមានអ្នកគ្រួសារដែលសម្រេចចិត្តថាចូលទៅក្នុងហ្នឹង មានអ្នកដែលចូលទៅនុ៎ងតាមដែលគេហៅតាមមីក្រូ។

[១៥:៥៨:២៤]

**ស៖** លោកជារដ្ឋការ លោកមានបានឆ្លើយតបទៅនឹងការអំពាវនាវរបស់គេទេ? គេហៅត្រឡប់ឲ្យទីក្រុងភ្នំពេញវិញនោះ?

**ឆ៖** ខ្ញុំពេលនុ៎ងខ្ញុំគិត ខ្ញុំគិតខ្លួនឯងៗប្រាប់ថា៣ថ្ងៃ ប្រាប់ថាទម្លាក់គ្រាប់បែក អត់មានៗទម្លាក់គ្រាប់បែក។ ប្រាប់ថា៣ថ្ងៃ អត់មែន អត់មានចូលទៅវិញ អ្នកដែលចូលទៅៗតែម្នាក់ គ្រួសារនៅក្រៅទាំងអស់។ ខ្ញុំមានៗមន្ទិលសង្ស័យមួយថា មានហេតុអីមួយដែលជាមិនត្រឹមត្រូវក្នុងរឿងហ្នឹងហើយ។ ម្ល៉ោះហើយ ខ្ញុំអត់សម្រេចចិត្តថាចូលទៅក្នុងវិញក្នុងឋានៈខ្ញុំជាពេទ្យ ដែលនឹងមានប្រយោជន៍សម្រាប់ពេលអាសន្ននុ៎ង។ ខ្ញុំសម្រេចថា ខ្ញុំអត់ចូល ពីព្រោះខ្ញុំៗមើលទៅៗវាៗ វាមានរឿងដែលៗ ដែលមិនមែនជាធម្មតា។ ពីព្រោះដោយប្រាប់ថា៣ថ្ងៃ រួចហើយ៣ថ្ងៃផុតអត់ៗមាន។ ៣ថ្ងៃទម្លាក់ ថាយន្តហោះមកទម្លាក់គ្រាប់បែកឥឡូវនេះឯង។ ទម្លាក់គ្រាប់បែប៣ថ្ងៃ ក្នុង៣ថ្ងៃវាអត់មានគ្រាប់បែកណាមួយធ្លាក់ វាអត់មានគ្រាប់បែក មានយន្តហោះណាមកទម្លាក់សោះ។ រួចហើយពេលដែលហៅចូលហ្នឹង ៤ថ្ងៃ ថ្ងៃទី៤ ថ្ងៃទី៥ ម្ល៉ោះហើយខ្ញុំអត់ប៉ាន ខ្ញុំសូមខ្លាច។ ខ្ញុំខ្លាច ខ្ញុំថាប្រហែលជាមានហេតុការណ៍អីដែលៗមិនមែនជាត្រង់ ម្ល៉ោះហើយខ្ញុំអត់ទៅ។ ប៉ុន្តែមានអ្នកដែលៗចូលហ្នឹង ព្រុយៗគេដើរៗទៅ។ ប៉ុន្តែមិនមានគ្រួសារទៅទេ ទៅតែម្នាក់ឯងៗ។

[១៦:០០:០០]

**ស៖** តើលោកដឹងថាមានរឿងអ្វីកើតឡើងទៅអ្នកដែលឆ្លើយតបនឹងការអំពាវនាវនឹងដែរឬទេ ដែលត្រឡប់ចូលទៅក្នុងទីក្រុងភ្នំពេញវិញនោះ?

**ឆ៖** អត់សោះតែម្តង។ ពីព្រោះ ទៅបាត់ៗ ហើយគ្រួសារដែលនៅចាំហ្នឹង នៅចាំទៅ នៅចាំក្បាលថ្នល់ហ្នឹងទៅ នៅចាំត្រើយខាងកើត។ មិនដឹងជាគេទៅហ្នឹង គេធ្វើការ -- ទៅហ្នឹងគេធ្វើស្អីយើង

អត់ដឹងៗ យើងអត់មានបាទទទួលអ្នកណាហើយរួចគេចមកវិញថា គេច្របាច់ក ឬក៏ស្អីយើងអត់មាន។ អត់មានបានទទួលអាហ្នឹងដែរ គឺថាទៅបាត់នៅក្នុងភ្នំពេញតែម្តង។

**ស៖** ចុះបើតាមលោកយល់ឃើញនោះ ហេតុអ្វីបានជាមួយគាត់មិនត្រឡប់មកវិញ ឬក៏គាត់បម្រើឲ្យរបបថ្មី?

[១៦:០១:១៧]

**ឆ៖** ក្នុងពេលនុ៎ង ខ្ញុំអត់មានៗគិតអំពីរឿង អត់មានគិតអំពីរឿងថា អ្នកដែលទៅហ្នឹងបម្រើរបបថ្មីទេ។ ខ្ញុំអត់មានៗគិតឃើញអ៊ីចឹងទេ។ ពីព្រោះខ្ញុំគិតឃើញ ខ្ញុំមើលឃើញអាបាញ់ប្រទូស្តប្រទាំង ដេញមនុស្ស ដែលដេញមនុស្សចេញៗ រួចហើយប្រាប់ថាៗ បើវាទម្លាក់គ្រាប់បែក អត់មានទម្លាក់គ្រាប់បែក, ឲ្យចូលវិញ អត់មានចូលវិញ ហើយឲ្យចូលវិញទៅធ្វើការ ខ្ញុំមិនមាននឹក ថាៗមនុស្សហ្នឹងទៅធ្វើចូលទៅធ្វើការ ឬឲ្យមនុស្សហ្នឹងចូលទៅក្នុងហ្នឹង គឺថាខ្ញុំអត់ដឹង ខ្ញុំអត់ឃើញៗ ប៉ុន្តែមនុស្សហ្នឹង វាអត់មានមកវិញៗ អ្នកដែលទៅហ្នឹងអត់មានមកវិញ។ ខ្ញុំអត់ដឹងៗទេ។

**លោកស្រី គ្រីស្ទីន ម៉ាទីណូ៖**

លោកប្រធានខ្ញុំឃើញថា ពេលវេលាកាន់តែទៅមុខហើយ ខ្ញុំមិនដឹងថាលោកប្រធានអនុញ្ញាតបន្ត ឬក៏លោកប្រធានសម្រេចថា បញ្ចប់ថ្ងៃនេះត្រឹមនេះសិន។

[១៦:០២:៣៧]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណណាស់នូវការកត់សម្គាល់ដូច្នេះ។ ប៉ុន្តែសូមរំឭកក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីថា ទាំងក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញាផង គឺមានពេលតែមួយពេលទេ។ ឥឡូវនេះយើងប្រើប្រាស់ពេលវេលាអស់១ម៉ោងជាងហើយ ហើយអាទិត្យក្រោយហ្នឹង គឺតែមួយពេលទេ បានន័យថា ម៉ោងសម្រាកទី១ គឺចប់ហើយនៅដំណើរការនៃការសួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

អ៊ីចឹងទេ សំណួរគួរតែត្រូវគិតយ៉ាងណាធ្វើឲ្យការតាំងសំណួរដេញដោលហ្នឹងមានប្រសិទ្ធភាព ហើយនិងសក្តានុពលនៃសំណួរដែលត្រូវជ្រើសរើសដើម្បីយកមកសួរដេញដោល។ ទី២ អំមិញនេះក៏មានសំណួរដែលបានតាំងសំណួរឲ្យដើមបណ្តឹងរដ្ឋប្បវេណីនេះបង្ហាញអំពីទស្សនៈ ការយល់ឃើញផ្ទាល់ខ្លួនរបស់គាត់ដែរ។ ហើយការធ្វើដូច្នេះ គឺមិនត្រឹមត្រូវទេ។ គប្បីពិនិត្យមើលពិចារណាបញ្ហានេះឡើងវិញ

ទោះបីមិនមានភាគីជំទាស់ ហើយអង្គជំនុំជម្រះក៏ដោយសារចុងម៉ោងផងក៏ឲ្យសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណីនេះឆ្លើយបញ្ចប់ទៅ។

[១៦:០៣:៥៥]

កិច្ចដំណើរសវនាការសម្រាប់ថ្ងៃនេះ ដល់ពេលត្រូវសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃព្រហស្បតិ៍ទី២២ ខែវិច្ឆិកា ឆ្នាំ២០១២ សប្ដាហ៍ក្រោយចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ សវនាការនៅថ្ងៃព្រហស្បតិ៍សប្ដាហ៍ក្រោយនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណី មាស សារ៉ាន់ បញ្ចប់ ហើយនិងស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-105 ដែលនឹងផ្ដើមសួរដេញដោលដោយក្រុមមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមុនភាគីដទៃទៀតនៃរឿងក្ដី សូមភាគីនិងសាធារណជនជ្រាប។

លោក មាស សារ៉ាន់ ការស្ដាប់សក្ខីកម្មរបស់លោកមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះនឹងធ្វើសវនាការស្ដាប់សក្ដីកម្មរបស់លោកនៅថ្ងៃព្រហស្បតិ៍ទី២២ ខែវិច្ឆិកា ឆ្នាំ២០១២ សប្ដាហ៍ក្រោយទៀត។ ហើយអង្គជំនុំជម្រះសូមកោះហៅលោក អញ្ជើញមកបន្តផ្ដល់សក្ខីកម្មនៅថ្ងៃព្រហស្បតិ៍សប្ដាហ៍ក្រោយនេះទៀត។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនដើមបណ្ដឹងរដ្ឋប្បវេណីនេះ វិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់វិញចុះ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្ដល់សក្ខីកម្មវិញ នៅក្នុងបន្ទប់សវនាការនេះនៅព្រឹកថ្ងៃព្រហស្បតិ៍ ទី២២ ខែវិច្ឆិកា ឆ្នាំ២០១២ នៅវេលាម៉ោងប្រាំបួនព្រឹក។

អនុរក្សមន្ទីរឃុំឃាំងឲ្យនាំខ្លួនជនជាប់ចោទទាំងពីររូបលោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំង នៃ អ.វ.ត.ក វិញចុះ ហើយនិងឲ្យនាំខ្លួនពួកគាត់ទាំងពីររូប ត្រឡប់មកកាន់បន្ទប់សវនាការនេះវិញ នៅថ្ងៃព្រហស្បតិ៍ ទី២២ ខែវិច្ឆិកា ឆ្នាំ២០១២ សប្ដាហ៍ក្រោយនេះ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។ សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០៦ នាទី)*